# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣២ លេខ ៨ ខែសីហា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

- ពុទ្ធដីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . ៨៤១
- សេចក្ដីបរិសុទ្ធនៅឯណា ? របស់ព្រះពុទ្ធវង្ស កឹម-ត្លូរ . . . . ៨៥១
- ព្រះអភិធម្មបិដក (គម្ពីរព្រះកថាវត្ថុ) (តមក) លោក ប៊ូ-ប៊ូ រៀបរៀង ៨៦១
- មធុរសវាហិណី (តមក) សម្ដេចព្រះធម្មលិខិត ល្វី - ឯម ប្រែរៀបរៀង ១៧០
- មហោសថជាតក (តមក) លោក អឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម–ត្លូរ ពិនិត្យ . . . . . . . ៨៨១

*ផ្នែកអក្សរសាស្ត្រ*

- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ៨៩៥
- រឿងព្រេងភក់ទងនិងរំនៀមធ្វើពិធីសម្លាប់មនុស្សដើម្បីផ្ដាច់គ្រោះ លោក ថង-វង រៀបរៀង តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ . . . ៩២១
- រឿងព្រេងនិងរឿងបុរាណជប៉ុនក្នុងមជ្ឈមសម័យ(តមក) លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង៩២៩
- រឿងសាមកុក (តមក) ឧកញ៉ា ខ្វួ - កន ប្រែ . . . . ៩៣៧
- ពាក្យវប្បធម៌ លោក នាង-ហ៊ួ រៀបរៀង លោក សម-ឃាំង ពិនិត្យ . ៩៤៣

*ផ្នែកកំណត់ទិនប្បវត្តិការណ៍*

- ការធ្វើសន្និសីទ លោក អៀង-គុណ-សាគី រៀបរៀង . . . ៩៥២
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . ៩៥៨

មួយឆ្នាំ មាន ១២ សៀវភៅ ជំរៀបដារ ២៣០រ០០

# KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh


## sommaire

### Partie religieuse :


— La Vie du Buddha (suite) par Prah maha PANG-KHAT . . . 841
— La pureté par le Vén. KEM-TO . . . . . . . . . . . 851
— Prah Abhidhammapitaka (Prah Kathavathu) (suite) par M. BOU-PO 861
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM. revu et corrigé par le Vén. NHEAN-CHHOEUN . . . . . . . . . . . 870
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu par le Vén-KEM-TO 881


### Partie littéraire :


— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . 895
— Tradition khmère selon laquelle on simule la décapitation d'un homme pour le délivrer d'une mort fatale par M. THANG-VONG. . 921
— Contes et Légendes du Japon au Moyen-Age (suite) traduits par M. RAY-BUC . . . . . . . 929
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 937
— Activités de la Commission Culturelle par M NEANG-HOU revues par M. SAM THANG. . . . 943


### Notes et Chroniques :


- L'Art de faire la conférence par M. IENG-KOUN-SAKY . 952
- Dictionnaire Sanscrit-khmer (suite) par le Vén.PANG-KHAT 958


---


Prix d'abonnement annuel (comprenant 12 numéros): 230$00 .

# ផ្នែកសាសនា

## ពុទ្ធប្រវត្តិ

(តមក)

ព្រះមហា ប៉ាន់-ខាត់ រៀបរៀង

---

## អភិនិក្ខមនៈ ភាគភិសកកបាទី ៤

១– ការថែរក្សាព្រះពោធិសត្វ ២- វប្បមង្គល ៣- ពោធិសត្វប្រកបដោយកាមសុខគ្រប់យ៉ាង ៤- ពោធិសត្វទ្រង់សំដែងសិល្បៈ ៥- ទ្រង់អភិសេកនឹងព្រះនាងយសោធរា ។

### ១– ការថែរក្សាព្រះពោធិសត្វ

លុះព្រាហ្មណ៍ទាំង ៨ នាក់បានថ្វាយទំនាយរួចស្រេចហើយ ព្រះបាទសុទ្ធោទនៈត្រាស់សួរថា ព្រះរាជបុត្ររបស់យើងដែលនឹងចេញទៅសាងព្រះផ្នួសនោះ តើដោយហេតុដូចម្តេច ? ។ ពួកព្រាហ្មណ៍នោះក្រាបទូលថា ព្រោះព្រះរាជបុត្រស្តេចទតឃើញទេវទូតទាំង ៤ បែបគឺ មនុស្សជរា ១ មនុស្សព្យាធិ ១ មនុស្សស្លាប់ ១ បព្វជិត ១ ។ ស្តេចទ្រង់ព្រះសណ្តាប់ហើយ ទ្រង់មានសេចក្តីទុក្ខព្រួយខ្លាំង ទើបត្រាស់បង្គាប់ឲ្យរាជបុរសថែរក្សាព្រះរាជបុត្រដោយម៉ឺនមាត់ ប្រយ័ត្នមិនឲ្យឃើញទេវទូតទាំង ៤ នោះឡើយ ហើយទំនុកបំរុងព្រះរាជបុត្រក្នុងកាមសុខគ្រប់ប្រការ ព្រោះទ្រង់សព្វព្រះទ័យ

១- ព្រះគន្ថរចនាចារ្យសំដែងសរសើរសេចក្ដីអស្ចារ្យនៃព្រះពោធិសត្វ ជាអនេកប្បការ ទុកក្នុងគម្ពីរផ្សេង ៗ ទាំងគម្ពីរថេរវាទនឹងគម្ពីរមហាយាន, ក្នុងគម្ពីរលលិតវិស្តារៈលទ្ធិមហាយាន មានសេចក្ដីអស្ចារ្យប្លែកខ្លះ ៗ ដោយសង្ខេបដូច្នេះ គឺ

ក) ព្រះរាជកុមារស្ថិតនៅក្នុងបឋមវ័យនៅឡើយ ព្រះវរបិតាស្ដេចប្រទានរូបតូច ៗ ជាគ្រឿងក្រសាលគ្រប់យ៉ាង សុទ្ធតែជាវិការនៃមាសនឹងពេជ្រ មានរូបម្រឹគ, រូបដំរី, រូបសេះ, រូបគោ, ឬរូបបក្សី, រូបរទេះតូចជាដើម, ថ្ងៃមួយ ព្រះនាងបជាបតីគោតមីយកកណ្ដាលថ្វាយព្រះពោធិសត្វឲ្យប្រដាប់ព្រះស្ទាវង្គនឹងព្រះហស្ត, មាសពេជ្រនោះអាប់រស្មីបាត់រស្មីព្រះពោធិសត្វ, នាងទេពធីតាម្នាក់អាស្រ័យនៅក្នុងវិជិតនោះបង្គាប់ឲ្យដោះចេញ ហើយនិយាយថា បើផែនដីទាំងអស់ជាមាសជាពេជ្រនោះទើបអាចនឹងមានពន្លឺប្រសើរជាងបាន,ម្យ៉ាងទៀតព្រះសិទ្ធត្ថកុមារនេះ សូម្បីពន្លឺថ្ងៃ, ព្រះចន្ទ្រ, ព្រះអាទិត្យក៏មិនអាចកន្លងរស្មីព្រះពោធិសត្វបានឡើយ នឹងនិយាយថ្វីត្រឹមរស្មីមាសពេជ្រប៉ុណ្ណេះនេះ ។

ខ) ព្រះវររាជបិតាស្ដេចនាំព្រះរាជកុមារទៅនមស្ការទេវរូបនៅមន្ទីរទេវរូប លុះព្រះរាជកុមារស្ដេចទៅដល់ទ្វារមន្ទីរ ទេវរូបផ្សេង ៗ គឺរូបព្រះឥសូរ, រូបស្កន្ទកុមារ, រូបព្រះវិស្ណុ, រូបកុវេរៈ រូបព្រះឥន្ទ្រ, រូបព្រះព្រហ្មជាដើមទាំងឡាយ ខ្លះទេវរូបក្រោកឡើងចូលមកថ្វាយបង្គំទៀបព្រះបាទរាជឱរសហើយពោលសរសើរថា ភ្នំព្រះសុមេរុ មិននមស្ការគ្រាប់ស្នូវទេ, នព្វមហាសមុទ្រមិននមស្ការទឹកក្នុកទេ ព្រះអាទិត្យមិននមស្ការអំពិលអំពែកទេ . . . ។

គ) កាលព្រះពោធិសត្វមានវ័យធំបន្តិចឡើង ព្រះវររាជបិតាស្ដេចឲ្យទៅរៀនអក្សរនៅក្នុងសំណាក់ព្រាហ្មណ៍វិស្វមិត្រ, ព្រះពោធិសត្វត្រាស់សួរថា «បពិត្រវិស្វមិត្រ! លោកបង្រៀនអក្សរសាស្ត្រដូចម្ដេច ? ព្រាហ្មណ៍វិស្វមិត្រក៏រាប់អក្សរ ៦៤ តួថ្វាយ និមិត្តតែព្រាហ្មណ៍រាប់ចប់ ព្រះពោធិសត្វក៏រៀនចប់ ឆ្លៀវឆ្លាសជាងគ្រូទៅទៀត, ព្រះពោធិសត្វត្រាស់សួរទៅទៀតថា «លោកគ្រូបង្រៀនអក្សរសាស្ត្រអីតទៅទៀត ? » ព្រាហ្មណ៍វិស្វមិត្រទាល់បំណេះ នៅស្ងៀមរកឆ្លើយមិនកើត បែរទៅជាសូមរៀនពីព្រះពោធិសត្វវិញ ។

## ២- វប្បមង្គល

ពិធីវប្បមង្គល (ច្រត់ព្រះនង្គ័ល) ជានក្ខត្តឫក្សសម្រាប់ព្រះនគរ គេបានតាក់តែងព្រះនគរល្អរុងរឿងហាក់ដូចជានគរនៃទេវតា ព្រះបាទសុទ្ធោ-ទនៈមហារាជ ស្ដេចព្រមដោយចតុរង្គសេនារាជបរិវារ យាត្រាទៅកាន់ស្រែជាទីច្រត់ព្រះនង្គ័ល ទ្រង់ព្រះរាជានុញ្ញាតឱ្យព្រះរាជកុមារស្ដេចទៅតាមផង ហើយទ្រង់តាក់តែងរាជដ្ឋានក្រោមដើមជម្ពូព្រឹក្សថ្វាយប្រថាប់ ដល់ពេលច្រត់ព្រះនង្គ័ល ពួកស្រីស្នំដែលជាបរិចារ បបួលគ្នាចេញទៅមើលពិធីច្រត់ព្រះនង្គ័លអស់ ព្រះពោធិសត្វស្ដេចនៅតែមួយព្រះអង្គ ទតមើលមិនឃើញព្រះរាជបរិវារនៅជិតខាង ក៏ស្ដេចតាំងផ្គត់ព្រះភ្នែនពែនព្រះបាទចំរើនអានាបានស្សតិកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចបឋមជ្ឈាន ។ គ្រានោះ សេចក្ដីអស្ចារ្យប្លែកចំឡែកកើតឡើង គឺបណ្ដាដើមឈើទាំងអស់ សុទ្ធតែស្រមោលបោលទៅតាមវិថីនៃមណ្ឌលព្រះអាទិត្យ ប្លែកតែស្រមោលដើមជម្ពូព្រឹក្សមួយប៉ុណ្ណោះ ដែលព្រះពោធិសត្វស្ដេចប្រថាប់នៅ មិនស្រមោលបោលទៅតាមដូចឈើទាំងពួងទេ ស្រ-មោលនោះតាំងនៅទីដដែល ដើម្បីនឹងការពារព្រះពោធិសត្វហាក់ដូចជាមានវិញ្ញាណ, ឯពួកស្រីស្នំរាជបរិវារត្រឡប់មកពីមើលពិធីច្រត់ព្រះនង្គ័លវិញ ឃើញសេចក្ដីអស្ចារ្យប្លែកដូច្នោះ ក៏យកសេចក្ដីនោះទៅក្រាបបង្គំទូលព្រះបាទសុទ្ធោទនៈ ស្ដេចទ្រង់ព្រះសណ្ដាប់ហើយ ស្ដេចចេញមកទស្សនា

ទតឃើញប្រាកដដូច្នោះ ទើបលើកព្រះហស្តប្រណម្យព្រះពោធិសត្វជា ព្រះកិត្តិយស ។ ការលើកព្រះហស្តប្រណម្យនេះ ជាលើកទី ២ ។

## ៣ ពោធិសត្វប្រកបដោយកាមសុខគ្រប់យ៉ាង

ព្រះសិទ្ធត្ថកុមារទ្រង់មានវ័យចំរើនឡើងដោយលំដាប់ មានព្រះជន្មាយុបាន៧ឆ្នាំ ព្រះរាជបិតាស្តេចត្រាស់ឲ្យជីកស្រះ៣ដាំឈូកផ្សេងៗថ្វាយ ឲ្យតាក់តែងគ្រឿងអលង្ការយ៉ាងប្រណីតគ្រប់ប្រការ សុទ្ធតែយកមកពីដែនកាសីដែលគេសន្មត់ថាប្រសើរក្នុងកាលនោះមកថ្វាយ ព្រមទាំងឲ្យសាងប្រាសាទ ៣ គឺ រមយប្រាសាទ ១ សុរមយប្រាសាទ ១ សុភប្រាសាទ ១ សម្រាប់រដូវទាំង ៣ ថ្វាយព្រះរាជឱរសទៀត ដូចការសិតដែលទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា (១)

"ម្នាលភិក្ខុទាំងឡាយ! តថាគតជាខត្តិយសុខមាលបុគ្គល ជាខត្តិយសុខមាលបុគ្គលដ៏ក្រៃលែង ជាខត្តិយសុខមាលបុគ្គលយ៉ាងប្រសើរជាទីបំផុត, គេជីកស្រះ ៣ ក្នុងវាំងនៃបិតាតថាគត ស្រះមួយដាំឧប្បល (លិបង់) ស្រះមួយដាំបទុម (ឈូកក្រហម) ស្រះមួយទៀតដាំបុណ្ឌរីក (ឈូកស) ដើម្បីប្រយោជន៍ដល់តថាគត, មិនមែនត្រឹមតែក្លិនបន្ទន់ដែលតថាគតសម្រាប់ប្រើ

---

១-បឋមបណ្ណាសក ទេវទូតវគ្គ, តិក. អំ. សៀវ. ទំព័រ ១០៣ ។

ដែលយកមកពីដែនកាសីប៉ុណ្ណោះទេ សូម្បីសំពត់សម្រាប់ជូតក្បាល, អាវ, សំពត់ស្លៀក, សំពត់ដណ្តប់ ក៏សុទ្ធតែយកមកពីដែនកាសីទាំងអស់ គេបាំងស្វេតច្ឆត្រឲ្យតថាគត ដោយបំណងនឹងការពារនូវត្រជាក់, ក្តៅ, លំអងធូលី, ស្មៅឬទឹកសន្សើម កុំឲ្យប៉ះពាល់កាយតថាគត មានប្រាសាទ ៣ ខ្នងសម្រាប់តថាគត ប្រាសាទ ១ សម្រាប់ហេមន្តរដូវ ប្រាសាទ ១ សម្រាប់គិម្ហរដូវ ប្រាសាទ ១ ទៀតសម្រាប់វស្សានរដូវ តថាគតនៅលើប្រាសាទ សម្រាប់វស្សានរដូវ អស់ ៤ ខែ មិនចុះពីប្រាសាទឡើយ ឲ្យគេបំរើដោយតូរ្យតន្ត្រី សុទ្ធតែស្រីឥតមានបុរសលាយឡំទេ ។

ម្នាលភិក្ខុទាំងឡាយ ! នៅក្នុងរាំងបិតាតថាគត គេឲ្យសុទ្ធតែបាយនៃអង្ករស្រូវសាលី លាយដោយសាច់ ដល់ទាសកម្មករ (ពោរពាសឥតខ្វះខាត) មិនមែនដូចទីដទៃទេ ដែលគេឲ្យតែបាយបុងអង្ករនឹងទឹកជ្រក់ដល់ទាសកម្មករ " ។

មួយទៀត ព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះមាគណ្ឌិយព្រាហ្មណ៍ថា (១)

១ មាគណ្ឌិយសូត្រ, បរិញ្វជកវគ្គ ម. ម. សៀវ. ២៤, ទំព័រ ៦៨ ។

"ម្នាលមាគណ្ឌិយ ! កាលពីដើម តថាគតនៅជាគ្រហស្ថ ក៏ធ្លាប់ឆ្អែតឆ្អន់ ប្អូលបិត្តឲ្យគេបម្រើដោយកាមគុណទាំង ៥ គឺ

១-រូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ត្រេកអរពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ,

២-សំឡេងដែលគប្បីដឹងដោយត្រចៀក ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ,

៣-ក្លិនដែលគប្បីដឹងដោយច្រមុះ ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ,

៤-រសដែលគប្បីដឹងដោយអណ្តាត ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ,

៥–ផោដ្ឋព្វ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ, ។

ម្នាលមាគណ្ឌិយ! តថាគតនោះ មានប្រាសាទ ៣ ខ្នង ប្រាសាទមួយសម្រាប់រដូវភ្លៀង ប្រាសាទមួយសម្រាប់រដូវរងា ប្រាសាទមួយសម្រាប់រដូវក្តៅ ។ តថាគតឲ្យគេបម្រើដោយតន្ត្រីដែលឥតបុរស លើប្រាសាទសម្រាប់នៅក្នុងរដូវភ្លៀងអស់ ៤ ខែ មិនដែលចុះមកខាងក្រោមសោះ ។ លុះក្រោយមក តថាគតដឹងច្បាស់ នូវហេតុដែលនាំកើតឡើងផង នូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌សម្រាប់រលាស់ចោលផង ដែលសុទ្ធតែសម្រាប់កាមទាំងឡាយតាមសេចក្តីពិតហើយ ក៏លះនូវសេចក្តីប្រាថ្នាក្នុងកាម បន្ទោរបង់នូវសេចក្តីក្តៅក្រហាយក្នុងកាម ប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់នៅក្នុងសន្តានសម្រាន្តនៅ ។ តថាគត

ឃើញសត្វឯទៀត ដែលមិនទាន់ប្រាសចាកតម្រេក ក្នុងកាមទាំងឡាយ ដែលតម្រេកក្នុងកាមកំពុងទំពាស៊ី ជាអ្នកក្ដៅក្រហាយព្រោះកាម កំពុងសេពនូវកាមទាំងឡាយ តថាគតមិនប្រាថ្នានូវពួកជនទាំងនោះ មិនរីករាយក្នុងការសេពកាមនោះ សេចក្ដីនោះ ព្រោះហេតុអ្វី ?

ម្នាលមាគណ្ឌិយ! ព្រោះថាកាលបុគ្គលត្រេកអរដោយសេចក្ដីត្រេកអរ វៀរលែងចាកកាមទាំងឡាយ វៀរលែងចាកអកុសលធម៌ទាំងឡាយក៏នៅជាអ្នកហោកបយ ព្រោះហេតុដូច្នោះ តថាគតទើបមិនប្រាថ្នា មិនរីករាយក្នុងការសេពកាមនោះឡើយ ” ។

## ៤-ពោធិសត្វសំដែងសិល្បៈ

*កាលព្រះពោធិសត្វមានព្រះជន្មាយុ ១៦ វស្សា គួរមានអគ្គមហេសី ព្រះរាជបិតាត្រាស់បង្គាប់ពួកព្រះញាតិសក្យរាជត្រកូល ឲ្យនាំព្រះរាជធីតាមកថ្វាយពោធិសត្វ ពួកសក្យរាជត្រកូល បដិសេធមិនព្រមថ្វាយ ហើយពោលទោសថា ព្រះរាជកុមារស្ដេចប្រកបដោយរូបសម្បត្តិល្អ ស្អាតជំនាញក្នុងការកីឡា តែទ្រង់មិនឈ្លាសវៃក្នុងយុទ្ធសាស្ត្រឲ្យសមតាមខត្តិយ*

ត្រកូលនោះ ព្រះវររាជបិតាទ្រង់ព្រះសណ្ដាប់ពាក្យនេះហើយ ទើបមានព្រះបន្ទូលចំពោះព្រះពោធិសត្វ ព្រះពោធិសត្វក្រាបទូលតបថា “បពិត្រព្រះអង្គ! តអំពីថ្ងៃនេះ ៧ ថ្ងៃ សូមទ្រង់ព្រះមេត្តាប្រោសឲ្យប៉ាវគងទូងកើ ខ្ញុំព្រះអង្គនឹងសំដែងសិល្បសាស្ត្រ ចំពោះព្រះភ័ក្ត្រ នៃព្រះញាតិទាំងឡាយ” ។

លុះដល់ថ្ងៃទី ៧ ព្រះពោធិសត្វស្ដេចចេញសំដែងរិទ្ធិបេស្កាឲ្យឃើញប្រចក្សគ្រប់គ្នា ស្ដេចឲ្យប្រជុំខ្មាន់ធ្នូ ៤ នាក់ ដែលធ្លាប់ស្គាល់ជំនាញគឺ អក្ខណវេធី ១ វាលវេធី ១ សរវេធី ១ ទឹងសទ្ទវេធី ១ ហើយស្ដេចសំដែងសិល្បធ្នូ ១៦ ប្រការ(១) ដែលឥតមានខ្មាន់ធ្នូណាមួយប្រឡងបេស្កានឹងព្រះអង្គបាននៅកណ្ដាលទីប្រជុំមហាជនក្នុងក្រុងកបិលពស្ដុ ចំពោះមុខព្រះញាតិសក្យរាជត្រកូលទាំងឡាយ ។

## ៥-ទ្រង់អភិសេកនឹងនាងយសោធរា

លំដាប់នោះ ពួកសក្យរាជត្រកូលឃើញសេចក្ដីអស្ចារ្យដូច្នោះហើយ អស់សេចក្ដីសង្ស័យ ទើបព្រមព្រៀងគ្នានាំយកខត្តិយកញ្ញាមកថ្វាយពោធិ-

---

១– ក្នុងបឋមសម្ពោធិកថា មិនឃើញមានភាយឈ្មោះវិជ្ជាធ្នូទេ, គ្រាន់តែមានសេចក្ដីថា ពោធិសត្វបាញ់ពេមព្រាយដែលបិតនៅទីឆ្ងាយក្នុងទីចំនួន ១ យោជន៍បាន ។ គម្ពីរខ្លះថា វិជ្ជាធ្នូ មាន ១២ ប្រការ ។

សត្វគ្រប់ ៗ ព្រះអង្គ(១) ។ ព្រះបាទសុទ្ធោទនៈ ស្ដេចទ្រង់អភិសេកព្រះរាជបុត្រនឹងព្រះនាងពិម្ពាយសោធរា ជាព្រះរាជបុត្រីព្រះបាទសុប្បពុទ្ធនឹងនាងអមិតា ដែលជាកនិដ្ឋភគិនីព្រះអង្គឲ្យជាព្រះអគ្គមហេសី, ព្រះពោធិសត្វស្ដេចនៅក្នុងប្រាសាទទាំងឡាយ ៣ នោះ តាមរដូវទាំង ៣ មានស្ត្រីចាំច្រៀងរាំប្រគំដេញដំតូរ្យតន្ត្រីថ្វាយទាំងយប់ទាំងថ្ងៃ ឥតមានបុរសម្នាក់នៅលាយឡំជាមួយឡើយ ហាក់ដូចជាទេវបុត្រដែលស្ថិតនៅស្ថានសួគ៌ទេវលោក រហូតដល់ព្រះជន្មាយុបាន ២៩ ព្រះវស្សា ។

---

១- សេចក្ដីនេះ សូម្បីគម្ពីរយើងថេរវាទក៏មានសេចក្ដីប្លែកគ្នា, ក្នុងបឋមសម្ពោធិកថាថា កាលព្រះបាទសិរីសុទ្ធោទនៈ ត្រាស់ឲ្យយកវត្ថុយកញ្ញាមកថ្វាយ ពួកព្រះញាតិមិនទាន់ព្រមថ្វាយដោយអាងហេតុថា ព្រះពោធិសត្វមិនចេះវិជ្ជាសម្រាប់គ្រប់គ្រងប្រទេស, នៅក្នុងអវិទូរនិទាន ឯកនិបាតវណ្ណនា បឋមភាគថា ព្រះពោធិសត្វបានអភិសេកនឹងនាងយសោធរារួចហើយ បានពួកព្រះញាតិលើកទោសព្រះពោធិសត្វថាមិនចេះវិជ្ជាអ្វី ។ ក្នុងគម្ពីរលលិតវិស្តរខាងមហាយានឆ្លើយត្រូវគ្នានឹងបឋមសម្ពោធិកថាដែរ ហើយមាននិយាយអំពីការប្រឡងប្លែកៗ ទៅទៀត ក្នុងគម្ពីរបឋមសម្ពោធិកថា គ្រាន់តែប្រាប់ថា ១២ ប្រការ, ក្នុងគម្ពីរលលិតវិស្តារនេះ មានសេចក្ដីថា ក្នុងទីប្រជុំនោះ មានបុរសម្នាក់ចេះអក្សរសាស្ត្រចប់យ៉ាងជ្រៅជ្រះចូលមកប្រឡង អាចារ្យវិស្វមិត្រចេញមកប្រាប់បុរសនោះថា ឥតអំពើទេ ព្រះរាជកុមារនេះជាអ្នកប្រាជ្ញជាងខ្ញុំទៅទៀត និយាយថ្មីត្រឹមអ្នកប៉ុណ្ណោះ. សក្យរាជឈ្មោះអជ៌ុនៈ ចូលមកប្រឡងគណិតសាស្ត្រ (វិជ្ជាលេខ) នឹងពោធិសត្វ យកចំណោទដែលពិបាកទីបំផុតយ៉ាងច្រើនមកសួរពោធិសត្វ ។

(នៅមានត)

# សេចក្ដីបរិសុទ្ធិនៅឯណា?

របស់ព្រះពុទ្ធវង្ស គឹម-ទូរ

---

សេចក្ដីបរិសុទ្ធិជាគូនឹងសេចក្ដីមិនបរិសុទ្ធិ ។ សេចក្ដីបរិសុទ្ធិគឺអ្វី? សេចក្ដីបរិសុទ្ធិគឺស្អាតកាយ, ស្អាតវាចា, ស្អាតចិត្ត, មិនសៅហ្មងដោយអំពើអាក្រក់ណាមួយ ដែលគួរឲ្យអ្នកផងតិះដៀលបាន ។ សេចក្ដីមិនបរិសុទ្ធិគឺអ្វី? សេចក្ដីមិនបរិសុទ្ធិ មានដំណើរផ្ទុយគ្នានឹងសេចក្ដីបរិសុទ្ធិ ដូចបាននិយាយមកហើយនេះ ។

មនុស្សប្រភេទណាក៏ដោយ នោះជាន់ខ្ពស់ក្ដី ជាន់កណ្ដាលក្ដី ជាន់ទាបក្ដី ជាអ្នកចេះលៃលករៀបចំទុកដាក់កាយឲ្យសមរម្យទៅតាមឋានៈរបស់ខ្លួន មិនប្រព្រឹត្តប្រឡើសបើស ជាអនុលោមតាមច្បាប់សម្រាប់ផ្លូវលោក នឹងច្បាប់សម្រាប់ផ្លូវធម៌ តាំងក្នុងទីចំពោះមុខ តាំងក្នុងទីកំបាំងមុខ មិនប្រើកម្លាំងកាយរំលោភឲ្យប្រព្រឹត្តទៅហួសហេតុហួសទំនង មានការប្រហារជីវិតសត្វនឹងការលាក់លួចឆក់ដណ្ដើមរឹបជាន់ យកទ្រព្យសម្បត្តិរបស់អ្នកដទៃដោយអយុត្តិធម៌ជាដើម, ជាអ្នកមានឫកពាសុភាពរាបសាល្អ តាំងមានចរិយាធម៌នឹងអបចាយនធម៌ចំពោះអ្នកដទៃមិនរើសមុខយ៉ាងនេះជាដើមហៅថា កាយបរិសុទ្ធិ បរិសុទ្ធស្អាតដោយកាយ ។

មនុស្សណាមួយកាលបើបញ្ចេញវាចានិយាយពីអ្វី វាចានោះឯងមិនដែលបៀតបៀន ឲ្យកើតសេចក្តីក្តៀសដល់អ្នកដទៃ ច្រើនតែនិយាយពាក្យណាដែលនាំឲ្យមានប្រយោជន៍ ជាវាចាសុភាពរាបសាពីរោះមិនទ្រគោះបោះបោក ប្រមាថមើលងាយអ្នកដទៃ, ជាសំដីគួរគេជ្រះថ្លា គួរគេចង់ស្តាប់ វាងផុតពីទុច្ចរិតទាំង ៤ យ៉ាង មិននាំឲ្យប៉ះពាល់ខូចសិទ្ធិអ្នកដទៃ យ៉ាងនេះជាដើមហៅថា វាចាបរិសុទ្ធិ បរិសុទ្ធស្អាតដោយវាចា ។

មនុស្សណាមួយ បានសង្រួមប្រុងប្រយ័ត្នសំអាតចិត្តរបស់ខ្លួន ឲ្យបរិសុទ្ធ ឲ្យតាំងនៅក្នុងកុសលធម៌ ប្រាសចាកមនោទុច្ចរិតទាំង ៣ យ៉ាង មិនបណ្តោយឲ្យចិត្តក្រេវក្រោធលោភលន់ឈ្នានីសច្រណែននិន្ទាគេ យ៉ាងនេះជាដើមហៅថា ចិត្តបរិសុទ្ធិ បរិសុទ្ធស្អាតដោយចិត្ត ។

អ្នកដែលបានកើតមកមានជីវិតរស់នៅក្នុងលោកនេះ មានសញ្ជាតិជាមនុស្សទាំងមួយៗគប្បីញុំាងកាយ វាចា ចិត្ត ឲ្យស្ងប់រៀបរយល្អទៅតាមច្បាប់លោកនិងច្បាប់ធម៌ដែលមានគំរូទុកមក ពុំគួរបើកអំណាចបណ្តោយឲ្យកាយ វាចា ចិត្ត ប្រព្រឹត្តពាយងាយតាំងនៅខាងក្រៅច្បាប់ឡើយ ព្រោះថាការដែលបានទទួលសុខភាព, វឌ្ឍនភាពនិងជោគជ័យគ្រប់ជំពូករបស់មនុស្សសត្វនីមួយៗ រមែងកើតអំពីកាយ វាចា ចិត្តដ៏បរិសុទ្ធល្អ ,

ឯការដែលបានទទួលទុក្ខទោសគ្រោះថ្នាក់អពមង្គលគ្រប់ជំពូក គឺមែន កើតមកអំពីកាយ វាចា ចិត្ត មិនបរិសុទ្ធល្អដែរ ព្រោះកាយ វាចា ចិត្ត ទាំង ៣ នេះ ទុកដូចជាទ្វារសម្រាប់បើកឱកាសឲ្យសុខនិងទុក្ខហូរចូលមក ឬថាជាប្រធានជាទីមុខក្រសួង ជាអ្នកបង្កហេតុឲ្យកើតសុខ និងទុក្ខ ក៏បាន ។ ព្រោះហេតុនោះ សេចក្ដីបរិសុទ្ធិនិងសេចក្ដីមិនបរិសុទ្ធិទាំងពីរនេះ ដែលកើតឡើងហើយរមែងឲ្យផលដល់បុគ្គលអ្នកធ្វើចំពោះខ្លួនឯង បើនិយាយតាមសាមញ្ញពាក្យថា អ្នកណាធ្វើក៏ជារបស់អ្នកនោះ ឥតមានអ្នកណាធ្វើឲ្យអ្នកណាបរិសុទ្ធិឬសៅហ្មងបានឡើយ ។ ប៉ុន្តែខាងលទ្ធិព្រាហ្មណ៍មានសេចក្ដីប្រកាន់ថា អំពើបាបណាមួយដែលបុគ្គលធ្វើហើយ គេអាចលាងជំរះបណ្ដែតឬបន្សាត់ចោលបានដោយធ្វើពិធីមានង្ងូតទឹកជាដើម គឺពេលដែលកំពុងង្ងូតទឹកជំរះមន្ទិលកាយ បាបនោះឯងក៏ជ្រះស្អាតអណ្ដែតរសាត់ទៅតាមខ្សែទឹកជាមួយនឹងមន្ទិលកាយដែរ ។ មានលទ្ធិដទៃខ្លះទៀតប្រកាន់ថា អំពើបាបណាមួយ ទោះបីធ្ងន់ក្ដីស្រាលក្ដី ដែលបុគ្គលធ្វើហើយ គេអាចទៅលន់តួអង្វរករសូមខមាទោសចំពោះព្រះម្ចាស់សួគ៌ ដើម្បីឲ្យព្រះម្ចាស់សួគ៌នោះប្រោសប្រាណត្រាប្រណីលើកទោសកំហុសរបស់ខ្លួនចោលចេញបាន ដូចគ្នានឹងព្រះមហាក្សត្រម្ចាស់ផែនដីទ្រង់ប្រោសប្រាណលើកទោសព្រះរាជទានដល់អ្នក

ធ្វើខុស ឲ្យផុតចាកព្រះពុទ្ធអាជ្ញាដែរ យ៉ាងនេះជាដើម ។

បំណែកខាងព្រះពុទ្ធសាសនា មានសេចក្តីផ្ទុយគ្នានឹងលទ្ធិទាំងនោះថា អំពើបាបដែលបុគ្គលធ្វើដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង, មិនធ្វើបាបដោយខ្លួនឯង រមែងបរិសុទ្ធដោយខ្លួនឯង ។ សេចក្តីបរិសុទ្ធិនិងសេចក្តីសៅហ្មង រមែងកើតចំពោះខ្លួនអ្នកធ្វើតែម្យ៉ាងប៉ុណ្ណោះ មិនមែនកើតចំពោះហេតុដទៃឡើយ ។ បុគ្គលដែលសៅហ្មងព្រោះអកុសលកម្ម ដែលបរិសុទ្ធចាកសេចក្តីសៅហ្មង ព្រោះកុសលកម្មប្រកបដោយប្រាជ្ញាដែលយល់ត្រូវ ។ អ្នកណាពិចារណាឃើញច្បាស់ដោយប្រាជ្ញាថា: ការប្រព្រឹត្តិធ្វើអកុសលកម្មគឺអំពើជាអកុសលផ្សេងៗ មានសម្លាប់សត្វ និងលួចណាក់ឆក់ដណ្តើមកំហែងប្លន់ប្រវ័ញ្ចយកទ្រព្យសម្បត្តិរបស់គេដោយអយុត្តិធម៌ជាដើម អំពើទាំងនេះសុទ្ធតែជាកម្មមានទោសជាផ្លូវអបាយ មិនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ខ្លួននិងអ្នកដទៃ ហើយក៏លះបង់គឺមិនធ្វើអកុសលកម្មនោះតទៅទៀត អ្នកនោះឈ្មោះថាជាអ្នកបរិសុទ្ធស្អាត សូម្បីជាអ្នកមានសេចក្តីសៅហ្មងជិតជាមជាប់មកអំពីមុនខ្លះ ព្រោះអកុសលកម្មដែលខ្លួនធ្វើដោយសេចក្តីប្រហែសធ្វេសល្ងង់ខ្លៅ ក៏គង់ត្រឡប់ទៅជាអ្នកបរិសុទ្ធស្អាតដោយកុសលកម្ម ដែលធ្វើក្នុងកាលជាខាងក្រោយដោយពិត សមដូចពុទ្ធភាសិតថា :

យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

អ្នកណា ធ្វេសប្រហែសក្នុងកាលពីមុន លុះកាលជាខាងក្រោយមក ក៏ងាកបែរទៅជាមិនធ្វេសប្រហែសវិញ អ្នកនោះទើបឈ្មោះថា ធ្វើលោកឲ្យភ្លឺស្វាងរុងរឿង ដូចជាព្រះចន្ទដែលចេញផុតពីពពក ។

អធិប្បាយបញ្ជាក់ពុទ្ធភាសិតនេះថា ជនណាមួយកាលពីពេលមុនមក ជាអ្នកមានសេចក្ដីធ្វេសប្រហែសច្រើនជ្រុល ធ្វើអំពើអាក្រក់ណាមួយ ដោយកាយ វាចា ចិត្ត ដែលអ្នកប្រាជ្ញលោករិះគន់ថាជាអំពើលាមកក្រខ្វក់សៅហ្មងមិនស្អាត លុះកាលជាខាងក្រោយមក ក៏បែរជាភ្ញាក់គំនិតដឹងខ្លួនជាខុស ហើយលះបង់សេចក្ដីធ្វេសប្រហែសច្រើនដែលធ្លាប់តែប្រព្រឹត្តធ្វើអំពើអាក្រក់នោះៗចោលចេញ ហើយប្រព្រឹត្តធ្វើតែអំពើល្អដោយកាយ វាចា ចិត្ត មានឲ្យទានរក្សាសីលជាដើម ជននោះឯងឈ្មោះថាធ្វើខ្លួនឲ្យមានពន្លឺភ្លឺឲ្យបរិសុទ្ធស្អាត ទាំងកេរ្តិ៍ឈ្មោះរបស់ជននោះសោត ក៏ត្រូវផ្សាយទៅកាន់ទិសទីទាំងពួងដោយសេចក្ដីរុងរឿងក្នុងលោកនេះ ប្រៀបដូចជាព្រះចន្ទពេញវង់ដែលលឿនឃ្លាតចេញផុតពីមន្ទិល មានពពកជាដើម ដូច្នោះឯង ។ សេចក្ដីដែលពណ៌នាមកប៉ុណ្ណោះនេះ ដើម្បីបញ្ជាក់ឲ្យឃើញថា ក្រៅអំពីខ្លួនរបស់ខ្លួនឯង អ្នក

ណាទីងអាចធ្វើអ្នកណាឲ្យបរិសុទ្ធឬសៅហ្មងនោះពុំបានឡើយ ។

មានជនពួកខ្លះក្នុងលោកនេះមានសេចក្តីយល់ថា សេចក្តីបរិសុទ្ធិនឹងសេចក្តីមិនបរិសុទ្ធិសម្រេចមកតែអំពីចិត្ត សូម្បីកុសលក្តី អកុសលក្តី ក៏សម្រេចមកអំពីចិត្តដែរ ឬដំណើរទៅកាន់សុគតិក្តី ទៅកាន់ទុគ្គតិក្តី ក៏សម្រេចមកតែអំពីចិត្តដែរ ហេតុនោះយើងមិនចាំបាច់ធ្វើទេ ដូចជាបុណ្យកុសលអ្វីផ្សេង ៗ យើងកុំចាំបាច់ធ្វើ ឬកុំចាំបាច់ហាត់គិតទុកជាមុន នាំឲ្យខាតទ្រព្យឬនាំឲ្យរវល់ខាតវេលាទេ ចាំដល់ពេលណាដែលយើងត្រូវការសេចក្តីល្អគឺបុណ្យ ឬក៏ក្នុងពេលជិតស្លាប់ សឹមយើងតាំងចិត្តឲ្យបរិសុទ្ធស្អាតល្អ ដើម្បីឈោងចាប់យកសុគតិតែម្តង ៗ អ្នកមានគំនិតយល់ដូច្នេះ ប្រហែលជាស្មានថាចិត្តនេះជាធម្មជាតងាយស្រួលអាចប្រដៅហ្វឹកហាត់ពត់តម្រង់ទៅយ៉ាងណា ៗ ក៏បានប្រែប្រួលតាម ៗ យ៉ាងនោះតាមបំណងខ្លួនទេដឹង? ការយល់ដូច្នេះ មិនត្រូវបែប មិនត្រូវទំនង មិនសមហេតុផលសោះឡើយ ។ បើតាមពិតនោះ ធម្មជាតិទាំង ៣ យ៉ាងគឺកាយ វាចា ចិត្តនេះមានលក្ខណៈពិបាកបង្ហាត់ទូន្មានប្រៀនប្រដៅឲ្យបានប្រែប្រួលដោយអាការផ្សេងគ្នាយ៉ាងនេះ ឯកាយដែលអាចធ្វើអ្វីទៅបានគ្រប់យ៉ាង ដូចជាចេះសរសេរអក្សរល្អក្តី ចេះធ្វើគ្រឿងអលង្ការអំពីមាសទឹងប្រាក់សំរាប់តាក់តែងកាយនៃបុរសនិងស្ត្រីឲ្យមានក្បាច់ក្បូរភ្ញីល្វិល្អក្តី ចេះ

គូររូបគំនូរដ៏វិចិត្រល្អក្តី ដូច្នេះជាដើម លុះណាតែបានរៀនបានហាត់ឲ្យស្ទាត់ទុកជាមុន ទើបកាយនោះឯងអាចប្រើការឲ្យសម្រេចប្រយោជន៍ទៅបាន ៗ ចំណែកខាងវាចាគឺសំដីសោតទៀតក៏ប្រហែលគ្នា ដូចជាចេះនិយាយការអ្វីឲ្យគេស្តាប់ ឬក៏ចេះថ្លែងសុន្ទរកថាជាដើម ក្នុងទីប្រជុំជនមិនមានការតាស់ឆ្គងទៅបាន លុះណាតែបានគិតហាត់អានឲ្យស្ទាត់ទុកជាមុនសិនដែរ ទើបវាចានោះឯងជាសំដីពីរោះទាប់ចិត្តដល់អ្នកស្តាប់គួរគេយកតម្រាប់តាម ៗ កាយនិងវាចា ទាំងពីរនេះជាធម្មជាតិមើលឃើញច្បាស់ដោយភ្នែក ស្តាប់ឮច្បាស់ដោយត្រចៀក ម៉េចគង់ពិបាកបង្ហាត់ទូន្មានម្ល៉េះទៅហើយ ចំណង់បើចិត្តជាអតិសុខុមជាតល្អិតក្រៃលែង គ្មានរូបពណ៌សណ្ឋានទ្រង់ទ្រាយអ្វីជាគ្រឿងប្រាកដសោះផង សមនឹងពិបាកទូន្មានយ៉ាងណាទៅទៀត, ហេតុនោះការទូន្មានហាត់ចិត្តឲ្យបានបែបបទបរិសុទ្ធស្អាតនោះ មិនមែនជាការងាយទេក្រជាទីបំផុត ព្រោះចិត្តនោះជាធម្មជាតល្អិតឆ្ងាយហួសវិស័យនឹងប្រដូច មានសន្ទុះលឿនរហ័សក្រៃលែងនឹងរកអ្វីមកប្រៀបឲ្យស្មើពុំបាន ជាធម្មជាតឆាប់ប្រែប្រួល, ឆាប់ញាប់ញ័រ, ឆាប់ឃ្វេងឃ្វាង, ឆាប់ធ្វេធ្វា ម្តងដូច្នេះម្តងដូច្នោះនឹងចាប់ពត់តម្រង់ឲ្យត្រង់ល្អតាមបំណងរបស់ខ្លួនភ្លាម ៗ នោះ បានដោយក្រពេកណាស់, មិនមែនជាការងាយស្រួល ដូចជនខ្លះដែលមានសេចក្តីយល់ច្រឡំដូចបានពោល

មកហើយនោះទេ ។

ម្យ៉ាងទៀត មានជនពួកខ្លះយល់ថា សេចក្ដីបរិសុទ្ធក្នុងជីវិតរបស់មនុស្សម្នាក់ៗដែលកើតឡើងក្នុងលោកនេះ គឺមកអំពីមានជាតិគោត្រត្រកូលពូជពង្សដ៏ខ្ពង់ខ្ពស់ ឬមកអំពីមានទ្រព្យសម្បត្តិច្រើន ទើបឈ្មោះថាជាសេចក្ដីបរិសុទ្ធិស្អាតរបស់មនុស្ស , ការយល់ដូច្នេះទុកជាគំនិតយល់ច្រឡំខុសផ្ទុយគ្នានឹងសេចក្ដីពិត ព្រោះតាមពិតនោះ គឺសេចក្ដីបរិសុទ្ធស្អាតនៅត្រង់កាយ វាចា ចិត្ត ដែលមិនប្រព្រឹត្តទៅអកុសលកម្មណាមួយ ទើបបានទៀតឈ្មោះថាជាសេចក្ដីបរិសុទ្ធស្អាតរបស់មនុស្សក្នុងទីនេះបាន មិនមែនបរិសុទ្ធព្រោះតែមានជាតិគោត្រត្រកូលពូជពង្សដ៏ខ្ពង់ខ្ពស់នោះទេ , មិនមែនបរិសុទ្ធព្រោះតែមានទ្រព្យសម្បត្តិច្រើននោះទេ សមដូចព្រះពុទ្ធភាសិតថា :

កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ

ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា

សត្វទាំងឡាយ រមែងបរិសុទ្ធស្អាតដោយគុណធម៌៥យ៉ាង(១)នេះ គឺ: កម្ម ១ វិជ្ជា ១ ធម៌ ១ សីល ១ ជីវិតដ៏ឧត្តម ១ មិនមែនបរិសុទ្ធដោយសារគោត្រត្រកូលឬដោយសារទ្រព្យសម្បត្តិទេ ។ គុណធម៌ទាំង៥យ៉ាង

១. ធម៌ ៥ យ៉ាងនេះ មានសេចក្ដីអធិប្បាយក្នុងគម្ពីរបរមត្ថមញ្ជូសាដិកាវិសុទ្ធិមគ្គត្រង់សីល-និទ្ទេស ។

នេះ ជាសេចក្តីប្រតិបត្តិដុសខាត់ខាងផ្លូវ កាយ វាចា ចិត្ត របស់សត្វឲ្យ បរិសុទ្ធផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាង មិនមែនបរិសុទ្ធដោយហេតុ ដទៃឡើយ ។ ព្រោះហេតុនោះ ពុទ្ធសាសនិកជនគួរជ្រាបថា បើប្រាថ្នា សេចក្តីបរិសុទ្ធិឲ្យកើតឡើងចំពោះខ្លួន ត្រូវតែខ្លួនយើងប្រតិបត្តិធ្វើបំពេញ កិច្ចផ្ទាល់ដោយខ្លួនយើង ឬសេចក្តីសៅហ្មងកើតឡើងដល់ខ្លួនហើយ ត្រូវ តែខ្លួនយើងលាងជំរះសំអាតផ្ទាល់ដោយខ្លួនយើង នឹងទៅពឹងពាក់អ្នក ដទៃឲ្យគេធ្វើជំនួសខ្លួនពុំបានឡើយ , សេចក្តីនេះប្រៀបដូចជនពីរនាក់ ជនម្នាក់បរិភោគអាហារស្កប់ស្កល់ហើយ ឃើញជនម្នាក់ទៀតមិនទាន់ បរិភោគអាហារសោះ កំពុងមានសេចក្តីស្រេកឃ្លាន ហើយចង់ចែក ឆ្អែតរបស់ខ្លួនឲ្យទៅអ្នកដែលកំពុងឃ្លាននោះបានឆ្អែតដូចខ្លួនផង តើជន ឆ្អែតនោះ អាចបះរំលែកឆ្អែតចែកទៅជនឃ្លាននោះខ្លះផងបានឬទេ ? ។ មួយទៀតៈប្រៀបដូចជនម្នាក់កំពុងអន្ទះអន្ទែង ដោយសេចក្តីស្រេកឃ្លាន បានឃើញជនម្នាក់ចូលមកជិត ហើយចង់ចែកឃ្លានរបស់ខ្លួនឲ្យទៅជន ម្នាក់នោះ ឲ្យគេជួយឃ្លានដូចខ្លួនផង តើជនឃ្លាននោះនឹងអាចបះរំលែក ឃ្លានចែកឲ្យទៅជនឯទៀត ឲ្យគេជួយឃ្លានខ្លះផងបានដែរឬទេ ? ។ តាម ពិតជនទាំងពីរនាក់គឺជនឆ្អែតនឹងជនឃ្លាន នឹងបះរំលែកឆ្អែតនឹងឃ្លានឲ្យ ដល់គ្នានឹងគ្នាទៅវិញទៅមកពុំបានសោះឡើយ មានឧបមាយ៉ាងណា ,

ឯសេចក្ដីបរិសុទ្ធិនិងសេចក្ដីមិនបរិសុទ្ធិនេះ  រមែងកើតឡើងអំពីខ្លួនរបស់ខ្លួនឯង  អ្នកណាមួយមិនអាចបេះរំលែកសេចក្ដីបរិសុទ្ធិនិងសេចក្ដីមិនបរិសុទ្ធិ ឲ្យដល់គ្នានិងគ្នាទៅវិញទៅមកពុំបានសោះឡើយ  ក៏មានឧបមេយ្យដូច្នោះឯង ។

ផលល្អនិងផលអាក្រក់  ដែលលេចចេញមកពីសេចក្ដីបរិសុទ្ធិនិងសេចក្ដីមិនបរិសុទ្ធិនៃកាយ វាចា ចិត្តនោះ អាចបង្ហាញឲ្យឃើញជាក់ស្ដែងក្នុងបច្ចុប្បន្ននេះ ដែលត្រូវទទួលសុខនិងទុក្ខផ្សេង ៗ គ្នានោះ មិនចាំបាច់ទាញគួយាំងមកបង្អួលប្រាប់ក្នុងទីនេះទេ សូមពិចារណាពិនិត្យសង្កេតមើលដោយប្រាជ្ញាដ៏ជ្រាលជ្រៅនៅជុំវិញខ្លួនក៏គង់ឃើញបានដោយមិនលំបាក ។

ហេតុនោះ ពុទ្ធសាសនិកជាអ្នកបង់បានសេចក្ដីសុខនិងសេចក្ដីចំរើនឲ្យកើតមានដល់ខ្លួនគ្រប់វេលានេះ ត្រូវតែតាំងសតិស្មារតីឲ្យយាមល្បាតប្រចាំនៅនឹងទ្វារកាយ វាចាចិត្តជានិច្ច ដើម្បីទប់កាំងអកុសលផ្សេងៗមានអភិជ្ឈានិងទោមនស្សជាដើម កុំឲ្យចូលមកបៀតបៀនបាន, បើពុំដូច្នោះទេ មុខជានឹងត្រូវទទួលទុក្ខទោសគ្រោះថ្នាក់ណាមួយតាមគួរដល់យថាកម្មទាំងក្នុងបច្ចុប្បន្ននិងបរលោក  ព្រោះតែសេចក្ដីមិនបរិសុទ្ធិនៃកាយ វាចា ចិត្តនោះឯងជាហេតុ ។

ពណ៌នាអំពីសេចក្ដីបរិសុទ្ធិ ជាគូនឹងសេចក្ដីមិនបរិសុទ្ធិចប់ដោយសង្ខេប ៗ

អត្ថន័យនេះមានក្នុងគម្ពីរធម្មបទដ្ឋកថា ខុទ្ទកនិកាយ ។

# ព្រះអភិធម្មបិដក

## (គម្ពីរព្រះកថាវត្ថុ)

(តមក)

លោក ប៊ូ-ប៊ូ ប្រែរៀបរៀង

---

បរវាទី– គ្រហស្ថបានសម្រេចព្រះអរហត្តនោះក៏មាន ។

សកវាទី– គ្រហស្ថដែលបានសម្រេចព្រះអរហត្តនោះ ប្រាកដជាមានមកមែនហើយ តើបុគ្គលណាដែលបានសម្រេចព្រះអរហត្តក្នុងភេទជាគ្រហស្ថមិនបានបព្វជ្ជា ?

បរវាទី – ដូចសន្តតិមហាមាត្យ ជាអាមាត្យធំរបស់ព្រះបាទបសេនទិកោសល ។

សកវាទី – សន្តតិមហាមាត្យនោះ ជាមនុស្សសេពសុខមែនឬទេ ?

បរវាទី – មែនហើយ សន្តតិមហាមាត្យជាមនុស្សសេពសុខ ។

សកវាទី – បើដូច្នោះ គ្រហស្ថដែលបានសម្រេចព្រះអរហត្តជាអ្នកសេពសុខមែនឬទេ ?

បរវាទី – ន ហេវំ វត្តព្វេ អ្នកកុំគប្បីនិយាយយ៉ាងនេះ ព្រះអរហត្តមិនដែលសេពសុខទេ សន្តតិមហាមាត្យនោះសេពសុខមែន ប៉ុន្តែ

តាំងពីនៅមិនទាន់បានព្រះអរហត្ត លុះបានព្រះអរហត្តហើយមិនបានសេពសុរាទេ ដែលសេពសុរាក្នុងថ្ងៃនោះ លុះបាត់ខ្ញុំជាស្ត្រីបាត់ក្ស័យជីវិតហើយ ក៏ស្វាងសុរាបាត់ស្រវឹងអស់រលីងទៅ ដូចជាអង្កែងដែលបុគ្គលដុតដោយរងើកភ្លើង មានបុគ្គលយកទឹកមកស្រោច ទឹកនោះក៏មិនអាចនឹងតាំងនៅបាន អ្នកគប្បីចូលចិត្តដូច្នេះចុះ ។

## រឿងសន្តតិមហាអាត្យ

សូមនាំឧទាហរណ៍នៃសន្តតិមហាមាត្យមកសំដែងក្នុងទីនេះ ជាសេចក្តីសង្ខេបថា សន្តតិមហាមាត្យនោះ ជាអាមាត្យធំរបស់ព្រះបាទបសេនទិកោសល ទៅបង្ក្រាបបច្ចន្តជនបទដែលបះបោរឲ្យរាបហើយលើកទ័ពត្រឡប់មកវិញ ។ គ្រានោះ ព្រះបាទបសេនទិកោសលឲ្យសោយរាជ-សម្បត្តិ ៧ ថ្ងៃ ព្រះរាជទានស្រីស្នំម្នាក់ជាស្ត្រីប៉ិនប្រសប់ខាងការច្រៀងនិងរាំណាស់ ដើម្បីនឹងឲ្យបម្រើសន្តតិមហាមាត្យ។ នោះក៏សោយរាជសម្បត្តិសេពសុរាស្រវឹងជាប់គ្រប់តាំង ៧ ថ្ងៃ សេពសុរាស្រវឹងហើយឡើងជិះដំរីបរទៅឯកំពង់ទឹកស្ទឹង កាលកំពុងទៅនោះ បានជួបនឹងសម្តេចព្រះសម្មាសម្ពុទ្ធនៅកណ្តាលមាគ៌ាក៏ថ្វាយបង្គំនមស្ការងក់ក្បាលហើយហួសទៅ ។

ស្មិតំ ការត្វា សម្តេចព្រះបរមសាស្តាទ្រង់ធ្វើព្រះអាការញញឹមព្រះទស្សឲ្យប្រាកដ ។ ព្រះអានន្ទក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន!

ព្រះអង្គទ្រង់ញញឹមឲ្យប្រាកដនោះតើ អាស្រ័យហេតុបច្ច័យអ្វី? ទើបទ្រង់ត្រាស់ថា បស្ស អានន្ទ នែអានន្ទ! អ្នកចូរក្រឡេកមើលទៅសន្តតិ-មហាមាត្យ មានសរីរៈប្រដាប់តាក់តែងហើយមកកាន់សំណាក់តថាគត នឹងបានសម្រេចព្រះអរហត្ត ហេតុតែបានស្តាប់ព្រះធម្មទេសនាមួយគាថា ត្រឹមបួនបទប៉ុណ្ណោះក្នុងថ្ងៃនេះ នឹងហោះទៅក្នុងអាកាសកំពស់ ៧ ជួរត្នោត ហើយនឹងនិព្វានក្នុងថ្ងៃនេះ ។

ជនទាំងឡាយបានឮព្រះពុទ្ធដីកាដូច្នោះ អ្នកដែលជាមិច្ឆាទិដ្ឋិគតថា អ្នកពល់គ្នាចូរមើលកិរិយារបស់ព្រះសមណគោតមចុះ ព្រះអង្គត្រាស់ថា សន្តតិមហាមាត្យនេះស្រវឹងស្រាខ្វាំងផុតស្មារតី មានសរីរៈគ្រឿងតាក់តែងហើយ នឹងមកស្តាប់ព្រះធម្មទេសនា ហើយនឹងបានសម្រេចព្រះអរហត្តដោយគេចយកពស ពួកយើងនឹងចាំផ្ចាញ់ផ្ចាលព្រះសមណគោតមដោយមុសាវាទក្នុងថ្ងៃនេះ ។

សម្មាទិដ្ឋិកា ចំណែកជនទាំងឡាយដែលជាសម្មាទិដ្ឋិគតថា ព្រះពុទ្ធានុភាពនេះជាការអស្ចារ្យខ្លាំងណាស់ ពួកយើងនឹងបានឃើញព្រះពុទ្ធលីលានឹងលីលានៃសន្តតិមហាមាត្យក្នុងថ្ងៃនេះ ។ សម្តេចព្រះជិនស្រីត្រាស់ដូច្នោះហើយ ក៏ស្តេចកិច្ចាចារបួស្រេចយាងត្រឡប់មកព្រះជេតពនមហាវិហារវិញ ។

ចិរសកាលំ តាំធៀត្វា ចំណែកសន្តតិមហាមាត្យលេងរាំរែកក្នុងមហានទីអស់ពេលមួយព្រឹកដល់ថ្ងៃត្រង់ ហើយក៏ទៅងូតទឹកឡើងអង្គុយក្នុងទីស្នាមសេពសុរាយ៉ាងសប្បាយ ។ ចំណែកស្រីនោះក៏តាក់តែងរាងកាយស្រស់បស់ចូលទៅក្នុងស្នាមច្រៀងរាំ សំដែងការច្រៀងរាំបម្រើនូវសន្តតិមហាមាត្យ ស្រាប់តែខ្យល់ឈ្មោះសត្ថកវាតកើតឡើងក្នុងខ្ទួចពុះដួងហឫទ័យរបស់ស្ត្រីនោះឲ្យដាច់ ដ្បិតស្ត្រីនោះច្រៀងរាំអស់ ៧ ថ្ងៃ ទាំងបរិភោគអាហារតិចផង ដើម្បីឲ្យការច្រៀងរាំបានពីរោះស្ដាប់ល្អមើលៗ ស្ត្រីនោះក៏ធ្វើកាលកិរិយា ស្លាប់ទៅបិទមាត់ធ្មេចភ្នែកក្នុងខណៈនោះ ។ សន្តតិមហាមាត្យសួរបុរសទាំងឡាយថា ស្ត្រីនោះដូចម្ដេចទៅ ? ។ បុរសទាំងនោះជំរាបថា ស្ត្រីនោះក្ស័យជីវិតហើយ ។ សន្តតិមហាមាត្យគ្រាន់តែឮគេប្រាប់ថា ស្ត្រីនោះស្លាប់ទៅហើយភ្លាម ដោយចិត្តប្រតិពទ្ធស្នេហាស្រឡាញ់ខាងនោះខ្លាំងពេក ស្រាដែលសន្តតិមហាមាត្យផឹកពេញ ៧ ថ្ងៃមកហើយ ក៏រីងស្ងួតហួតហែងអស់ទៅក្នុងខណៈនោះភ្លាម ។ សន្តតិមហាមាត្យស្វាងលែងស្រវឹងស្រាហើយគិតថា ក្រៅពីព្រះបរមសាស្ដាមួយអង្គចេញ គ្មានអ្នកណាអាចនឹងរំលត់នូវសេចក្ដីសោករបស់អាត្មាអញបានទេ គិតឃើញដូច្នេះហើយ ក៏ទៅកាន់សំណាក់នៃព្រះបរមសាស្ដាក្នុងសាយណ្ហសម័យ លុះដល់ហើយថ្វាយបង្គំនមស្ការរួចអង្គុយ

ក្នុងទីដ៏សមគួរក្រាបទូលថា បពិត្រព្រះមានព្រះភាគ ! ខ្ញុំព្រះអង្គមកគាល់ពេលនេះដោយយល់ឃើញថា ព្រះអង្គអាចរំលត់សេចក្តីសោករបស់ខ្ញុំព្រះអង្គបាន សេចក្តីសោកដែលកើតមានដល់ខ្ញុំព្រះអង្គនោះអាស្រ័យហេតុយ៉ាងនេះ, ទូលពីចិត្តស្រឡាញ់ស្ត្រីនោះសព្វគ្រប់ ព្រះមានព្រះភាគសូមជាទីពឹងរបស់ខ្ញុំព្រះអង្គ ។

សម្តេចព្រះភគវាទ្រង់ត្រាស់ថា អ្នកមកកាន់សំណាក់តថាគតដែលជាអ្នកអាចរំលត់សេចក្តីសោយសោកបរិទេវនាការបាន ពិតណាស់ហើយ ការនឹងកំណាត់អស្សុជលធារដែលអ្នកទួញយំស្តាយព្រោះហេតុតែស្ត្រីភាពនេះក្ស័យជីវិត ស្មើប្រៀបដូចនឹងទឹកក្នុងមហាសមុទ្រទាំងបួន គឺទឹកមហាសមុទ្រទាំងបួននោះ នៅតិចជាងទឹកភ្នែករបស់អ្នកដែលទួញយំសោក-ស្តាយស្ត្រីនោះដែរ ទ្រង់ត្រាស់ដូច្នេះហើយ ទើបទ្រង់សំដែងបទព្រះគាថា ថា:

យំ បុព្វេ តំ វិសោសេហិ បច្ឆា តេ មាហុ កិញ្ចនំ
មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសិ ។

សេចក្តីថា សេចក្តីកង្វល់ណារបស់អ្នកមានក្នុងកាលមុន អ្នកចូរញុំាងសេចក្តីកង្វល់នោះឲ្យរីងស្ងួតហួតហែងទៅចុះ, សេចក្តីកង្វល់ណាមានក្នុងកាលខាងក្រោយ អ្នកចូរញុំាងសេចក្តីកង្វល់នោះឲ្យរីងស្ងួតហួត

ហែងទៅចុះ, សេចក្តីកង្វល់ណាមានក្នុងបច្ចុប្បន្នកាលនេះ បើអ្នកមិនបានប្រកាន់យកទេ អ្នកនឹងទៅជាមនុស្សមានចិត្តដ៏ស្ងប់រម្ងាប់ ឥតករាគាទិកិលេស ។

កាលសន្តតិមហាមាត្យបានស្តាប់ព្រះធម្មទេសនាក្នុងខណៈនោះចប់ហើយ ក៏បានសម្រេចព្រះអរហត្ត ជាអង្គព្រះអរហន្តរាប់ចូលក្នុងខិប្បាភិញ្ញា ។ សន្តតិមហាមាត្យនោះ លុះបានសម្រេចព្រះអរហត្តហើយ ទើបពិចារណាមើលនូវខន្ធប្រវត្តិនៃខ្លួន ក៏ឃើញថាអាយុសង្ខាររបស់ខ្លួនមិនបានតាំងនៅយូរអង្វែងនៅមុខទៀតទេ ទើបក្រាបទូលព្រះបរមគ្រូថា បពិត្រព្រះអង្គ! សូមព្រះអង្គទ្រង់អនុញ្ញាតនូវបរិនិព្វានដល់ខ្ញុំព្រះអង្គ ។ សូមថ្វាយបង្គំលាចូលកាន់ព្រះបរិនិព្វាន ។

ជាធម្មតា អង្គសម្តេចព្រះសុគតទ្រង់ជ្រាបដោយព្រះញាណនូវបុព្វកុសលនៃសន្តតិមហាមាត្យ ប៉ុន្តែនឹងផ្ចាញ់ផ្ចាលពាក្យបរប្បវាទពួកអ្នកមិច្ឆាទិដ្ឋិ ប្រការមួយទៀត ទ្រង់ឃើញថាពួកអ្នកសម្មាទិដ្ឋិបានស្តាប់បុព្វកុសលនៃសន្តតិមហាមាត្យនោះហើយ នឹងកើតមានសេចក្តីខ្វល់ខ្វាយក្នុងការកុសល សម្តេចព្រះបរមទសពលទ្រង់ជ្រាបយ៉ាងនេះហើយ ទទួលជូនជាសន្តតិមហាមាត្យក្រាបទូលថា ខ្ញុំព្រះអង្គនឹងចូលកាន់ព្រះនិព្វាន សម្តេចព្រះអនន្តញាណប្រាប់ថា បើអ្នកនឹងបរិនិព្វាន ក៏ចូរ

មើលការដ៏សមគួរដល់អ្នកចុះ  អ្នកចូរសុំផែនដីនូវបុព្វកុសលដែលអ្នកត្រូវធ្វើ ឲ្យច្បាស់ប្រាកដចំពោះតថាគតមុនទើបវិទិត្វាន  កាលសុំផែនដីនោះ ចូរកុំ សុំផែនដីលើប្រថពី ចូរទៅសុំផែនដីឰដ៏អាកាសវិថីឲ្យបានកំពស់ ៧ ជួរត្នោតៗ

សន្តតិមហាមាត្យទទួលព្រះពុទ្ធដីកា សាធុ ១ រួចហើយ ក៏ ថ្វាយបង្គំនមស្ការ ហោះឡើងទៅឰដ៏អាកាសបានកំពស់មួយជួរត្នោត ហើយត្រឡប់ចុះមកថ្វាយបង្គំម្តង ហោះទៅទៀតបានកំពស់ពីរជួរត្នោត ត្រឡប់ចុះមកថ្វាយបង្គំម្តង ហើយហោះឡើងទៅឯអាកាសទៀត ធ្វើតាម ទំនងនេះរហូតដល់ ៧ ជួរត្នោត ចុះមកក្រាបថ្វាយបង្គំគ្រប់ ៧ ដង ស្រេច ហើយក៏អង្គុយឰដ៏អាកាសវិថី លើកអញ្ជលីប្រណម្យក្រាបទូលសុំផែង នូវបុព្វកុសលគឺកុសលដែលខ្លួនបានកសាងពីកាលមុនកពមុនថា:

វិបស្សីសម្មាសម្ពុទ្ធកាលេ ក្នុងកាលដ៏ជាព្រះបវរពុទ្ធសាសនានៃព្រះសម្ពុទ្ធទ្រង់ព្រះនាម វិបស្សី ខ្ញុំព្រះអង្គកើតក្នុងព្រះនគរពន្ធុមតី-គិតនឹងធ្វើកុសលពសីដែលមិនបានបៀតបៀនខ្លួននឹងបុគ្គលដទៃ ក៏យល់ ឃើញថា ការប៉ាវគងទូងកេរ៍ប្រកាសប្រាប់គេឲ្យធ្វើកងការកុសលនោះឯង មិនបានបៀតបៀនខ្លួននឹងអ្នកដទៃ លុះគិតឃើញយ៉ាងនេះហើយ ក៏ដើរ ឃោសនាបបួលឲ្យអ្នកនគរធ្វើការកុសលបំពេញទាន, ស្ដាប់ព្រះសទ្ធម្មទេសនា, រក្សាព្រះត្រៃសរណគមន៍នឹងសីល ។

គ្រានោះ ព្រះបាទពន្ធុមតីជាព្រះពុទ្ធបិតានៃព្រះវិបស្សីបរមទសពលត្រាស់ហៅឲ្យចូលគាល់ហើយទ្រង់សួរថា អ្នកឯងធ្វើការអ្វី បានជាចេះតែដើរទៅដើរមកតាមមុខព្រះលាន ។ ខ្ញុំព្រះអង្គក្រាបទូលថា ខ្ញុំដើរប្រកាសឃោសនាឲ្យអ្នកនគរធ្វើបុណ្យកុសល ។ ព្រះបាទពន្ធុមតីទ្រង់ព្រះរាជទាននូវកែវមុក្តាហារសម្រាប់ប្រដាប់តាក់តែងខ្លួនមួយគូ គ្រាមួយទៀត ទ្រង់ព្រះរាជទានអស្សរាជសម្រាប់ជិះ ក្រោយមកទៀត ព្រះរាជទានរាជរថទឹមដោយសេះសិន្ធពបួន ក្រោយមកទៀត ព្រះរាជទានគ្រឿងឧប-ភោគនិងបរិភោគជាច្រើន និងគ្រឿងប្រដាប់សម្រាប់អ្នកធំ ហើយព្រះរាជទានគជសារសមួយសម្រាប់ជិះទៅប្រកាសកិច្ចការកុសល ខ្ញុំព្រះអង្គតាក់តែងខ្លួនប្រណាបានស្អាតបាតល្អ ឡើងជិះដំរីចរទៅប្រកាសឃោសនាឲ្យអ្នកផងធ្វើកិច្ចការកុសលតាំងពីប្រមាណប្រាំបីម៉ឺនឆ្នាំ ក្លិនកាយនៃខ្ញុំព្រះអង្គក្រអូបឈ្ងុយឈ្ងប់ ប្រៀបដូចក្លិនខ្លឹមចន្ទន៍, ក្លិនកេសរនៃផ្កាឧប្បលធុំក្រអូបឈ្ងុយចេញពីមាត់នៃខ្ញុំព្រះអង្គ ដោយកិច្ចការកុសល គឺដើរប្រកាសឃោសនាឲ្យមហាជនធ្វើបុណ្យ តាំងពីក្មេងរហូតដល់ចាស់ជក ក្ស័យជីវិត នេះជាបុព្វកុសលនៃខ្ញុំព្រះអង្គ ។

សន្តតិមហាមាត្យក្រាបទូលព្រះពុទ្ធអង្គ អំពីបុព្វកុសលរបស់ខ្លួនចប់ហើយ ក៏ចូលតេជោកសិណសមាបត្តិហើយរលត់ខន្ធចូលកាន់ព្រះនិព្វាន

នៅវេលានោះឯង ។

អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា - សន្តតិមហាមាត្យនេះ បានសម្រេចព្រះអរហត្តក្នុងភេទជាគ្រហស្ថ ចាត់ចូលក្នុងគីហិអរហាកថាដូចវិសជ្ជនាមកហើយនេះ ។

រឿងសន្តតិមហាមាត្យ ចប់តែប៉ុណ្ណេះ ។

## រឿងពាហិយបុរស

ទារុចិរិកោ ពាហិយោ ច គីហិ សមានោ អរហត្តំ បត្តោតិ ។ សោ ច ទារុចិរិកោ អហិរិកោ អត្តានំ លោកសទ្ធហាបេត្វា លោកំ វញ្ចេសីតិ អាមន្តា តេន វត្ថេ វត្ថេ អរហា ហិរិកោតិ វត្ថញ្ញាតិ ។

វាក្យនេះ មិនបានវិសជ្ជនាក្នុងគីហិអរហាកថាតទៅ ដំណើរសេចក្តីថា គីហិ សមានោ បុគ្គលជាគ្រហស្ថបានសម្រេចអរហត្តនោះមានគតិ ដូចបានឮមក ឯកស្មឹ សមយេ សម័យមួយ ជនជាច្រើននាំគ្នាជិះសំពៅបើកទៅក្នុងមហាសមុទ្រ ដើម្បីទៅធ្វើពាណិជ្ជកម្មការលក់ដូរ បើកសំពៅទៅបានច្រើនទិវារាត្រី សំពៅនោះបែកធ្លាយលិចលង់កណ្តាលមហាសាគរ ។

(នៅមានត)

# មធុរសវាហិណី

សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

ចាប់ដើមតាំងតែអំពីកាលនោះមក ព្រះបាទមន្ធាតុព្រះបរមចក្រ ព្រះអង្គបានសោយរាជសម្បត្តិជាសុខក្សេមក្សាន្ត ឥតមានសេចក្ដីរង្កៀសឡើយ ។

លុះដល់កាលកន្លងទៅយូរអង្វែងយ៉ាងនេះហើយ, សក្កទេវរាជនោះបានសោយសម្បត្តិទិព្វពាក់កណ្ដាល កំណត់អាយុបានបីកោដិឆ្នាំមួយលានឆ្នាំមនុស្សក៏ច្យុតទៅ មានព្រះឥន្ទ្រាធិរាជដទៃឡើងទៅកើតក្នុងឋានតាវតឹសទេវលោកនោះទៀត ព្រះឥន្ទ្រាធិរាជនោះបានសោយរាជសម្បត្តិទិព្វក្នុងឋានតាវតឹសទេវលោកនោះឯង ដល់កំណត់អស់អាយុក៏ច្យុតចុះមកទៀត ដរាបដល់ព្រះឥន្ទ្រាទាំងឡាយ ៣៦ ព្រះអង្គតែងឡើងទៅកើត កំណត់អស់អាយុ ហើយច្យុតដោយហេតុដូចបានអធិប្បាយមកខាងដើមនេះឯង ។

ចំណែកឯព្រះបាទមន្ធាតុព្រះបរមចក្រ បានសោយរាជសម្បត្តិជាស្ដេចនៃទេវតា កំណត់អាយុព្រះឥន្ទ្រាធិរាជ ៣៦ ដំណ ដោយរាង

កាយជាមនុស្សយ៉ាងនេះហើយ កំព្រះអង្គមានកាមតណ្ហាសេចក្តីប្រាថ្នាក្នុងកាមគុណមិនចេះពេញ ចេះតែខ្វះជានិច្ច រឹងរឹតតែមានកាមតណ្ហាចំរើនកើតធំក្រៃលែងឡើងទៀត, ហើយទ្រង់ព្រះចិន្តាពិចារណាថា រាជសម្បត្តិទិព្យពាក់កណ្តាលនេះ មិនជាប្រយោជន៍អ្វីដល់អញឡើយ ៗ ត្រូវតែអញសម្លាប់ព្រះឥន្ទ្រាធិរាជនេះចោល ហើយសោយរាជសម្បត្តិក្នុងឋានតាវត្តឹង្សទេវលោកនេះតែម្នាក់ឯង ទើបល្មមនឹងបុណ្យអញដោយពិត ៗ ព្រះបាទមន្ធាតុព្រះបរមចក្រទ្រង់គិតដូច្នេះហើយ ក៏ពុំអាចនឹងសម្លាប់នូវសក្កទេវរាជនោះបានឡើយ ៗ ឯកាមតណ្ហាដែលកើតឡើងយ៉ាងនេះគ្រាន់តែជាឫសគល់ នៃសេចក្តីវិបត្តិ ខូចខាតប្រយោជន៍ខ្លួនតែម្យ៉ាង ៗ សេចក្តីពិតដូច្នេះ បានជាព្រះអរហន្តទាំងឡាយលោកពោលជាបទគាថាទាំងឡាយថា :

វរមតិសុខទុក្ខកា អតិច្ចាវិហារោ ឯកោ
ឥជ ភ បរិន្ទភ តាតិញ្ញា ឯ សា តំ វុឌ្ឍតោ សទា ។

សេចក្តីសុខដ៏ប្រសើរក្រៃលែង ទើបអាចធ្វើឲ្យផុតចាកកងទុក្ខទាំងពួងបាន ឯនរជនតែបណ្តែតបណ្តោយឲ្យសេចក្តីឥច្ឆាប្រាថ្នាលោភច្រើនដ៏ក្រៃលែងគ្របសង្កត់ខ្លួនបានហើយ សេចក្តីឥច្ឆាប្រាថ្នាដ៏ក្រៃលែងនោះពុំបានញ៉ាំងនរជននោះ ឲ្យបាននូវសេចក្តីសុខដ៏ប្រសើរនោះតិចតួច ក្នុងលោកនេះ ឬលោកខាងមុខ ក្នុងកាលទាំងពួងឡើយ ៗ

តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ
តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ

សេចក្តីសោកស្រណោះអាឡោះអាល័យក្តៅក្រហាយដែលនឹងកើតឡើង ក៏កើតមកតែពីសេចក្តីប្រាថ្នាក្នុងកាមគុណពិត សេចក្តីភ័យអន្តរាយក៏កើតតែពីសេចក្តីប្រាថ្នាក្នុងកាមគុណពិត កាលបើបុគ្គលមានចិត្តរួចស្រឡះចេញចាកតណ្ហាហើយ សេចក្តីសោកក្តៅក្រហាយ នឹងភយន្តរាយកើតមានមកពីទីណា ។

តណ្ហាទាសោ នរោ ឯត្ថ ភជតោភិសម្ភវំ
ហត្ថច្ឆេទាទិកំ ទុក្ខំ បាបុណាតិ វិហញ្ញតិ ។

នរជនដែលលុះអំណាចនៃតណ្ហាជាខ្ញុំបំរើតណ្ហាហើយ តែងលំបាកដល់នូវសេចក្តីទុក្ខជាទម្ងន់មានត្រូវពោសកាត់ដៃជើងជាដើម កើតឡើងព្រមអំពីសត្រូវមានស្តេចវៃជាន់នឹងចោរលួចប្លន់ជាដើមក្នុងលោកនេះ ។

យេន លោភេន ជាតេន លទ្ធា ជិយន្តិ បាណិនោ
ខេត្តវត្ថុហិរញ្ញំ វា គវស្សទាសបោរិសំ
សព្វថាមេន សោ លោភោ បហាតព្វោ ច វិញ្ញុនា ។

សត្វទាំងឡាយដែលបានស្រែចំការនឹងមាសប្រាក់ច្រើនក្តី បានគោសេះនឹងបុរសជាខ្ញុំបំរើច្រើនក្តី ហើយទំនងនឹងវិនាសទៅវិញដោយសេចក្តី

លោភតណ្ហាឯណា ដែលកើតឡើង ហើយសេចក្ដីលោភតណ្ហានោះគឺអ្នកប្រាជ្ញដែលចេះដឹងពិត ត្រូវប្រព្រឹត្តលះបង់ចោលចេញឲ្យដាច់ ដោយកម្លាំងនៃញាណ ដែលមានកម្លាំងដោយប្រការទាំងពួងពិត ។

ឯអាយុសង្ខារនៃព្រះបរមពោធិសត្វ ដែលមានសេចក្ដីឥច្ឆាប្រាថ្នាច្រើនក្រៃពេក គ្របសង្កត់ចិត្តហើយ ក៏សាបសូន្យថយចុះទៅក្នុងកាលនោះឯង សេចក្ដីចាស់ជរាក៏ប្រហារនូវសរីរៈឲ្យទ្រុឌទ្រោមគ្រាំគ្រាទៅមួយរំពេច ឯសរីរៈរបស់មនុស្សក៏ប្រាកដឡើង ពុំបានលាយច្រឡំដោយសរីរៈនៃទេវតាក្នុងឋានទេវលោកឡើយ ។

គ្រាកាលនោះ ព្រះបាទមន្ធាតុព្រះបរមចក្រពត្រាធិរាជ ទ្រង់របូតធ្លាក់ចុះមកចាកឋានទេវលោក បានមកឋិតនៅក្នុងព្រៃឧទ្យានរបស់ព្រះអង្គដូចកាលមុនវិញ ។

ឯបុរសដែលជាអ្នករក្សានូវឧទ្យាន បានដឹងហើយ ក៏នាំយកសេចក្ដីដែលព្រះបាទមន្ធាតុព្រះបរមចក្រនោះ ស្ដេចត្រឡប់មកពីស្ថានសួគ៌វិញហើយ ចូលទៅក្រាបទូលក្នុងរាជត្រកូលទាំងអស់ ឲ្យបានជ្រាបសព្វគ្រប់ក្នុងវេលានោះឯង ។ ឯស្ដេចដែលជាធំក្នុងរាជត្រកូល ក៏បានចេញមកអំពីរាជត្រកូលហើយ ចាត់ចែងសេវកាមាត្យទាំងឡាយឲ្យក្រាលរាជាសនៈដ៏ប្រសើរក្នុងសួនឧទ្យាននោះ ។

លំដាប់នោះ ព្រះបាទមន្ធាតុព្រះបរមចក្រព្រះអង្គក៏ឡើងផ្ទំលើកជាសនៈដ៏ប្រសើរ ដែលសេវកាមាត្យក្រាលថ្វាយហើយ ព្រះអង្គផ្ទំស្រេចជាអនុដ្ឋានសេយ្យាគឺផ្ទំពុំបានក្រោកឡើងវិញឡើយ ៗ វេលានោះ អាមាត្យទាំងឡាយក៏បានចូលមកជួបជុំ ហើយថ្វាយបង្គំក្រាបទូលសួរថា ៖ បពិត្រព្រះសម្មតិទេព! ពីកាលមុនរៀងមកយើងទាំងឡាយត្រូវពោលដូចម្តេចខ្លះ ? ឯព្រះបាទមន្ធាតុព្រះបរមចក្រ ព្រះអង្គទ្រង់ព្រះសណ្តាប់ហើយក៏ត្រាស់ថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ! អ្នកត្រូវសម្តែងប្រាប់ពាក្យបណ្តាំរបស់អញពីកាលមុនរៀងមកថា ព្រះបាទមន្ធាតុជាស្តេចធំដ៏ប្រសើរ ព្រះអង្គបានសោយរាជសម្បត្តិជាស្តេចចក្រពត្តិក្នុងទ្វីបធំទាំងបួន មានទ្វីបតូចពីរពាន់ជាបរិវារ ជាអស្ចារ្យពន់ពេកណាស់ មិនតែប៉ុណ្ណោះ ព្រះអង្គបានឡើងទៅសោយសម្បត្តិទិព្វ ក្នុងឋានចាតុមហារាជិកាកំណត់បានប្រាំបីម៉ឺនបួនពាន់ឆ្នាំមនុស្ស ហើយស្តេចបានឡើងទៅសោយរាជសម្បត្តិទិព្វ ក្នុងឋានតាវត្តិង្សទេវលោក អស់កាលជាអមុងយូរពន់ពេក ដោយកំណត់នៃអាយុព្រះឥន្ទទាំងឡាយ ៣៦ ក ទើបព្រះអង្គបានធ្វើមរណកាលក្សិណក្ស័យព្រះជន្មទៅ ៗ

ឯព្រះបាទមន្ធាតុព្រះបរមពោធិសត្វនោះ ព្រះអង្គមានព្រះបន្ទូលតែប៉ុណ្ណោះហើយ ក៏ទ្រង់សោយព្រះទិវង្គតទៅ ហើយបានទៅកើតក្នុង

បានសួគ៌សោយសម្បត្តិទិព្វ ដោយសមគួរតាមបុញ្ញកម្មរបស់ព្រះអង្គហោង ។

បពិត្រអើយ ! អង្គសម្តេចព្រះលោកុត្តមាចារ្យជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់សម្តែងរឿងនេះចប់ស្រេចហើយ ក៏ពោលជាបទព្រះគាថាទាំងឡាយថា ៖

យាវតា ចន្ទិមសុរិយា ទិសា ភន្តិ វិរោចមានា
សព្វេវ ទាសា មន្ធាតុស្ស យេ ច បាណា បថវិស្សិតា ។

សេចក្តីថា ព្រះអាទិត្យនិងព្រះចន្ទទាំងឡាយ ដែលភ្លឺស្វាងរុងរឿង ញុំាងទិសទាំង ៤ ឲ្យភ្លឺច្បាស់ ផ្សាយទៅក្នុងទីមានប្រមាណត្រឹមណា សត្វទាំងឡាយណា ដែលនៅអាស្រ័យនឹងផែនដី ក្នុងទីមានប្រមាណប៉ុណ្ណោះ សត្វទាំងនោះសុទ្ធតែជាទាសីទាសាជាខ្ញុំបំរើព្រះបាទមន្ធាតុព្រះបរមចក្រទាំងអស់ ដោយពិត ។

ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ
អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ ។

បណ្ឌិតជាតិជាអ្នកប្រាជ្ញអាចមានបញ្ញា ត្រូវពិចារណាឲ្យដឹងដូច្នេះថា សេចក្តីឆ្អែតពេញប្រាថ្នាក្នុងកាមគុណទាំងឡាយ ដោយអំណាចតែកហាបណៈមានប្រមាណច្រើនក៏ពុំមានឡើយ កាមគុណទាំងឡាយរមែងនាំមក

នូវសេចក្តីទុក្ខលំបាក មានសេចក្តីជ្រះថ្លាតិចស្តួចស្តើងណាស់ ៗ

អបិ ទិព្វេសុ កាមេសុ រតឹ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។

ចំណែកឯព្រះបាទមន្ធាតុព្រះបរមចក្រ នោះព្រះអង្គពុំបានសម្រេចនូវសេចក្តីដំរេកត្រេកអរក្នុងកាមគុណដ៏ជាទិព្វឡើយ ៗ ព្រោះហេតុដូចនោះ បានជាសម្មាសម្ពុទ្ធសាវក លោកមានតែដំរេកត្រេកអរក្នុងកិច្ចដែលអស់សូន្យទៅនៃតណ្ហា ដោយចំណែកមួយដោយពិត ៗ

មហាជនទាំងឡាយ បានស្តាប់នូវព្រះគាថានោះហើយក៏បានសំរេចនូវមគ្គនិងផលមានសោតាបត្តិមគ្គជាដើម ក្នុងកាលនោះឯង ៗ

ព្រោះហេតុដូច្នេះ បានជាព្រះអរហន្តទាំងឡាយលោកសំដែងបទគាថាដូច្នេះថា៖

ឥតិ និយតគតីនំ ពោធិយា និមត្តានំ
សកាវសមុបនេត្វា នេតិ ទុក្ខានិ តណ្ហា
អនិយតគតិកានំ កា កថា មាទិសានំ
បជហថ ឥតិ មន្ត្វា ភោ ភវេ តន្តិ រត្តុំ ៗ

សេចក្តីថា តណ្ហាអាចប្រមូលដឹកនាំមហាបុរសទាំងឡាយដែលមានព្យាយាមមាំក្នុងពោធិញ្ញាណ មានគតិទៀងទាត់នេះឲ្យចូលទៅនិគ

គាត់អំណាចរបស់ខ្លួនបាន ហើយប្រគល់ឲ្យនូវសេចក្តីទុក្ខលំបាកឥតគណនាយ៉ាងដូច្នេះ, ទំបាច់និយាយទៅថ្វីដល់បុគ្គលប្រាកដស្មើដោយយើងទាំងឡាយ ដែលប្រកបដោយគតិមិនទៀងយ៉ាងនេះ ម្នាលអ្នកទាំងឡាយដ៏ចំរើន ! បើអ្នកបានពិចារណាដឹងច្បាស់យ៉ាងនេះហើយ, ត្រូវតែលះបង់ពាលនូវតណ្ហានោះ ដែលជាវត្ថុជាគ្រឿងត្រេកអរក្នុងភពឲ្យស្រឡះចេញ ទើបបានសេចក្តីសុខក្សេមក្សាន្តពិតហោង ។

សំដែងរឿងព្រះមហាមន្ធាតុបរមចក្រជាគំរប់ ៨ ក្នុងវគ្គទីមួយ ក៏ចប់សេចក្តីដោយសង្ខេបតែប៉ុណ្ណេះឯង ។

## ៩ ពុទ្ធវម្មវាណិជវត្ថុកថា

សំដែងរឿងនិទានវាណិជឈ្មោះ ពុទ្ធវម្ម: តទៅទៀត ដោយបទបាលីថា ជម្ពុទីបេ កិរ បាតលិបុត្តនគរេ ដូច្នេះជាដើម. អធិប្បាយជាសេចក្តីថា កិរ បានឮរឿងៗមកថា: មានឈ្មួញម្នាក់ ឈ្មោះពុទ្ធវម្មពាណិជ តែងរកស៊ីចិញ្ចឹមជីវិតដោយវណិជ្ជកម្មការជំនួញដើរទេះ គាត់នៅអាស្រ័យក្នុងនគរបាតលិបុត្តក្នុងជម្ពូទ្វីប ។

លុះដល់ចំណេរមកជាខាងក្រោយ ពុទ្ធវម្មពាណិជនោះបានប្រកបនូវការជំនួញក្នុងប្រទេសទាំងឡាយ មានខណ្ឌជនបទនិងកជងគលាទីជាដើម ក៏យកទំនិញដាក់ក្នុងរទេះ ហើយបរចេញទៅអំពីក្រុងបាតលិបុត្តជាមួយនឹង

នាយឈ្មួញរទេះជាច្រើន ដើម្បីនឹងចេញទៅជួញក្នុងប្រទេសផ្សេងៗ

សម័យនោះ ព្រះមានព្រះភាគព្រះអង្គបាននាំព្រះភិក្ខុសង្ឃច្រើនជាងពាន់អង្គហែមរោមជាបរិវារត្រាច់ទៅកាន់ចារិកនៃជនបទ ហើយ ព្រះអង្គបានសំដែងធម៌ទេសនាប្រោសមនុស្សនិងទេវតា ឲ្យបានទទួលអម្រិតសេឲ្យបានឆ្លងផុតចាកផ្លូវឆ្ងាយគឺសង្សារវដ្តចាកទុក្ខទាំងពួង ។

កាលនោះ ពុទ្ធវម្មពាណិជ បានជួបប្រទះនឹងព្រះមានព្រះភាគដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ ទាំងប្រដាប់ដោយអនុព្យញ្ជនៈប៉ែតសិបគត់ ដ៏ភ្លឺស្វាងរុងរឿងប៉ីដូចរូបមាសដែលមានព្រះភិក្ខុសង្ឃច្រើនហែមរោមជាបរិវារត្រាច់ទៅតាមផ្លូវនោះដែរ លុះបានឃើញហើយក៏មានបីតិពាល់ត្រូវសព្វសពាង្គកាយ ហើយដើរចូលទៅកាន់សំណាក់ព្រះមានព្រះភាគលើកអញ្ជលីថ្វាយបង្គំដោយគោរព ព្រមទាំងបានស្តាប់ធម៌ទេសនាផង ក៏រឹងរឹតតែមានសេចក្តីជ្រះថ្លាខ្លាំងឡើងទៀត លុះចប់ធម៌ទេសនាហើយក៏បាននិមន្តព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃឲ្យទទួលបង្ហាន់ក្នុងសាយណ្ហសម័យថ្ងៃសៀលនោះឯង ព្រោះខ្លួនទើបតែបានជួបនឹងព្រះពុទ្ធជាដំបូង ពុំទាន់បេះដឹងកិច្ចក្នុងព្រះពុទ្ធសាសនានៅឡើយ ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលពាណិជ ! តថាគតទាំងឡាយពីមុនរៀងៗមក ព្រះអង្គតែងវៀរវេលាវិកាលភោជន ពុំ

ដែលបរិភោគបាយវេលាថ្ងៃរសៀលឡើយ ។

ចំណែកឯពុទ្ធមាមកកេណិយនោះ លុះបានស្តាប់ព្រះពុទ្ធដីកាដូច្នោះហើយ ក៏ក្រាបបង្គំទូលសួរថា បពិត្រព្រះមានព្រះភាគដ៏ចំរើន ! ព្រះមានព្រះភាគទាំងឡាយ ព្រះអង្គនឹងសោយតែអ្វីខ្លះ ទើបគួរក្នុងវេលាថ្ងៃល្ងាចអម្ចាស់ ? ។

កាលនោះ ព្រះមានព្រះភាគព្រះអង្គបានអនុញ្ញាតទឹកបានៈទាំង ៨ យ៉ាងចំពោះនឹងពុទ្ធមាមកកេណិយនោះថា ម្នាលកេណិយ? ក្នុងវេលាវិកាល ព្រះតថាគតគួរឆាន់បានចំពោះតែទឹកទាំង ៨ យ៉ាង ឯទឹកទាំង ៨ យ៉ាងនោះគឺ អម្ពបានំ ទឹកស្វាយទុំឬស្វាយខ្ចីមួយ ជម្ពុបានំ ទឹកផ្លែព្រីងមួយ ចោចបានំ ទឹកផ្លែចេកមានគ្រាប់មួយ, មោចបានំ ទឹកផ្លែចេកឥតគ្រាប់មួយ, ឧច្ឆុបានំ ទឹកអំពៅមួយ, ផារុសកបានំ ទឹកផ្លែមាក់ប្រាងមួយ, មធុ-កបានំ ទឹកផ្លែស្រគំមួយ, មុទ្ទិកបានំ ទឹកផ្លែចន្ទូមួយ, ត្រូវជាទឹក ៨ យ៉ាង ទឹកទាំងនេះគួរដល់សមណៈនិងព្រាហ្មណ៍ឆាន់ក្នុងវេលាវិកាលបានដោយពិត ។

ឯកេណិយបានស្តាប់ហើយ ក៏មានចិត្តជ្រះថ្លាចាត់ចែងយកផ្លែចន្ទូទុំមកច្របាច់លាយនឹងទឹក ហើយត្រងឲ្យស្អាតផ្សំលាយដោយរសទាំងឡាយមានរសស្ករជាដើម, ស្រេចហើយយកទៅប្រគេនព្រះភិក្ខុសង្ឃមាន

ព្រះសម្មាសម្ពុទ្ធជាប្រធានក្នុងកាលនោះឯង ។

លុះព្រះបរមសាស្ដាចារ្យព្រមទាំងព្រះភិក្ខុសង្ឃបានទទួលទឹកមុទ្ទិកបានៈឆាន់ស្រេចហើយ ក៏ព្រះអង្គទ្រង់សំដែងធម៌ទេសនាដល់ពុទ្ធវម្មពាណិជនោះ លុះព្រះអង្គសំដែងព្រះធម៌ចប់ហើយ ក៏នាំភិក្ខុសង្ឃចេញទៅកាន់ចារិកនៃជនបទក្នុងកាលនោះឯង ។

ចំណែកឯពាណិជវិញក៏មានចិត្តជ្រះថ្លាក្នុងការថ្វាយបានៈនោះពុំមានក្លេបបានទឹមរទេះបរចេញទៅ ប្រកបការជំនួញក្នុងស្រុកជនបទនានា ជាមួយនឹងឈ្មួញរទេះទាំងឡាយ លុះបានបរទៅដល់ផ្លូវឆ្ងាយធំធេងមានសុទ្ធតែដីខ្សាច់ ឥតមានទឹកក្នុងព្រៃធំឡើយ ។

ឯទឹកសម្រាប់ផឹកក្នុងរទេះទាំងឡាយ របស់ពាណិជនោះក៏អស់ទៅពុំមានសេសសល់តិចតួច ទាំងទឹកសម្រាប់មនុស្សក្ដី សម្រាប់ពាហនៈក្ដី ក៏ពុំមានសេសសល់ក្នុងវេលានោះឯង ។

ឯពុទ្ធវម្មពាណិជនោះសោត កាលបើដាច់ទឹកសោះដូច្នោះហើយ ក៏ស្រេកទឹកជាខ្លាំង អត់ទ្រាំពុំបាន ទើបដើរស្វែងរកទឹកក្នុងរទេះទាំងឡាយនោះ សូម្បីត្រាច់ទៅត្រាច់មកតាមលំដាប់រទេះនោះ ក៏ពុំបានទឹកផឹកដល់តិចឡើយ : ។

(នៅមានត)

# មហោសធជាតក

(តមក)

លោក អ៊ឹម.កន ចម្លងពីសាស្ត្រស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-ទូរ ពិនិត្យ

---

ឯអ្នកទាំង ២ នោះមិញ កាន់កន្ទៀររទេះទៅ, បុរសម្ចាស់រទេះគេ បានបន្តិចហើយ លែងរទេះឈប់នៅហោង ។ ព្រះឥន្ទ្រមិញ គេ ទៅជិតមួយរំពេច មួយអន្ទើនឹងរទេះនោះហោង សូម្បីញើសមួយតំ-ណក់ ក៏ពុំចេញអំពីសរីរកាយឡើយ, ហើយពុំហត់ដង្ហើមចេញចូល ឡើយ ហើយមិនខ្លាច ភ្នែកពុំប៉ប្រិច, បុរសនេះឈ្មោះព្រះឥន្ទ្រាធិរាជ ជាស្តេចទេវតាហោង ។ បុរសបររទេះដណ្តឹងថា អ្នកជាព្រះឥន្ទ្រពិត ហ៎ះ ? ព្រះឥន្ទ្រថា អើអញជាព្រះឥន្ទ្រពិត ។ កាលបើពាក្យព្រះឥន្ទ្រ ថាដូច្នោះហើយ, មហាសត្វដណ្តឹងថា ចុះអ្នកមកធ្វើអំពើដូច្នេះ, ព្រះឥន្ទ្រថា ហៃចៅអ្នកប្រាជ្ញអើយ អញមកនេះប្រយោជន៍នឹងសំដែង ល្បងប្រាជ្ញានៃអ្នក ឲ្យយល់ជាក់ច្បាស់ប្រាកដហោង ។ ព្រះមហាសត្វ ថា អំពីនេះទៅ កុំបីអ្នកធ្វើអំពើដូច្នេះទៀតឡើយ ។ ព្រះឥន្ទ្រាធិរាជ

សំដែងអានុភាពអាត្មាជាព្រះឥន្ទ្រស្រេចហើយ អ្នកទៅឋិតនៅកណ្តាលអាកាស ដ៏មានពណ៌ពន្លឺរស្មីដូចព្រះអាទិត្យពេញកំលោះ ឆ្លោះសរសើរប្រាជ្ញានៃព្រះមហោសថអ្នកប្រាជ្ញថា ហៃចៅមហោសថអ្នកប្រាជ្ញប្រសើរអើយ, រីអាថ៌សេចក្តីប្រាជ្ញាចៅពិចារណានេះ គាប់ប្រពៃដោយនូវសុចរិតធម៌ពេកហោង ៗ ព្រះឥន្ទ្រាធិរាជសរសើរព្រះមហោសថស្រេចហើយអ្នកក៏ហោះទៅកាន់ឋានអាត្មាវិញហោង ៗ ក្នុងកាលនោះ រីអាមាត្យដែលចាំនៅនោះមិញ ខ្ញុំឯងមើលឃើញដូច្នោះ ក៏ចូលទៅថ្វាយបង្គំព្រះបាទវិទេហរាជហើយទូលថា បពិត្រមហារាជអើយ រីសេចក្តីដែលចៅអ្នកប្រាជ្ញបង្អាប់ជាក្តាត់ហោង សូម្បីព្រះឥន្ទ្រឯងក្តី ក៏គន់ពាញ់ប្រាជ្ញានៃចៅអ្នកប្រាជ្ញដែរ ហេតុអ្វីក៏ព្រះបាទអម្ចាស់មិនទ្រង់ជ្រាបថា ចៅអ្នកប្រាជ្ញជាមហាបុរសរតនវិសេស ស្តេចស្តាប់ជាក់ហើយមានបន្ទូលដណ្តឹងអាចារ្យសេនកថា ម្នាលអាចារ្យសេនកអើយ យើងនឹងឲ្យទៅនាំចៅអ្នកប្រាជ្ញនោះមកឬម្តេច? រីអាចារ្យសេនកហេតុតែជាអ្នកកំណាញ់លាភសក្ការៈនោះមិញក៏ទូលតាស់ថាបពិត្រអើយ នាប៉ីហៅថាអ្នកប្រាជ្ញ នៅប្រមាណមានចំណេះតែអម្បាលនេះក៏ហៅចំណេះតិចក្តាត់ណាមហារាជ! ពុំទាន់ជាអ្នកប្រាជ្ញទៀយ សូមអម្ចាស់ឈប់ស្ទុះសិន ហើយយើងល្បងប្រាជ្ញឲ្យអស់ចិត្តគំនិតហោង ៗ

រីព្រះបាទវិទេហរាជ ស្តេចស្តាប់ហើយគង់ស្ងៀមវិញហោង ។

សត្តធារគាបញ្ហា និដ្ឋិតា រីយើងបានស្រង់ពីប្រស្នាក្មេងអាយុ ៧ ឆ្នាំមិញ ក៏ស្រេចទៅប្រការអម្បាលនេះហោង ។

ទណ្ឌាតិ រីការល្បងកំណាត់ឈើគគីរនោះមិញ មានដូចតទៅនេះ អជេតកាធិវសិំ ភជា បណ្ឌិតំ វីមំសិស្សាមាតិ បពិត្រអើយ មានកាលសម័យថ្ងៃមួយ, មហាក្សត្រាធិរាជ ជំនុំរះគិតនឹងអស់អ្នកប្រាជ្ញទាំង ៤ ថា យើងនឹងចង់ល្បងលព្រះមហោសថអ្នកប្រាជ្ញនោះគួរ ហើយស្តេចឲ្យយកកំណាត់គគីរមួយកំណាត់កាត់ចេញនៅតែប្រវែងមួយចំអាម ហើយឲ្យយកជាងមកក្រឡឹងឲ្យស្មើ ធ្វើមិនឲ្យដឹងជាចុង ជាដើមស្រេចហើយ ស្តេចឲ្យអាមាត្យនាំទៅកាន់សិរីវឌ្ឍកសេដ្ឋី នៅស្រុកបាចីនយវមជ្ឈគ្រាមនោះមកជំនុំពិចារណានឹងគ្នា ពុំអាចដើម្បីនឹងដឹងកំណាត់ឈើគគីរនោះថា ខាងណាចុង ខាងណាដើមបានឡើយ, ទើបថាជៀតមានព្រះបន្ទូលត្រាស់ឲ្យមកដល់អ្នកពលគ្នា ឲ្យយកកំណាត់ឈើគគីរនេះ ឲ្យដឹងជាខាងណាចុង ខាងណាដើម, បើដឹងហើយ អើនោះក៏ជាការឥតទោសពៃរ៍ឡើយ, ថាបើមិនដឹងហើយ ព្រះអង្គនឹងឲ្យត្រូវទោសជំណាំងដល់អ្នកឯងពលគ្នាបាន ១០០០ ជង ។ រីសិរីវឌ្ឍក-

សេដ្ឋី នូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាមនោះមកជុំគ្នា ពិចារណា ក៏ពុំអាចដើម្បីនឹងដឹងជាចុងជាដើមបានឡើយ ទើបសិរីវឌ្ឍកសេដ្ឋីគិតពិចារណាឯងថា មានតែចៅមហោសថកូនអញនេះមានប្រាជ្ញា ក៏អាចដឹងកំណាត់ឈើគគីរនេះជាចុងជាដើមមិនទេឡើយ, បើដូច្នោះ ចូរគ្នាយើងទៅហៅមកដណ្ដឹងល្បងមើល ។ ទើបសិរីវឌ្ឍកសេដ្ឋីឲ្យទៅហៅព្រះមហោសថ អំពីចរមសាលាក្រឡាល្បែងនោះមកក៏ដណ្ដឹងថា ម្នាលចាមហោសថកូនសំឡាញ់អាពុកអើយ! ឥឡូវនេះ មហាក្សត្រឲ្យយកកំណាត់ឈើគគីរជូនមកអាពុក នូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាមប្រើទាយឲ្យដឹងជាចុងជាដើម អស់យើងទាំងនេះ ពុំអាចដើម្បីនឹងទាយដឹងបានឡើយ ឯបាទើបមានប្រាជ្ញាអាចដឹងបាន, រីព្រះមហោសថអ្នកប្រាជ្ញស្ដាប់ហើយ ទ្រង់ចិន្តាពិចារណាថា នះមហាក្សត្រាធិរាជ ស្ដេចឲ្យជូនកំណាត់ឈើគគីរនេះមក ដើម្បីឲ្យទាយនឹងធ្វើជាប្រយោជន៍ឲ្យអញឯងហោង, ហើយថា បើដូច្នោះ ចូរអ្នកឲ្យនាំមកខ្ញុំនឹងមើលគេះ, ទើបសិរីវឌ្ឍកសេដ្ឋី ឲ្យនាំកំណាត់ឈើគគីរនោះមកឲ្យព្រះមហាសត្វអ្នកប្រាជ្ញ។ ទើបព្រះមហោសថ អ្នកកាន់កំណាត់ឈើគគីរនោះលើកឡើងហើយ ក៏ព្រះអង្គស្គាល់មួយរំពេចនោះឯងថា ឯនេះចុង ឯនេះដើម, តែពោះបើ

ព្រះអង្គដឹងប៉ុន្មានៗក្តី ក៏ធ្វើជាមិនដឹងឡើយ, ហេតុនឹងចង់យកចិត្តអ្នកផង ទាំងឡាយឲ្យដឹងផង ទើបព្រះអង្គឲ្យទៅយកកាជន៍មួយមកដាក់បំពេញ ទូវទឹកហើយឲ្យយកខ្សែអម្បោះមកចងទាក់កណ្តាលកំណាត់ឈើគគីរនោះ ហើយដាក់ក្នុងទឹកកាជន៍នោះ ហើយកាន់តែចុងខ្សែបណ្តោត, រីឯដើម សភាពជាធ្ងន់លិចចុះក្នុងទឹកកាជន៍នោះ ហើយអណ្តែតឯចុងឡើងវិញ ហោង ៗ លំដាប់នោះ ទើបព្រះមហោសថធ្វើជាមិនដឹងក៏សួរ អស់មហាជនទាំងឡាយថា ម្នាលអ្នកទាំងឡាយអើយ, នាឈើផងទាំងឡាយ នោះ តើធ្ងន់ឯដើមលើសឬធ្ងន់ឯចុងលើសហ្នឹង ? រីអស់មហាជន ទាំងពួងឆ្លើយថា បពិត្រព្រះមហោសថអើយ រីឈើទាំងឡាយធ្ងន់ឯដើម លើស, ទើបព្រះមហោសថប្រាប់ថា ម្នាលអ្នកទាំងឡាយអើយបើដូច្នោះ លិចមុននោះឯងជាខាងដើមឈើ. ដ្បិតសភាពធ្ងន់លើស ទើបលិច ចុះ, ឯម្ខាងនេះសភាពស្រាលជាចុងឈើហោង, ម៉្លោះហើយព្រះអង្គឲ្យ កត់សំគាល់ជាចុងជាដើមស្រេចហើយ ឲ្យនាំទៅថ្វាយព្រះមហាក្សត្រាធិ-រាជនោះវិញហោង ៗ ព្រះមហាក្សត្រាធិរាជស្តេចជ្រាបហើយ ក៏មានព្រះ រាជហឫទ័យនោះពេញទូវព្រះអំណរអរក្រៃពេក មានព្រះបន្ទូលដណ្តឹងថា អ្នកណាដឹងជាចុងជាដើមហ្នឹង ? រីអស់មហាជនផងទាំងឡាយ ក្រាប

ថ្វាយបង្គំប្រណម្យទូលថា សូមទានព្រោស ព្រះមហោសថកូនសិរីវឌ្ឍក-សេដ្ឋីនោះឯងអាចដឹងជាចុងជាដើមហោង ។ ព្រះមហាក្សត្រាធិរាជស្ដាប់ហើយ មានព្រះបន្ទូលដណ្ដឹងទៅកាន់អាចារ្យសេនកថា អើអាចារ្យគួរហើយ អញនឹងឲ្យទៅនាំបកមកទុកជាអ្នកប្រាជ្ញឬដូចម្ដេចហឹង ។ ឯអាចារ្យសេនកទូលតាស់ទៀតថា មហារាជ បពិត្រមហារាជអើយ សូមទានឈប់ស្វែះសិន រង់ចាំយើងខ្ញុំនឹងល្បងដោយនូវឧបាយកលឲ្យអស់ចិត្តហោង ។ ព្រះមហាក្សត្រស្ដាប់ហើយមានព្រះបន្ទូលថា ហៃអាចារ្យសេនកអ្នកគិតនោះនាច់ហោង ។

សីសដ្ឋិ នេះទឹងស្រដីពីការល្បងក្បាលខ្មោចដូចតទៅនេះ ។ អបេតាធិវសំ ឥត្ថិយា ច សីសំ បុរិសស្ស ច សីសដ្ឋិ ។ល។ មានកាលសម័យថ្ងៃមួយ ព្រះមហាក្សត្រាធិរាជនូវអ្នកប្រាជ្ញទាំង ៤ ជំនុំរិះគិតស្រេច ស្ដេចឲ្យល្បងលអ្នកប្រាជ្ញ ទើបឲ្យទៅយកក្បាលខ្មោចទាំង ២ មួយគឺក្បាលខ្មោចស្រី មួយគឺក្បាលខ្មោចប្រុស ហើយទើបឲ្យនាំទៅកាន់សិរីវឌ្ឍកសេដ្ឋី នូវអស់អ្នកស្រុកបាចីនយវមជ្ឈ-គ្រាមថា ដ្បិតមានព្រះបន្ទូលពិសេស ត្រាស់ឲ្យយើងនាំក្បាលខ្មោចស្រីមួយក្បាលខ្មោចប្រុសមួយ ទាំង ២ មកកាន់អ្នកឯង, ឲ្យទាយឯណាក្បាល

ខ្មោចស្រី ឯណាក្បាលខ្មោចប្រុស ថាបើអ្នកទាយត្រូវ អើតជាការឥតទោសឡើយ, ថាបើមិនដឹងហើយ ព្រះអង្គនឹងឲ្យត្រូវព្រះរាជទំណាំងពាន់ផង ។ កាលនោះសិរីវឌ្ឍកសេដ្ឋី នូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាមនោះ រមិលមើលក្បាលខ្មោចទាំង ២ នោះហើយ សឹងតែមិនដឹងពល់គ្នា, លុះទៅដណ្ដឹងព្រះមហោសថអ្នកប្រាជ្ញ ទើបព្រះអង្គរមិលមើលទៅយល់ហើយ ព្រះអង្គស្គាល់ជាក្បាលខ្មោចស្រី ជាក្បាលខ្មោចប្រុសនោះមួយរំពេចហោង ។ បពិត្រសប្បុរសជនទាំងឡាយអើយ នាព្រះមហោសថព្រះអង្គដឹងជាស្រីជាប្រុសនោះ តើហេតុដូចម្ដេច ? ថាដ្បិតក្បាលខ្មោចប្រុសមានសរសៃច្រើនត្រង់ ឯក្បាលខ្មោចស្រីមានសរសៃច្រើនវៀចក្រឡាបន្តិចហើយដាច់ចេញវិញ, ដ្បិតហេតុនោះហោងទើបព្រះអង្គដឹង ហើយព្រះអង្គប្រាប់អស់អ្នកទាំងឡាយថា នេះឯងជាក្បាលខ្មោចស្រី នេះជាក្បាលខ្មោចប្រុសហោង ។ សិរីវឌ្ឍកសេដ្ឋី មួយអន្លើនូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាមនោះ ឲ្យនាំក្បាលខ្មោចនោះទៅថ្វាយព្រះមហាក្សត្រាធិរាជវិញហោង ។ កាលណាបើស្ដេចជ្រាបសុភាពអស់អាថ៌សេចក្ដីនោះហើយ ក៏មានព្រះរាជហឫទ័យនោះ ដំពេញនូវព្រះអំណរអរក្រៃពេកហោង ។

អហីតិ នេះឯងទីងស្រដីពីការល្បងពស់នោះមិញ ៗ អជេ-
គធិវសំ សបញ្ញា សបរិធិញ្ញា អាហាភេត្វា អយំ
សបេប្បា អយំ សប្បីធីតិ ជាធន្ន អជាធន្នាធំ សហា-
សង្ឃធណ្ណាតិ បហាណាសុ ៗ បពិត្រអើយ មានកាលសម័យ
ថ្ងៃមួយវិញៈទៀតគូវ ស្តេចឲ្យរាជអាមាត្យយកពស់ឈ្មោលខ្វវពស់ញី
ឲ្យនាំទៅកាន់សិរីវឌ្ឍកសេដ្ឋី នូវអ្នកស្រុកបាចីនយវមជ្ឈគ្រាមថា ស្តេច
មានព្រះបន្ទូលត្រាស់ឲ្យយើងនាំពស់ទាំង ២ មកកាន់អ្នក ឲ្យអ្នកទាយ
ពស់ទាំង ២ នេះ ឲ្យដឹងជាឈ្មោលជាញី ថាបើមិនដឹងហើយ ព្រះ
មហាក្សត្រាធិរាជឲ្យត្រូវព្រះរាជតំណាំងពាន់ដងពុំលែងឡើយ ៗ សិរី-
វឌ្ឍកសេដ្ឋី នូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាមនោះ ពុំអាចដឹងបាន
ឡើយ ក៏នាំពស់នោះទៅដណ្តឹងពោធិសត្វអ្នកប្រាជ្ញ ព្រះអង្គយល់ពស់
នោះហើយ ទ្រង់ស្គាល់មួយរំពេចនោះហោង ៗ ថានាព្រះអង្គស្គាល់នោះ
តើដោយហេតុដូចម្តេច ថាធម្មតាពស់ឈ្មោលនោះ វាមានកន្ទុយនោះ
ធំវលហើយមានក្បាលនោះធំសមទឹងភ្នែក មានផ្ពកកនោះជុំវិញ ៗ រីឯ
ពស់ញីនោះសោត មានកន្ទុយនោះស្តួចក្តាត់ ហើយមានផ្ពកកនោះតិចៗ
មិនជុំវិញឡើយ, ហេតុនោះហោង ទើបព្រះអង្គដឹង ហើយព្រះអង្គប្រាប់

អស់អ្នកផងថា ម្នាលអ្នកទាំងឡាយអើយ នេះឯងជាពស់ឈ្មោល នេះឯងជាពស់ញីហោង ៗ អធិប្បាយសេចក្តីនេះ ដូចយើងបានស្រង់មកអំពីខាងដើមនោះឯងហោង ៗ

កុក្កុដោតិ នេះឯង នឹងស្រង់ពីការល្បងមាន់នោះមិញ ៗ

អថេកទិវសំ បាចីនយវមជ្ឈគាមវាសិនោ អម្ហាកំ សព្វសេតំ បាទវិសាណំ សីសក្ខន្ធំ តយោ វារេ អនតិក្កមិត្វា នទន្តំ មង្គលឧសភំ បេសេន្តុ នោ ចេ បេសេន្តិ សហស្សទណ្ឌោតិ សាសនំ បហិណីសុ ៗ

មានកាលសម័យថ្ងៃមួយ, ព្រះមហាក្សត្រាធិរាជ ទ្រង់សាបាយ្យតាំង ៤ ប្រើកដូតមួយនាំពាក្យមានទៅសិរីវឌ្ឍកសេដ្ឋី មួយអញ្ជើញនូវអ្នកស្រុក បាចីនយវមជ្ឈគ្រាមថា ព្រះបន្ទូលពិសេសត្រាស់ឲ្យមកកាន់អ្នក ឲ្យអ្នកកោគោមង្គលឧសភកាជ ឲ្យបាននាំទៅថ្វាយព្រះបាទជាម្ចាស់, រីឯគោនោះសោត ឲ្យមានខ្លួនៈនោះសល្អបរិសុទ្ធអស់ទាំងខ្លួនគោនោះហោង ៗ រីគោសោត មិនវិស័យដូចគោទាំងឡាយឡើយ ឲ្យមានស្នែងនោះដុះឯជើង ឬនោះមានឯក្បាល ហើយឲ្យបានស្រែកកើមួយក្រើ ៣ ដង មិនកន្ទួងលែងឡើកាលទាំង ៣ នោះឡើយ បើអ្នកបានគោដូច្នោះនាំទៅ

ថ្វាយនោះ ក៏ការផែតទោសឡើយ បើពុំដូចន័យព្រះបន្ទូល ក៏ព្រះអង្គពុំអត់ទោសឡើយ, ហើយទីនគ្រប់តំណាំនមួយពាន់ជនពុំខានឡើយ ។ រីសិរីព្រះសេដ្ឋី មួយអន្ទើនូវអ្នកស្រុកជនទាំងឡាយ មកជំនុំពិចារណាកំពាចយល់អាចសេចក្ដីប្រស្នានោះបានឡើយ ហើយមកដណ្ដឹងព្រះមហោសថអ្នកប្រាជ្ញ, រីព្រះមហោសថ ព្រះអង្គជំនពិចារណាប្រស្នាដោយនូវព្រះប្រាជ្ញាទិព្វ ឈ្វេងយល់មួយរំពេច ទើបមានព្រះបន្ទូលថា ម្នាលគ្នាយើងទាំងឡាយអើយ, ចូរអ្នកទាំងឡាយជ្រើសរើសរកមាន់សបរិសុទ្ធបានមួយឲ្យនាំទៅថ្វាយ, ដ្បិតមាន់នោះមានធ្លាល់ឯជើងហោង លោកហៅថា ស្នែងឯជើងវិញ; ឯមាន់នោះសោត វាមានសិរឯក្បាលនោះហោង លោកហៅថា ឫសឯក្បាលនោះវិញ, ឯមាន់នោះ វាតែងរងាវមួយយប់ ៣ ដង មិនកន្លងនូវកាលទាំង ៣ នោះឡើយ, ហេតុនោះឯង លោកថាជាគោកេទ៍ស្រែក ៣ ដងមួយយប់វិញហោង ។ រីអស់អ្នកផង ព្រួចស្ដាប់ព្រះមហោសថថាដូច្នោះ ក៏រកមាន់សល្អបរិសុទ្ធនាំទៅថ្វាយព្រះមហាក្សត្រាធិរាជ ព្រះអង្គជ្រាបហើយមានព្រះរាជហឫទ័យដំពេញនូវព្រះអំណរក្រពេក ដូចន័យដែលយើងស្រដីអំពីមុននោះហោង ។

មណឹតិ នេះទីស្រដ់ពីការល្បងមណីរតន៍ ។ សរេក្ខា ច កុសរញ្ញោ ធិរេង្ខាតិ មណិក្ខុត្តោ អត្ថិ ។ សេក អដ្ឋសុ ឋានេសុ វេក្កោ យោតិ ឥស្សរ បុក្ខណាសុត្តំ ធិដ្ឋិ ។ បពិត្រអើយ, កាលនោះ មានកែវមណីរតន៍មួយអំពីសម្តេចឥន្ទ្រាធិរាជ យកមកថ្វាយព្រះបាទកុសរាជ, រីឯកែវមណីរតន៍នោះសោតមានរន្ធនោះវៀច ៨ ស្ពាន, មានពន្ធីស្មើនោះក្តីរវៀងរៀងល្អល្អះត្រចះត្រចង់មហិមាក្រៃពេក, ពួចកាលនោះ រីខ្សែចាស់អំពីបុរាណដាច់បង់ផ្លើនយូរហើយ ឥតអ្នកឯណាមួយក៏ទឹងអាចដោះខ្សែស្បូត្រចាស់អំពីបុរាណនោះបានឡើយ ដ្បិតរន្ធមណីរតន៍វៀចច្រើនអន្លើ ហើយទឹងផ្ញើខ្សែស្បូត្រថ្មីដើម្បីទឹងបញ្ចូលទៅក្នុងរន្ធច្បោះមណីរតន៍នោះបានឡើយ ។ មួយសោតមានសម័យថ្ងៃមួយនោះហោង ព្រះមហាក្សត្រចង់ល្បងប្រាជ្ញាព្រះមហោសថអ្នកប្រាជ្ញ ក៏ព្រះអង្គប្រើកអាមាត្យនោះនាំកែវមណីរតន៍នោះទៅកាន់សិរីវឌ្ឍកសេដ្ឋីប្រាប់ថា ព្រះបន្ទូលពិសេសត្រាស់ឲ្យយើងនាំកែវមណីរតន៍នេះមកកាន់អ្នក ឲ្យដោះខ្សែមណីរតន៍អំពីបុរាណចេញ ហើយឲ្យយកខ្សែស្បូត្រថ្មីបញ្ចូលក្នុងច្បោះរន្ធមណីរតន៍ឲ្យបាន ថាបើបញ្ចូលពុំបានទេ ព្រះអង្គទឹងឲ្យត្រូវព្រះតំណាំងមួយពាន់ដង ។ សិរីវឌ្ឍកសេដ្ឋី

នូវអស់អ្នកផងទាំងឡាយ សឹងពុំអាចដើម្បីនឹងយកខ្សែសូត្រចាស់ នឹង
ផ្លាស់យកថ្មីបញ្ចូលពុំបានឡើយ ទើបអស់អ្នកផងទាំងឡាយ សឹងតែ
បបួលគ្នាទៅកាន់សំណាក់ពោធិសត្វ ប្រាប់ដោយដំណើរសព្វគ្រប់ហើយ
ព្រះអង្គពិចារណានូវព្រះប្រាជ្ញាទិព្វវិសេស យល់ដោយនូវកិច្ចបញ្ចូលខ្សែ
ក្នុងពេជ្រៈមណីរ័តន៍នោះឲ្យបានទាំងងាយប្រាកដក្តាត់ហោង ។ ទើបព្រះ
មហាសត្វ ព្រះអង្គមានព្រះបន្ទូលថា ហៃគ្នាយើងទាំងឡាយអើយ,
កុំបីអស់គ្នាយើងគិតឡើយ ទុកឲ្យអញឯងនឹងបញ្ចូលខ្សែមណីរ័តន៍នេះ
ឯង កុំបីឲ្យគ្នាយើងព្រួយបារម្ភឡើយ ទើបព្រះអង្គឲ្យទឹកឃ្មុំមកលាប
ស្រលាបនូវរន្ធពេជ្រៈមណីរ័តន៍ទាំងសងខាងស្រេចហើយ ព្រះអង្គឲ្យវេញ
ខ្សែប្រាលរន្ទាលថ្មីល្អ, ហើយឲ្យយកទឹកឃ្មុំមកលាបឯចុងខ្សែសូត្រនោះ
ហើយបញ្ចូលខ្សែនោះត្រង់រន្ធមណីរ័តន៍ស្រេចហើយ ឲ្យនាំទៅដំកល់ពួង
រន្ធស្រមោចវាតែងវារចេញចូល, រីឯស្រមោចផងទាំងឡាយ កាលណា
បើវាធុំក្លិនទឹកឃ្មុំ វាវារចេញមកខាំពាំនាំខ្សែសូត្រចាស់អំពីបុកណានោះ
រួចចេញអំពីក្នុងរន្ធនោះស្រឡះហើយ វាមកពាំនាំខ្សែសូត្រថ្មីនោះ វារ
ទន់ទាញត្រង់ចូលរមួលទៅក្នុងរន្ធនោះ លេចចុងខ្សែចេញមកឯខាង
ម្ខាងវិញហោង ។ កាលនោះ ព្រះមហោសថអ្នកប្រាជ្ញដឹងថា

ស្រមោចពាំនាំខ្សែលេចចេញដូច្នោះហើយ ព្រះអង្គចាប់យកមណីរតន៍នោះមក ហើយទើបឲ្យនាំទៅថ្វាយព្រះមហាក្សត្រាធិកជនោះវិញ ហោង ទើបស្តេចត្រាស់ថា ព្រះមហោសថអ្នកប្រាជ្ញ អាចបញ្ចូលខ្សែក្នុងប្រឡោះមណីរតន៍បានដូច្នោះហើយ ក៏មានព្រះហឫទ័យនោះដំពេញនូវព្រះអំណរអរក្រៃពេកហោង ៗ

វិជាយនត្តិ នេះនឹងស្រដីពីការល្បងប្រសូតកូនគោនោះវិញ ៗ

ឯកទិវសំ គាវិរ រញ្ញោ មង្គលឧសភំ ពព្ភ កុច្ឆា-សេ ទាតាបេត្វា មហោទរំ កត្វា វិសាណានិ ធោ-វិត្វា តេលេន មក្ខេត្វា ហលិទ្ទិយា នហាបេត្វា គាមកសីចំ បេសយឹសុ ។ ល ។ បពិត្រអើយ យើងបានឮរៀងៗមកថា មានកាលសម័យថ្ងៃមួយ ព្រះមហាក្សត្រាធិកជស្តេចឲ្យយកគោមង្គលឧសភរាជ ចងក្បាលឲ្យធំផ្ទៃបណ្ដែកច្រើន ធ្វើឲ្យរាហើមផ្ទៃពោះធំក្រៃ ហើយឲ្យពួតស្នែងគោនោះឲ្យរលីង ហើយយកប្រេងលាបលោងបំព្រងស្ម ហើយទើបយករមៀតផ្ចិតជូតអស់ទាំងខ្លួនគោ ឲ្យមានសម្បុរលឿងល្អ ហើយស្តេចឲ្យនាំទៅកាន់សិរីវឌ្ឍក្រសេដ្ឋនូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាមថា មានព្រះបន្ទូលពិសេសត្រាស់

ប្រើឲ្យយើងនាំគោនេះមកកាន់អ្នក ដ្បិតគោនោះមានគភ៌ចាស់ផ្ទៃហើយ ល្មមនឹងប្រសូតកូន ចូរអ្នកឲ្យក្រា.គោនេះឲ្យប្រសូតកូនចេញឲ្យល្អ ហើយ ឲ្យនាំទៅថ្វាយទាំងបាទាំងកូនគោនោះឯង, បើអ្នកឲ្យគោនេះប្រសូតកូន ចេញបាននាំទៅថ្វាយ ក៏ជាការឥតទោស, បើប្រសូតកូនពុំបានទេ ព្រះអង្គនឹងឲ្យត្រូវព្រះរាជទណ្ឌ ជាដំណាំងមួយពាន់ដង ពុំខានឡើយ ។ សិរីវឌ្ឍកសេដ្ឋី ទូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាមជំនុំគិតពិចារណា ថា យើងឯឡូវនេះ មហាក្សត្រាធិរាជ ព្រះអង្គឲ្យយកគោឈ្មោល មកឲ្យយើងរក្សាឲ្យមានកូន ធ្វើម្ដេចនឹងបានកូន ខ្លះថា អើអញឆ្ងល់ដែរ ហ៎ះ ខ្លះថា បើខ្ញុំឯងខ្លៅណាស់ហើយ តើហេតុអ្វីក៏មិនទៅរក លោកអ្នកប្រាជ្ញហ្នឹង ? ទើបសិរីវឌ្ឍកសេដ្ឋីឮ ហើយ ស្រដីប្រើបំរើឲ្យទៅ ហៅព្រះមហោសថអ្នកប្រាជ្ញ មកទឹងដណ្ដឹងហេតុអាថ៌សេចក្ដីនោះហោង ទើបអស់អ្នកទាំងឡាយស្ដាប់ហើយ ម្នីម្នារលះលោំងទៅកាន់សំណាក់ ពោធិសត្វ ហើយដំណាលដំណើររឿងច្បាប់សព្វគ្រប់ ទើបពោធិសត្វអ្នក ទៅយល់គោនោះហើយ ព្រះអង្គពិចារណាអាថ៌ប្រស្នាខ្ទូរចេះហើយក៏រះគិត គបជាអាថ៌ប្រស្នាទៅវិញទើបបានអេះ ។

( នៅមានត )

## ផ្នែកអក្សរសាស្ត្រ

# រឿងមរណមាតា

(តមក)

លោក ប៊ី សុវណ្ណ បម្រួលពីសាស្ត្រស្លឹករឹត

---

សុរាមេរយ មជ្ជប្បមាទដ្ឋានា ឲ្យវៀរចាកកិរិយា គឺផឹកស្រាទឹកស្រវឹង ៗ ពនាំឲ្យចិត្តហ៊ាន ផ្តាត់វិញ្ញាណសោះសូន្យឈឹង ប្រមាទឃ្លាតទីពឹង ទីងវង្វេងចិត្តតិរិយ ៗ កុដុម្ពិកទទួលសីល ឥតមន្ទិលពីឥសី ចាំចាំគ្រប់បាលី សេចក្តីប្រែមិនខានសល់ ៗ ស្រេចហើយព្រះឥសី ប្រើកុដុម្ពិកជ្រួចទឹកទស- ស្នោទកដម្រះអស់ កម្មវេរាជាបច្ច័យ ៗ ចូរញោមទាំងបីនាក់ ចាំឲ្យជាក់តែសព្វថ្ងៃ តាំងចិត្តឲ្យប្រពៃ ឲ្យបរិសុទ្ធក្នុងអាត្មា ៗ តាមសតិបរិសុទ្ធ តាំងប្រព្រឹត្តឲ្យសីលា ស្រេចហើយលោកកត្តា ថាអាត្មាចំរើនពរ ៗ លាញោមទាំងបីទៅ ទីលំនៅព្រឹក្សាករ ថាៈហើយអ្នកក្រោកឈរ ប្រែព្រះភ័ក្ត្រព្រហាមពាន្ត ៗ ដំណើរដើរស្រគត់ ឥរិយាបថល្អគេគ្មាន ស្រេចចរចេញចាកឋាន ចូលព្រឹក្សព្រៃទីបព្វតា ៗ ក្រោយព្រះឥសីទៅ ទីលំនៅព្រៃព្រឹក្សា កុដុម្ពិកបង់ចិន្តា ចាំសីល ៥ មិនឲ្យភ្លេច ៗ ដាស់តឿនកូនប្រពន្ធ ឲ្យទុកគុណសីលកុំដាច់ សព្វថ្ងៃ

មិនមានភ្ញេប ចិត្តកាចខូចពាលស្រឡះ ។ កុដុម្ពិកបានសាងផល សីលកុសលពីមុនក្រាស់ ទើបបានជួបប្រទះ ព្រះឥសីមកទូន្មាន ។ ឲ្យ តាំងក្នុងសីល ៥ ខ្ជាប់ចងចាំជឿក្នុងប្រាណ មិនបាត់បង់វិញ្ញាណ ជាប្រក្រតីសព្វទិវា ។ ទើបកុដុម្ពិកកាលី នាំកូនស្រីបរិភោគ្គា ស្រេចកាប់ឈើធ្វើជា ខ្ទមអាស្រ័យនៅទីនោះ ។ ហើយកាប់ចំការដាំ យកពូជត្រាំដាំដាក់ដុះ មួស្តាវីដាំចុះ ដើមល្អណាស់ដោយដិតទឹក ។ ដាំស្រូវស្វៃឃ្លោកល្ង សណ្តែកគ្រសក់ឪឡឹក ប្រើកូនឲ្យស្រោចទឹក ដាំត្រឡាចៈល្ពៅស្ពៃ ។ កាលីដើរទៅលក់ សព្វភូមិស្រុកគ្រាន់អាស្រ័យ កុដុម្ពិកនៅចាំដៃ ដំរះស្មៅដំណាំផង ។ ដំណាំផ្លែទុំខ្ចី នោះកាលីរៀបផ្គួផង ទូលៈទៅលក់សព្វជន បានជាប្រាក់ទិញភោគ្គា ។ រីឯអស់អ្នកស្រុក ចូលគ្រុកច្រើនក្រៀមក្រា សុំទិញអស់ផលា ផ្លែគ្រសក់ឪឡឹកស្វៃ ។ លុះបានឃើញកាលី មានកូនស្រីរូបល្អមល្អៃ កក្រ្តាស្រស់បំប្រថ្វាគ្រប់ដួងវង់ខែ ។ មានចិត្តចាប់ស្រឡាញ់ អរអស់អញ្ញតិតបៀតបែរ សាកសួររកឆ្នាំខែ ចង់ចងពន្ធមូលមេត្រី ។ អ្នកស្រុកមានកូនប្រុស ពាលកម្មោះស្រស់ប្រិមប្រិយ កុដុម្ពិកមានកូនស្រី រូបល្អល្អះសាក់សមគ្នា ។ ជណ្តើងបានដូចចិត្ត ព្រមគ្នាគិតរកវេលា សង់ផ្ទះការបុត្រភ្លា បានពេលាក្រាបសំពះ ។ សន្តានញាតិខាងប្រុស ច្រើនប្រុង

ប្រុះចង្អៀតផ្ទះ ប្រុសស្រីពាលក្មេងចាស់ មកជួយការជុំកុះករ ៗ រួបលើកចំណងដៃ ទ្រព្យថោកថ្លៃមកឈូនរ ញាតិខ្លះជាអ្នកក្រ គ្មានទ្រព្យអ្វីទីងចងដៃ ៗ យកដើមស្វាយដូងត្នោត ញាតិខ្លះសោតក៏មានព្រៃ ឈើទាលមកចងដៃ គ្រាន់ទុកជាធ្វើចន្ទុះ ៗ ខ្លះចងក្របីគោសេះដំរីកែបងចុះ ញាតិខ្លះទាបទ័លតុះ យកគន្ទីលបចងដៃ ៗ ញាតិខ្លះនៅស្រុកលើ ខំស្រូតដើរទៀយល្ហិតល្ហៃ យករទេះចងដៃបានពីលើកគ្នាជប់ទាក់ ៗ រួបលើកស្លកមករៀប ដន្ធ្លៀតគ្រៀបតាមយសស័ក្តិ នាម៉ឺនរៀបតុប្រាក់ ចំណីខ្វមសិនប្រាំដាន់ ៗ គ្រៀពស្ត្រអ្នកគ្រាន់បើ សិនយ៉ាងស្មើជាក់តុស្ពាន់ រៀបសិនជាប់ជាន់ តាមសណ្តាប់ស៊ីថ្នាក់ក្រោម ៗ ញាតិឆ្ងាយអ្នកតាលតាប ទទួលកាពារៀបយ៉ាងល្អម តុស្ពាន់ទីងបានគោម ប្រាំមួយស្លកដូច ៗ គ្នា ៗ អស់ញាតិទាំងប្រុសស្រី ចាស់ក្មេងក្តីទាំងព្រះពញា អ្នកមុខអ្នកមានងារ រៀបស៊ីផឹកត្រេកអរលេង ៗ ស្រេចហើយវិលលាទៅ ទីលំនៅស្រុកដំបន់ កុដ្ឋមីក៍ការកូនគន់ ស្រេចសុរេចមង្គលការ ៗ កុដ្ឋមិក៍បានផ្ទះថ្មីនៅប្រក្រតីជួរចិន្តា បានទាំងកូនប្រុសារ ជា ៤ នាក់គ្រាន់គក់ក្តៅ ៗ តាំងតែពីថ្ងៃនោះ ឥតមានមោះឥតហ្មងសៅ កុដ្ឋមីក៍កាលីនៅ ជាស្រុកទេសក្តេរកាគ្នា ៗ

បទកាកគតិ

ន័យនេះនៅទី– ទានទៅអំពី បរមក្សត្រា វិមលបពិត្រ ទ្រ រិទ្ធិក្លៀវក្លា កាលប្រើអាជ្ញា ពិឃាដជីវិត ។ នាងចន្ទូណី ស្រេចព្រះ-ចក្រី បរមបពិត្រ ត្រាស់ហៅអាមាត្យ មួយមានគំនិត គំនាប់ គាប់គិត ល្អល្អះចិន្ដា ។ ជាចៅក្រមធំ ទុកតែងជំនុំ ក្តីក្តាំនគរ អស់រាស្ត្រទាំងឡាយ សប្បាយគ្រប់គ្នា ព្រោះចៅក្រមជា ជំនុំក្តី ស្អាត ។ ទើបស្តេចត្រាស់ប្រើ បង្គាប់ទៅលើ អនុជិតអាមាត្យ ឲ្យជាចៅក្រម ជំនុំតាមខ្នាត ពិនិត្យឲ្យស្អាត រកទោសអក៌យាយ ។ ទូរទោសកុដុម្ពិក៏ កាលីទដ្ឋី ជាអាពុកម្ដាយ មេចន្ទូណី អប្រិយ អន្ទកយ អាមាត្យទុនកាយ ទទួលទង្ការ ។ ក្រាបលាករចុះ ដើរទៅ ចំពោះ ឡើងលើសាលា នាហ្មឺនធំតូច ជួបជុំត្រៀបត្រា ទើប អាមាត្យា ប្រើឲ្យទៅកោះ ។ អ្នកអក៌ជាធំ យកមកជំនុំ បម្រើ លាចះ ដើរដល់ពោះឆាប់ ប្រញាប់កាលនោះ អ្នកអក៌ក្រោកចុះ ពីផ្ទះយាត្រា ។ ស្រីង្ការទាំងឡាយ ដែលហៃអក៌យាយ ក៏បស្ទុក ពល់គ្នា អ្នកអក៌ដើរដល់ មណ្ឌលហើយណា ឡើងលើសា.ហ អន្ទុយនៅទី ។ អាមាត្យសួរថា អ្នកអើយក្សត្រា ជាម្ចាស់សិរសី ស្តេចឲ្យបុណ្យស័ក្តិ ពិភ័ក្ត្រនារី រក្សាទេវី វរខត្តិយា ។ ម្តេចយាយ

ប្រហែស ព្រងើយធ្វើធ្វេស ព្រះរាជធីតា អង្គអគ្គមហេសី សិរីវត្តិយា
មរណមាតា បរមបពិត្រ ៗ នាំនាងយកទៅ ទីណាហ្នឹងសៅ ដល់
ក្ស័យជីវិត ចេះចូអ្នកអក់ ធ្វើយមកដោយពិត អញនឹងពិនិត្យ តាម
ទោសនោះណា ៗ អ្នកអក់កិតភ័យ សំពះញ័រដៃ ជម្រាបទៅថា
តាមដោយគន្ធី ទំនើអតីតា ដូចបានពណ៌នា ពីមុនមកស្រាប់ ៗ
អនុជិតមាមាត្យ ជំទុំគិតស្អាត ឃើញហើយថ្លែងប្រាប់ ថាតាមមាត្រា
ឧក្ការប្រញាប់ អក់ឯងពុំគាប់ ពុំគួរទៅប្រាណ ៗ នាំអគ្គមហេសី
ចេញចាកបុរី បរមក្សត្រក្សាន្ត ស្ដេចវិលមកដល់ មណ្ឌលរាជឋាន
អក់ឯងពុំបាន ឡើងទូលក្សត្រថ្លៃ ៗ ទោសនោះធ្ងន់ក្ដាត់ ច្បាប់ត្រូវ
កាត់មាត់ កាត់ជើងកាត់ដៃ ទោសមួយទៀតធ្ងន់ ពេកពន់ក្រៃក្រ នាំ
មហេសីថ្លៃ ចេញពីរាជវាំង ៗ ឥតពិចារណា ពុំបានរក្សា ប្រហែសក្ដួច
ក្លាំង បណ្ដាយមហេសី លុះក្ដីមរណំ ទោសនោះហៅខ្លាំង តាមដោយ
មាត្រា ៗ ត្រូវឲ្យពិឃាដ បំបាត់ជន្មជាតិ ចេញចោលអសារ អ្នកអក់
កិតភ័យ ពេកក្រៃហាមា នឹកម្ដងហ្វាប់ជា ខ្លួនហាស់ម្ល៉េះហើយ ៗ
ទើបលាទៅផ្ទះ តាំងចិត្តជម្រះ ទុក្ខសោកបានស្បើយ រក្សាសីលសុទ្ធ
ស្រគត់ព្រងើយ យកសីលជាត្រើយ ទីពឹងអាត្មា ៗ ហើយចាយទ្រព្យ
ធន ឲ្យទានធ្វើបុណ្យ សព្វទិនទិវ កូនស្រីអក់នោះ នាមឈ្មោះ

ឆន្នា ទេវីជាតិជា សៅឡឹកក្សត្រថៃ ៗ បានជជីងរាម្ដាយ ពិតពុំសប្បាយ
មានទោសដល់ក្ស័យ ព្រោះនាងសារិកា ឆន្នាចិនថៃក្រ គុំគួន
សព្វថ្ងៃ ព្យាបាទពុំស្បើយ ៗ អនុជិតអាមាត្យ រកទោសមួយស្អាត
ទោសមួយទៅទៀយ គឺទោសកុដុម្ពក កាលីឥតត្រើយ ជំនុំឃើញហើយ
ទៀនទូលក្សត្រា ៗ ដល់ហើយបង្គំ ទូនអង្គប្រណម្យ ក្រាបទូល
ទៅថា ត្រាស់ប្រើយើងខ្ញុំ ជំនុំកាក្យា ទោសទាំងទ្វេហា ពុំបេរ
ក្សត្រថៃ ៗ វរទោសអ្នកអករ បានឲ្យហៅមក ជំនុំវិនិច្ឆ័យ តាម
ច្បាប់ក្រូវកាត់ នូវមាត់ជើងដៃ ទោសមួយធ្ងន់ក្រៃ លុះដល់ជន្មា ៗ
កុដុម្ពក–កាលី បញ្ចោតមហេសី ព្រះបាទពជា យកទៅសម្លាប់
តាមច្បាប់ត្រូវជា ពិឃាដជន្មា ប្រាំពីរសន្ដាន ៗ ស្ដេចស្ដាប់ត្រាស់ថា
អើទោសម្ដេចម្ដា ធ្ងន់ស្រាលប៉ុន្មាន ចូរធ្វើតាមទោស សន្ដោស
ពុំបាន ជំនុំរះឃ្យាន ឲ្យត្រូវមាត្រា ៗ អនុជិតអាមាត្យ ក្រួញក្រាប
បទបាទ ទទួលទុក្ខារ ស្រេចហើយបង្គំ ប្រណម្យក្សត្រា លាវិល
សាលា ជំនុំប្រក្រតី ៗ ដល់ហើយអាមាត្យ បង្គាប់ពេជ្ឃឃាត
នូវមុខមន្ត្រី ទៅចាប់កុដុម្ពក ចន្ទី កាលី នូវញាតិប្រុសស្រី ប្រាំពីរ
សន្ដាន ៗ គេកោះទាំងមេស្រុក ស្នងពាសកុំពុក ក្នាក់ងារប៉ុន្មាន
កងងារពេញនគរ គេកោះយកឲ្យបាន ទាំងអស់កុំខាន នាំមកឲ្យចាប់ ៗ

រីឯកុដុម្ពិក ការិចន្ទី ដាក់ក្តីឲ្យជាប់ តាមព្រះឱង្ការ ក្សត្រាបង្គាប់
ចូរទៅប្រញាប់ កុំវង់វេក ៗ ហើយគោះហៅហ្វាយ ស្រុកខូច
អន្តរាយ ទាំងស្បៀងភ្នាក់ងារ យកមកជំទុំ ទិតទិស្រវ៉ា តាមព្រះឱង្ការ
ក្សត្រក្សាន្តចមហៅ ៗ គាជាបុរសស្លាប់ ទទួលបង្គាប់ លុតលាចេញ
ក្រៅ ខ្លួចព្រះបម្រើ ទំដើរលឿនស្មៅ កាត់ប្រូតស្រូតទៅ កាសិក
រដ្ឋ ៗ កាលកុដុម្ពិក រត់ចេញបោលទី បោលស្រុកអាត្មា ក្រោយ
ញាតិសន្តាន ព្រៀងលានបណ្តា-កស្ត្រីក្រពល់គ្នា មិនដឹងខ្លួនសោះ ៗ
ព្រឹកព្រាងស្វស្តិ ភ្ញាក់ចុះដី ចុះដើរទៅឆ្ពោះ ដល់ផ្ទះកុដុម្ពិក ឃើញ
ទីផ្ទះនោះ ផ្ទះទៅស្ងាត់សោះ ពុំឃើញពុំយល់ ៗ អ្នកស្រុកភ័យគិត
បបួលគ្នាគិត ជំទុំរបល់ ខ្ទះថាទេអញ គិតពេញហៅធ្លល់ ហេតុ
ម្តេចក៏យល់ ក្បាលខ្មោចនៅនោះ ៗ ខ្មោចប្រុស ឬស្រី ទោសនោះ
ពីអ្វី ក៏ស្លាប់ដូច្នោះ កុដុម្ពិករត់បាត់ បោលផ្ទះស្ងាត់សោះ ខ្ទះស្តាប់
ថាឆុះ មិនដឹងទេអ្វី ៗ នៃអញស្គាល់ជាក់ ពិនិត្យជាក់លាក់ ខ្មោច
កូនកាលី កូនប្រសារគាត់នោះ ឈ្មោះចន្ទណី ហើយចុះកុស្តី យើង
នៅមិនជា ៗ គេរៀបរត់ចេញ ពីស្រុកនោះវិញ ចាកបោល
គ្រឹហា ស្រីខ្ទះខ្សឹបខ្សៀវ គិះគៀវប្រាប់គ្នា កុំឲ្យវេក រៀបរត់
រីកើយ ៗ ឯកាលិណី ជាបងកាលី នៅស្បៀមកន្ទើយ ទើបភ្ញាក់

ពីដេក ក្រឡេកមើលហើយ សួរថាអ្នកអើយ រៀបរត់ទៅណា ៗ
គេឆ្លើយប្រាប់មក ថាយាយទៅរក មើលផ្ទះលោកតា កុដុម្ពិកទីនជីន
ដំណើរកិច្ចការ កាលីណាំយា ក្រោកក្រេះដើរទៅ ៗ ដល់ផ្ទះកុដុម្ពិក
មើលមិញឃើញទី ស្ងាត់សូន្យហ្នឹងសៅ ដើរដល់ចូលជិត ពិនិត្យ
មើលទៅ ឃើញក្បាលខ្មោចនៅ លើផ្ទះកាលី ៗ ទើបកាលិណី
ស្គាល់ជាក្មេងស្រី ភ្ញាក់មាត់ថាយី មេចន្ទណី ម្ដេចក្ស័យជីវ៍ គិត
ឃើញថាយី អញនៅមិនបាន ៗ ម្លោះវិលមកផ្ទះ យកសំពត់ផ្លាស់
ស្លៀកខ្លាប់ប្រុងប្រាណ រៀបរបស់ អម្រស់ធនធាន គៀន
តិចតួចបាន កញ្ជើដាក់ទុក ៗ ហើយចូលក្នុងយក ហិបស្វាបានមក
អង្រែត្បាល់បុក រៀបហើយដាក់ស្រេច អំបិលប្រហុក លើកចេញមក
ទុក រានហាលនោះក្ទូ ៗ ចាប់យកកញ្ជើ អង្ករលើ រត់តាម
គេទៅ វារក្មេចសំពាយ អន្ទពាយតោលនៅ រត់តាមគេទៅ
ទើបគិតអនិច្ចា ៗ ថាឲ្យកាលី រត់ចោលបងស្រី ឲ្យស្លាប់អសារ ហន
រត់តែខ្លួន ទៅពួនទីណា គិតដើមគិតថា ស្លាប់ផងរស់ផង ៗ អញ
ស្មានជាពិត ម្ដេចឡើយប្រែចិត្ត រឺប្រចេញចោលបង ឲ្យស្លាប់តែឯង
កន្ទុងកន្ទន ស្ដីហើយយំផង តេច ៗ ដើរទៅ ៗ គេរត់ចោលបាត់
ម្នាក់ឯងស្ញប់ស្ងាត់ វង្វេងសៅដៅ ព្រៃតមាត់ភ្លក សម្រែកតាវៅ

ស្ពានជាគេហៅ ចំរត់ម្នីម្នា ៗ វាអស់កម្លាំង ខះកស្ងួតគាំង មាត់តែ
ទំពា ជញ្ជក់ជញ្ជប់ តែមាត់ទទេ ដឹងជាគ្មានស្លា ទើបរកតុល្ពោ ៗ
ដោយចាស់ហើយរត់ កម្លាំងតិចហត់ អន្ទុយជ្រះរោ ដង្ហើមតិចណាស់
ហេតុចាស់ទុំជោរ គិតឃើញថានេះ អញត្រូវសំរាយ ៗ ក្រូចហាបត្បាល់
ចុក បានអ្វីជ្រលក់ ស្លាស៊ីទុកកាយ ទុកម្ចាន់ហាន់ តាមទាន់មិនធ្លាយ
ក្រូចទាំងសំពាយ សំពត់ដណ្តប់ ៗ កាលនៅគ្រឹហា បើល្ងាចកាល
ណា រោចប្រាប់ ឥឡូវប្រស្រ័យ យកព្រៃជាម្លប់ បានអ្វីដណ្តប់ រោ
ជាចំខ្យល់ ៗ បើនៅឯផ្ទះ ជួនជាតើបពះ អាជ្ញាមកដល់ វាយកះទៅ
កាប់ សម្លាប់គ្មានសល់ រត់ពួនជាប់ខ្យល់ ស្លាប់ទីងរោ ៗ អន្ទុយ
សញ្ជឹង គិតសព្វមិនដឹង ទៅណាមកណា គិតម្តងថានេះ កុំរះទេព
ទៅផ្ទះយើងជា បានឈ្លួតដណ្តប់ ៗ គិតហើយក្រោកដើរ ក្រូចយក
កញ្ជើ ទៅរៀបលាន់លប់ ស្រូតរូតទៅផ្ទះ លលះគ្មានឈប់ ដើរផ្លួល
ជំពប់ តើបទីងអាជ្ញា ៗ គឺនាយពេជ្ឈឃាដ ដែលពជអាមាត្យ
ប្រើមកនោះណា បណ្តើរគ្នាហៃ ចិនខ្មែរយួនថ្ងា កាលីណាយា
ឃើញហើយភិតភ័យ ៗ រត់វិលទៅក្រោយ ហត់ហេតុព្រោះដោយ អត់
បាយពល់ថ្ងៃ ដើរដល់កញ្ជើ ក្អកហើរគង់ព្រៃ កញ្ជ្រៀវពេញ
ព្រៃ ចឹកស៊ីអង្ករ ៗ កំពប់ចាល់អស់ គ្មានសល់តិបសោះ ដោយ

ដកកគរ កាលិណើដល់ បានយល់ហើយហោរ យកដៃគក់គរ ទ្រូង
យំក្តែង ៗ ទុកអញសម្លាប់ គិតទៅជាគាប់ ប្រែខុសបញ្ញាសដៃង ឃ្លាន
បាយដាច់ខ្យល់ ពោះហលម្នាក់ឯង នេះគឺកម្មព្រេង តាមទាន់ថ្មី ៗ ៗ
ជាហើយទុនចុះ រើសអង្ករនោះ ចាំងស្មៅចាំងដី បានមកមួយក្តាប់
ចាប់ស៊ីចាំងដី លើកអកខ្សៀងខ្ញី គ្មានឆ្អែតទំពា ៗ រៀបលេប
ទឹកមាត់ ឃ្លានបាយពេកក្ដាត់ ស្ទើក្សយដង្ហា ដើរទៅដើរមក
ត្រលប់ត្រឡប់ព្រករក មិនដឹងទៅណា ឲ្យបានបាយស៊ី ៗ គេតែហោល
អស់ មិនឃើញដានសោះ ស្មៅគ្មានរំកិល គេទៅផ្លូវណា ពឹង
ពាក់ពូខទី ណាបាត់ដានពី នោះទៀតទៅហើយ ៗ កាលីណីយំ
គក់ទ្រូងស៊ីក្រំ ម្នាក់ឯងល្វើយ ៗ លទ្ធោចខ្លោចផ្សា ឥតការឥត
ត្រើយ ខំដើរទៅហើយ ឈ្លោកដានគន្ធ ៗ អង្ករមួយក្តាប់
បៀមគ្រាន់ជញ្ជប់ មាត់លេបម្តង ៗ កម្លាំងតិចតាប ដុនដាបកន្ទង
ដើរហើយយំផង ពេបខ្សែបអប្រិយ ៗ គឺកម្មគាត់ឯង ព្រោះចិត្ត
រង្វើង ប្រមាថក្សត្រ មរណមាតា ព្រះមហាមហេសី តាមទាន់
លោកិយ ឲ្យរងវេទនា ៗ ខំដើរមួយថ្ងៃ ពោះបាក់សន្ធៃ ដើរ
ដួលប្រើនគ្រា លុះដល់ព្រលប់ មិនឃើញរក ទើបបានជួបគ្នា ព្រៀង
លានចាំងឡាយ ៗ ដើរដល់ដួលដេក ដួលដាបឆ្អបក្តែក ស្ទឹង

ស៊ីតក្តនិកាយ អស់ព្រៀងសាច់ញាតិ ខ្ចីឃ្លាតខ្វល់ខ្វាយ ហៅឲ្យហូប
ចាយ ផ្អែតហើយដឹកទៅ ៗ រីឯពេជ្ឈឃាត ទំដើរខ្ចីឃ្លាត បាន
ដល់លំនៅ ខេត្រគូម៉ាកុដម្ពីក ឃើញទីហ្វនសៅ បាត់មនុស្សអស់ទៅ
ទៅផ្ទះស្ងាត់ធេង ៗ ឃើញតែគ្មានក្អែក កញ្ច្រៀវស្រៀវស្រែក ចឹក
ឆ្នាំងអំបែង ជ្រូកក្តាន់មាន់ទា ខ្ទែធ្លាកខ្ទេង ព្រុសលូល្វើយល្វេង
ស្រែងស្រូចមហិមា ៗ ពេជ្ឈឃាតមើលយល់ ទីតាំងមណ្ឌល ពុំមាន
មនុស្សម្នា ប្រើពលដើររក ក្រែងជ្រកពួនពា ខ្វះឡើងគ្រឹហា
យល់ស្ងាត់អស់ក្តី ៗ ផ្ទប្រាបនាយថា ពុំបរមេត្តា ទើបកេច្ច ៗ ក្នក់
ក្រើងគុកក្តៅ រណ្តៅទៅដី ស្នាមដើងថ្មី ៗ ទើបទៅតបសោះ ៗ
នាយបើកអំណាច ថារើយកុំខ្លាច រិចរើឲ្យអស់ កុំមានមេត្តា ករុ-
ណាវ៉ាសោះ ដំណាំទាំងអស់ តាមតែពល់គ្នា ៗ ពេជ្ឈឃាតទាំង-
ឡាយ តេចូលប្រញាយ ចាប់ជ្រូកមាន់ទា ចាប់គោក្របី ដំរីពល់គ្នា
ខ្វះឡើងបេះស្លា បេះដូងដីកទឹក ៗ ខ្វះចូលទៀងចិន យកបានផ្ទឹក
ចាក់ស្រាលើកផឹក កាប់ចេកខ្ទះស្វាយ ប្រញាប់ប្រញឹក ខ្វះចុះដងទឹន
លានឆ្នាំងដាំបាយ ៗ ធ្វើជ្រូកមាន់ទា ស្អាំងញាំភ្លា លើកជូនចៅ
ហ្វាយ រួចហើយពល់គ្នា ផឹកស្រាសប្បាយ ឆ្កាដៃនិយាយ ទឹកមាត់
ហូរខ្លាត ៗ មិនគិតអនិច្ចា កំណើតអ្នកស្រា អ្នកស្រែដូជាតិ

មកបួមចូលធ្វើ បំរើអាមាត្យ ផ្គាប់គេសង្កាត គ្រាន់តែធកស្រា ៗ
នាយធំសម្រេច គោត្ការួបស្រេច ដំនុំពជការ ថាយើងបំរើ លោក
ប្រើអាត្មា ចេញមកចាប់អា អ្នកទោសទាំងអស់ ៗ លោកប្រើប្រញាប់
ត្រូវចាប់ឲ្យចាប់ ត្រូវកោះឲ្យកោះ ឥឡូវដឹងខ្លួន . រត់ពួនទាំងអស់
យើងគិតពិគ្រោះ ធ្វើម្តេចចាប់បាន ៗ នាយមួយឆ្លើយថា យើងតាមរកវា
ទីងរត់ប៉ុន្មាន ស្អាក់រកបានតិច រំពេចចាប់បាន នាយធំឆ្លើយថ្កាន
ថាទេមិនជា ៗ ស្រុកនេះព្រៃធំ ព្រៃជិតជើងភ្នំ ឯងដឹងផ្លូវណា វាជាស
ដេញកាប់ ឯងស្លាប់អសារ ចោលខ្លួនឯកា ខ្ទបគេក្តីមិនខាន ៗ នាយ
មួយឆ្លើយស្មោះ ថាបើដូច្នោះ ធ្វើម្តេចចាប់បាន វិលទៅទទេ ក្រែងខុស
ខ្លួនប្រាណ យើងមិនអាចហាន រិះគិតយ៉ាងណា ៗ ឯនាយជាធំ ថាទេបើកុំ
ព្រះបាទពជា ស្តេចប្រើយកអ្នក នាំមកឲ្យវា កុំអីឃើញជា មិនដឹង
ខ្លួនសោះ ៗ នាយមួយថាអើ យើងឥតអំពើ ខាតបាតជើងសោះ
ចំដើរព្រួយប្រាណ មិនហាឡចឈប់ស្មោះ ឥតលាភទាំងអស់ ទាំង
លោកទាំងយើង ៗ មួយទៀតអាថា ព្រះបាទក្សត្រា ឥស្សូវថ្កល់ថ្កើង
ត្រាស់ប្រើចំពោះ លើអស់ទាំងយើង ឥឡូវបង់ជើង ពុំបានពជការ ៗ
ឯនាយជាធំ ថាទេអ្នកកុំ គិតថ្ងូកល់គ្នា ព្រោះតែព្រះអង្គ ស្តេចទ្រង់
គ្រោធា ទើបខ្ទបពជការ យើងធ្វើពុំបាន ។ គួរតែយើងទៅ យើង

ទូលព្រះចៅ ចក្រពត្តិក្សត្រក្សាន្ត តាមតែព្រះទ័យ ក្សត្រថ្លៃទ្រង់ព្យាន
គិតនោះទើបបាន ឃើញស្រួលពល់គ្នា ។ នាយទាំងនោះគិត ស្រួល
ព្រមគំនិត វិលក្រោយលើលា ដល់ប្តឹងអាមាត្យ ជាអាចថ្លែងថា ដូច
បានពណ៌នា ពីមុនមកនោះ ។ អាមាត្យឡើងទៅ ឡើងទូលព្រះចៅ
ជ្រាបត្រាស់ថាទុះ ហេតុម្តេចដឹងខ្លួន តែពួនដូច្នោះ អាមាត្យក្រាបចុះ
ទូលស្នងឧត្តរ ។ ពុំបោក្សត្រថ្លៃ ទ្រង់ជ្រាបព្រះទ័យ ដោយព្រះអាជ្ញា
ត្រង់នោះពុំដឹង ដំណឹងកិច្ចការ ទ្រង់ព្រះចិន្តា គង់ជ្រាបមិនខាន ។
ស្តេចទ្រង់សណ្ឋិត សន្និដ្ឋានរិះគិត ជ្រាបដោយទិព្វញាណ មានព្រះ
ឧត្តរ បរបាស្មោះស្មាន ថាទុកបាន ដឹងដោយអាជ្ញា ។ អញប្រើ
ឲ្យយក ឲ្យនាំពានផ្អក សាច់មនុស្សឲ្យវា ហេតុនោះឲ្យដឹង ដំណឹង
កិច្ចការ ណ្ហើយចុះពល់គ្នា អុំគិតកុំភ័យ ។ ឯទោសអក់យាយ ដែល
អ្នកទាំងឡាយ ជំនុំវិនិច្ឆ័យ លែងទោសគាត់ទៅ កុំទៅឲ្យក្ស័យ កុំ
ឲ្យគាត់ភ័យ គាត់គិតកាន់កាំង ។ ប៉ុន្តែឲ្យឃាត់ ស័ក្តិយសពីគាត់ កុំ
ឲ្យចូលរាំង ទោះស្នំស្នេហា បរិពារពលំ ខានគាត់ឲ្យខាំង ឲ្យខាត
ហូតចេញ ។ អាមាត្យបានស្តាប់ ស្តេចត្រាស់បង្គាប់ ក្រាបលាវិលវិញ
ធ្វើតាមអាជ្ញា ក្សត្រានោះមិញ អ្នកអក់អរពេញ ចិត្តសោមនស្សា ។
ហេតុស្តេចទ្រង់ធម៌ ព្រះទ័យស្មោះស មែនមានមេត្តា ស្តេចសាងបារមី

ជាពុទ្ធបិតា ព្រះច័យជ្រះថ្លា ដោះទុក្ខសត្វផង ។ ស្រេចហើយក្សត្រថ្លៃ
កំសាន្តព្រះច័យ ពុំមានសៅហ្មង អស់ស្រីស្រីគ្គារ បរិពារស្នំផង គ្រេក
អរគន្ធង ឥតឯកបមា ។ ពីថ្ងៃនេះទៅ ក្សត្រក្សាន្តបមទៅ គ្រេកសោម-
នស្សា នឹងនាងបក្សី សរីសារិកា មិនឲ្យឃ្លាតឃ្លា ឃ្លាតឃ្លៀងមួយថ្ងៃ ។
បើក្សត្រទ្រង់គម ចូលទីបន្ទំ បរមសុខសោយ នាំនាងសារិកា ចរចាសុំមៃ
ព្រះបាទក្សត្រថ្លៃ ផ្ទៀងព្រះកាមា ។ លុះតើនបាតទី សយនាមុនី
ស្តេចនាំសារិកា ចេញស្រង់ទឹកអប់ គ្រប់បុប្ផា ស្រង់ស្រេចក្សត្រា
ធិរាជចក្រ ។ ស្តេចសោយក្រយា ទិព្វទេសទុជា សេរៀនប្រក្រតី
សោយស្រេចក្សត្រក្សាន្ត ប្រទានចំណី ចែកចំផងក្តី ឲ្យនាង
សារិកា ។ ចេញចុងកេងរត្ន ព្រះបាទមហាក្សត្រ នាំនាងសារិកា
ឲ្យចំទៀបពាល់ គង់គាល់ក្សត្រា ត្រាស់ប្រើចរចា ស្តេចស្តាប់សំដី ។
សម្តេចក្សត្រា គ្រេកសោមនស្សា នឹងនាងបក្សី ពុំដែលឃ្លាតឃ្លា
ព្រះបាទចក្រ រៀងៗប្រក្រតី សព្វទិនទិវា ។ ស្រីគ្គារស្នំស្និទ្ធ សោក
សឹងមានចិត្ត ស្រឡាញ់កល់គ្នា អញ្ចើញនាងទៅ លំនៅត្រីហា លួង-
លោមសទ្ធនា ឲ្យស្តីនឹងស្តាប់ ។ ឯនាងសារិកា យល់ស្នំស្នេហា
ស្រឡាញ់រកកប់ នាងចង់ចរចា វោហារសាស័ព្ទ ស្នំស្និទ្ធស្តែងស្តាប់
ពុំលោះវេលា ។

បទពំនោល

ន័យនេះឈប់ស្ទុះពណ៌នា ពោលពីគ្រាមា នាមឈ្មោះព្រះចន្ទជន។
បទ ។ ជាខេត្តស្រុកក្រៅកំណត់ កស្រ្តផងប្រាកដ កំកើតមានចោរក្បួយ
ខ្លាំង ៗ លើកគ្នាជាទ័ពគគាំង តរល់ចេញច្បាំង ដណ្ដើមយកទ្រព្យ
អ្នកស្រុក ៗ មហាជនកើតហេតុកលិយុគ ជ្រិតចោរធ្វើទុក្ខ លំបាកលំ
បិនពេកក្រៃ ។ ក្មួយតូចផ្ទះតិចភិតភ័យ រត់ទៅព្រៃផ្សៃ ជ្រកនៅផ្ទះ
ច្រើនភូមិធំ ៗ នាំគ្នាកាប់ឈើរលំ ស្នាក់ប្រកតូចធំ ធ្វើជាទ័ពពាយ
ពល់ស្រុក ៗ ចោរលើកទ័ពចូលគគុក ឥតខ្លាចចូលលុក រុកពន
ទន្ទ្រានបន្ទា ៗ ខ្លះពាយបែកពីគ្រាមា ប្រាំពីរជាន់ជា ជួរជិតប្រកិត
ជុំស្រុក ៗ អស់កស្រ្តក្នុងភូមិកើតទុក្ខ ភិតភ័យពកលាមក ស្រែកយំ
ទ្រហឹងអឺងកង ៗ ប្រុសខ្លះបេះគុណដំបង ចេញទៅប្រឡង ប្រឡូក
ទឹងចោរការស្រុក ៗ ចោរបេះគុនខែលចូលលុក ច្បាំងនឹងអ្នកស្រុក
សំរុកសំរុញចូលបាន ។ ប្ញន់រាយយកទ្រព្យធនធាន ដាល់តប់ធាក់ប្រាន
អ្នកស្រុកពាញ់ចោរគ្រាំគ្រា ៗ អ្នកស្រុកស្រែកហៅមហិមា ហៅភូមិ
ជិតគ្នា មកជួយមកចូលប្រកាប់ ៗ ចោរខ្លះរាំតាក់ក្រពាប់ ចំរូងដែកស្រាប់
ពាយស្នាក់គ្រប់ប្រកចាំនៅ ៗ ភូមិជិតឮគ្នាស្រែកហៅ ម្នីម្នារត់ទៅ ចំរូង
ក្រពាប់មុតដើង ៗ ឈើធៀបក្ដៅផ្សាដូចភ្លើង ដួលស្រូសក្រោកឡើង

នឹងដើរពុំបានឡើយណា ៗ ឯចោរឡើងរើទ្រព្យ យកតាមចិត្តរាំ បាន ហើយត្រឡប់វិលទៅ ៗ អ្នកស្រុកកើតទុក្ខកាត់ក្តៅ ដៀតចោរវាយត្រូវ ដំណាំឈើក្រកាយា ៗ ខ្លះត្រូវរបួសធ្ងន់ស្វា បាក់ដៃបាក់ស្មា ពិការខ្វៀនខ្វិន ជាទុក្ខ ៗ កើតកោលាហលគ្រប់ស្រុក អស់រាស្ត្រពុំសុខ ពុំសូវសប្បាយ ទ័យា ៗ គ្រប់ខេត្តស្រុកក្រៅនានា នាំគ្នាល័លា ទៅប្តឹងស្តេចត្រាញ់ សម្រេច ៗ ចៅមឿងស្តេចត្រាញ់ដឹងស្រេច កេណ្ឌពលរំពេច រាប់សែន សុទ្ធសឹងខ្លះខ្លាំង ៗ លើកចេញទៅប្រាប់ចោរខ្លាំង ចោរលើកក្តួយ ម៉ឺន ចេញច្បាំងចៅមឿងធំពាញ់ ៗ លើកទ័ពថយក្រោយវិលវិញ ពលកើតទុក្ខម្ចេញ ក៏រត់ចោលស្រុកអាត្មា ៗ ជ្រកពួនសព្វព្រៃព្រឹក្សា ចោរមានជយា រកកនគង៌ានដេញដិត ៗ ចៅមឿងស្តេចត្រាញ់ក័យកិត ស្ទើរក្ស័យជីវិត ក៏រត់ទៅប្តឹងមន្ត្រី ៗ ជាធំសម្រេចផែនដី ឯអស់មន្ត្រី ក៏នាំសេចក្តីនោះទៅ ៗ ឡើងទូលក្សត្រាចោមចៅ ស្តេចជ្រាប ដោយនៅ ដំណើរត្រាស់ប្រើអម្ចាស់ ៗ ឲ្យកេណ្ឌពលពាលសេនា គ្រប់សាសន៍ភាសា ដាក់មេដាក់នាយកំណាន់ ៗ សឹងមានគ្រប់គ្រឿង ប្រកាន់ កេណ្ឌបានរួសពន់ ក៏ឡើងក្រាបទូលក្សត្រា ៗ ស្តេចជ្រាប សព្វគ្រប់ប្រការ ត្រាស់ប្រើអមច្ចា ឲ្យជុំចតុរង្គពាហាន ៗ ពួកពល ថ្មើរជើងប្រុងប្រាណ ពលសេះក្បាហាន ពលរថគជេន្ទ្រជើងសឹក ៗ

រូបកងឆាត់ធំពន្លឺក ប្រទះច្បាំងសឹក មិនថុចមិនថយរួញរា ៗ សឹងមុត
សឹងមានជយោ ធ្វើសឹកច្រើនគ្រា ប្រសព្វប្រសិទ្ធិរិទ្ធិរឹង ៗ សេនា
ថ្មើរជើងបើង រូបធំខ្ពស់ស្ពឹង ក្រអើតក្រអាញស្វាញស្វិត ៗ សេនា
អាសាស័ក្តិសិទ្ធិ ក្លៀវក្លាគំនិន កំឡោះកម្លាំងស្មើខ្យល់ ៗ សេនារថា
មង្គល បើកបរគង់ ប្រទូស្តប្រទះឥតក្តុក ៗ សេនាគជេន្ទ្រស័ក្តិ
សឹក ចិត្តមុតដ៏ពន្លឺក សាហាវសហ័សពេកក្រៃ ៗ រូបកងឆាត់ធំស្លឹម
ស្រៃ ក្លាក្លៀវប្រៀវប្រៃ កំហោះទ្រហឹងអឹងកង ៗ ត្រួតត្រាសេនា
ពលផង សូរស័ព្ទរំពង កញ្ជ្រៀវខ្ទាន់ពស្មុគា ៗ ជុំស្រេចសម្តេចពញា
ទ្រង់គ្រឿងសោភា ព្រះមកុដអាភមរត្នកយ ៗ ភ្លឺប្រុះផ្លាសថ្ពុះព្រោង
ព្រាយ ចេតចោមធាធាយ គ្រប់គ្រប់រស្មី ៗ ហាក់ដូចអគ្គឥន្ទ
កោសិយ ស្រេចព្រះបក្រី ស្ដេចយាងចេញចុងរោងរត្ន ៗ នាហ្មឺន
ឡើងគាល់ច្រើនក្កាត់ ទើបព្រះមហាក្សត្រ ស្ដេចផ្តាំអគ្គឯកមន្ត្រី ៗ
ឲ្យប្រុងប្រយ័ត្នបុរី ស្រីគ្គាសៅស្រី ទីតាំងនពជកំងរត្នរម្យ ៗ ប្រាសាទ
ក្រឡាបន្ទំ អករយាយស្រីស្ងំ រក្សាសារិកាឲ្យល្អ ៗ ក្រែងមានអន្តរាយ
ភ័យមរណ៍ ផ្តាំស្រេចភូធរ ឡើងគង់ទីនាំងគជសារ ៗ បនគ្រៀង
មាលមាសបេនា ភ្លឺតាំងយាកា តព្រោងពព្រាយថ្ពុះថ្លាស ៗ បញ្ចោង
ប្រាសាទសឹងមាស រត្នកាយផាំផាស ពៃទូរ្យស្មុំកាទមុក្តា ៗ រស្មីហាក់
ដូចសុរិយា ទៃងតាំងវេហាស៍ រន្ទាលប្រះប្រាលពេកក្ដាត ៗ ព្រាហ្មណ៍

ទេសផ្ទុំសាំងប្រឆាត់ ដង្ហែមហាក្សត្រ ចេញចាកក្រុងកែវបេនា ៗ ពលពង្សចតុរង្គអាសា តាំងហោ៊បីត្រា ខ្ចរខ្ចាយញាប់ញ័រប្រថពី ៗ ភ្លេងផងពាតគង់ភេរី សព្ទស្នូរដន្ត្រី ប្រគោះប្រគំព្យខ្ទាំង ៗ ស្គរទ័ពស្គរ ទូងស្គរទាំង ទូរស្គរពិណពាំង សុរភោរហោ៊ទុករមនា ៗ ទង់ជ័យមាស មៃលាតណា ប្រាស់ប្រាលមហិមា ទង្គួលទង្គុំដេរដាស ៗ ស្រទំខ្ទលៈ ខ្មៅអាកាស ពពកដេរដាស ដោយតេជអានុភាពក្សត្រា ៗ ទៅមឿង ជាមុខសេនា ទ័ពស្រួចក្សត្រា នាំផ្លូវតម្រូវទ័ពទោរ ៗ ចាត់ចែងជាបែក ពហុលោ សឹងមានតេជោ តេជៈតបៈរឹងរិទ្ធ ៗ បែកស្គាំលលាំពិទិត្យ បែកធ្វេងជំប្រសិទ្ធ ទ័ពល្អូខសឹងរិទ្ធិក្លា ៗ ស្តេចលើកចតុរង្គពហុលា ប្រាំពីរទិវ៉ា បានដល់ព្រះចន្ទជនបទ ៗ វេលាសុរិយារលត់ អ័ព្ទអស្តង្គត ព្រលប់ជួបចូលសិទ្ធិយា ៗ ព្រះចន្ទចែងចាំងវេហាស៍ ស្រឡះមេឃា ត្រចះត្រចង់រស្មី ៗ ស្តេចឲ្យបញ្ឈប់សេនីយ អាមាត្យមន្ត្រី ក៏លើកព្រះ ពន្លាជ័យ ៗ រួចស្រេចរំពេជធាប់វៃ ព្រះបាទក្សត្រថ្លៃ ឡើងគង់ក្រឡា មណ្ឌល ៗ អាមាត្យចាត់ចែងរេហ៍ពល ឲ្យបោះទ័ពទល់ ទាបទាយរៀប វាយប្រកិត ៗ ជាជួរប្រាំពីរជាន់ជិត គយល្បាតពិទិត្យ រានភ្លើងភ្លឺផ្ទុក ព្រោងព្រាយ ៗ គ្រប់ច្រកគ្រប់ទ្វារទ័ពទាយ ទាំងបាវទាំងនាយ ក្រវែល រង្គាត់ទៅមក ៗ កាំភ្លើងមេរៀបគ្រប់ច្រក កាំភ្លើងដៃដក រនុកច្រកគ្រាប់

ដើរល្បាត ៗ សេនាហាត់រៀនបានខ្នាត ធ្វើការសង្វាត មិនឈប់មួយយប់

ទល់ព្រឹក ៗ សូរស័ព្ទសន្ធាសន្ធឹក គគ្រឹកគគឹក ដោយនាយសេនាទ័ពធំៗ

ស័ព្ទភ្លេងល្វើយល្វើងរងំ ត្រែសង្ខប្រគំ រំពងព្រៃព្រឹក្សអគ្គា ៗ ឮលាន់

ស្មើរផ្ទាយពសុធា ហោហៅគ្នា សន្ធឹកសន្ធាប់ឮឆ្ងាយ ៗ រីឯអស់

ពពួកទាំងឡាយ ឮសូរស័ព្ទសាយ ក៏ដឹងជាទ័ពក្សត្រា ៗ ស្ដេចលើកចតុរង្គ

សេនា ចំពោះភ័ក្ត្រា ទៅត្រូវទ័ពរាំងផ្លូវនោះ ៗ ភិតភ័យញាប់ញ័រពុងពោះ

រូតរត់ចោលអស់ នៃស្បៀងសម្បត្តិភ័ស្ដុការ ៖ ទាំងគ្រឿងនូវទ្រព្យជា ៗ

រត់ចោលឃ្លាតឃ្លា ពុំបានជាប់នៅអាត្មា ៗ ចោលទាំងខោអាវភ័ស្ត្រា គជ

កាសគាប ទាំងភ្លុកគជព្រះសហឹង ៗ រត់ខ្លួនទទេមិនដឹង ភិតបាត់ព្រលឹង

ដោយគេជក្សត្រាពណ្ណរាយ ៗ ខ្លះចេញតាមច្រកបន្ទាយ ខ្លះភ័យរាយមាយ

ទំលាយបន្ទាយពុំបាន ៗ ខ្លះមុជមមុលធ្លាក់ប្រាន ជាប់រងើអស់ប្រាណ ពក

អាចម៍ពកនោមពេញខោ ៗ ភិតភ័យតឹកតងពោទ្យា សុតស្ងួនស្ងឹងស្ងោ

ប្រាត់បង់វិញ្ញាណសោះសា ៗ វេករត់ផ្លាយលាមកផ្លាយមូត្រ ពួនសព្វកំពោត

កំពប់អង្គអស់ផង ៗ រត់ខ្លួនទទេរលីង អាវខោចោលផង អាក្រាត

អាក្រាសនៅរាល ៗ ដងើកដងអាកដងអាល ខ្លះចាប់បានផល សំបកទទេ

រត់ទៅ ៗ រត់ពីសៀលថ្ងៃនៅ លុះដល់យប់ជ្រៅ ទៅពួននៅគុកគុហា ៗ

ន័យនេះឈប់ស្ងួតពណ៌នា ពោលតពីជា វិមលវង្សរង្គជាញជ័យ ៗ

ព្រឹកព្រាងស្រេចស្រាងទទ័យ តើខពាកសុខសេឃ្យ ស្រប់គ័ក្រពេញគង់
ក្រឡា ៗ តំនាល់ទិពទីអាសនា ចតុរង្គអាសា គង់គាល់ជាជួរគាប់គាន់ ៗ
ដោយបែកដោយពួកកំណាន់ ស្តាំឆ្វេងច្រើនជាន់ ជុំជិតប្រកិតត្រៀបត្រា ៗ
ទើបស្តេចបើកព្រះទស្សនា ត្រាស់ប្រើអមច្ចា នូវពួកទាហានពាលា ៗ
ទៅមើលបន្ទាយទ័ពចោរ តែចោរមោហោ វាគិតប្រការម្តេចម្តា ៗ អាមាត្យ
ទទួលបង្គាប់ បង្គំលុតលា ផែលឡើងពាជីបរទៅ ៗ បានដល់ទ័ពចោរ
ឃោរឃៅ ឃើញបន្ទាយនៅ ស្ងួនស្ងាត់បង់បាត់មនុស្សម្នា ៗ អាមាត្យ
នូវពលយោធា ចុះពីអស្វា ចូលក្នុងបន្ទាយមើលជាក់ ៗ ឃើញសឹង
ទ្រព្យចោរអប្បល័ក្ខណ៍ ប្អូនបានមកដាក់ រៀបទុកពេញតាំងបន្ទាយ ៗ
ពានគោកថាសត្តឆ្នាំងបាយ មាសប្រាក់វត្ថុភាយ សំពត់ហូលព្រែកាសា ៗ
អាមាត្យហាមប្រាមសេនា នៅពលអាសា កុំឲ្យយកទ្រព្យនោះនៃ ៗ
ចាំទូលក្សត្រាជៀសជ័យ តាមតែព្រះទ័យ ទ្រង់ឈ្វេងប្រការម្តេចមិញ ៗ
ថាហើយនាំគ្នាវិលវិញ បរសេះចរចេញ ដល់ហើយឡើងទូលក្សត្រ
ថៃ្ង ៗ ស្តេចបន្ទូលទៅថាហៃ អាមាត្យវៃៗ ចូលធាប់ប្រញាប់ម្ន័ម្នា ៗ
ទៅប្រាប់អស់រាស្ត្រប្រជា ឲ្យវាំនាំគ្នា មកគិតជញ្ជូនយកទ្រព្យ ៗ
របស់នរណាស្គាល់ស្រាប់ កុំឲ្យសាប់ឡាប់ ទៅយករបស់គេវិញ ៗ
អាមាត្យលុតលាចរចេញ រួតរត់ត្របាញ់ ប្រាមប្រាប់អស់រាស្ត្រនានា ៗ

អស់ពស្រ្តគ្រែកអរមហិមា បបួលគ្នីគ្នា មកដឹកជញ្ជូនទ្រព្យធន ។ គ្រែកអរពល់គ្នាពេកពន់ បានទ្រព្យថទបុណ្យ ក្សត្រក្សត្តនទ្រើសទ្រង់ករុណា ។ សីង៍ថ្វាយស័ព្ទសាធុការ ពល់មាត់ពល់គ្នា នៅឡើ ទ្រហឹងអឹងកង ។

បទព្រហ្មគីតិ

ព្រះបាទវិមលធម្ម ពជទត្តមលើសលោកផង ស្ដេចប្រាប់សឹកយង់យួង បានបាក់បបដោយចេស្ដា ។ ស្រេចហើយក្សត្រប្រាស់ប្រង់ប្រាប់ពស្រ្តផងស្រែចំការ ឲ្យចេញពីព្រឹក្សា មកនៅភូមិស្រុកទីទៃ ។ កាលណោះពួកអ្នកស្រុក មីគេគុកច្រើនក្រាស់ក្រៃ បរចេញពីគុងព្រៃ មកនៅភូមិគ្រប់អាត្មា ។ ឯអង្គក្សត្រកូនាថ ស្ដេចប្រពាតព្រៃព្រឹក្សា ចតុរង្គអង្គសេនា ហែក្សត្រក្សត្តចរចូលព្រៃ ។ បរចាប់សត្វម្រឹគា ព្រះពជាក្សត្តព្រះទ័យ សេនាពលទ័ពជ័យ សីង៍សប្បាយឥតក័យា ។ ឯអស់ចោរទាំងឡាយ រត់ទៅឆ្ងាយក័យមហិមា ព្រះស្ដេចលើកយោធា ប្រពាតព្រៃចាប់ម្រឹគា ។ ស័ព្ទស្បូរអស់កងពល រត់រចល់រកហៅគ្នា ញាប់ញ័រទាំងព្រឹក្សា ស្មានជាស្ដេចដេញអាត្មា ។ នាំគ្នារត់ទៀតទៅ ចោលទោអាវ ស្បៀងកោក្កា រត់បាត់ម្ខាត់អាហារ ដាច់ពោះស្លាប់កងព្រឹក្សព្រៃ ។ ខ្លះពួនកូងរូងកំ គ្រុនសន្និស្គមសខ្មៃ ស្លាប់

ពោលខ្លោចក្នុងព្រៃ ច្រើនអនេកពេកក្រៀបក្រា ។ ស្លាប់អស់គ្មានសល់ម្នាក់ ដោយធុរៈច្រើនប្រការ ខ្លះពួនពានលើខ្លា ខ្លាខាំស្លាប់ពាំយកទៅ ។ ខ្លះតែពានលើពស់ លេបទាំងរស់គ្មានសល់នៅ ហេតុកម្មពារឃោរឃៅ ឲ្យស្លាប់អស់ដោយវេរា ។ និទានគតិខ្មែរជូនប្រៀបប្រែពាលពណ៌នា កាលស្ដេចលើកយោធា ចេញទៅប្រាប់ពោរក្ខយខ្មាំង ។ ចាក់បបដោយបារមី ព្រះចក្រីទ័ពខ្លាំង ដល់ស្ដេចលើកគួយហាំង ចូលប្រពាតព្រៃព្រឹក្សា ។ ដំណើរទំនងកាព្យ កិច្ចសុភាពពិតសត្យា សុំរេចដួបចូលជា ខ្មែរប្រាំប្រាកដមែនមាន ។

បទកាកគតិ

នេះនៅរៀបរាប់ រៀបរៀងសាសត្ត សាសនដោយដាន តែងតពីខ្មែរ ប្រាំប្រែទំពាន ពិតពីក្សត្រក្សាន្ត វិមលចេស្ដា ។ កាលក្សត្រប្រពាត ព្រឹកព្រៃរុក្ខជាតិ ឈប់ស្រះបរបា នេះទីងទាំង-ពានពីសា-រិកា កាលក្រោយក្សត្រា ស្ដេចលើកទ័ពទៅ ។ នាងនាថនៅទិត្យ ក្នុងវាំងស្នេហ៍ស្និទ្ធ ឯកឥតហ្មងសៅ អស់ស្នំស្នេហា បរិវារក្នុងក្រៅ អញ្ជើញនាងទៅ លួងលោមបរបា ។ ហើយថ្វាយចំណី ចេកទំនិក្តនូវអស់ផលា ទូរេនមង្ឃុត ទំងលុតសេដា ទំកយ៉ុំផលា ប្រឡំនូវលាជៗ រៀបជូនសារិកា ឲ្យបរិភោគ្គា សព្វថ្ងៃព្រឹកល្ងាច ឯនាងសារិកា រាំហារប្រោសប្រាជ្ញ អស់ស្នំគោតខ្លាច ស្រឡាញ់រាល់គ្នា ។ មិនហ៊ានឲ្យអាក់

ឲ្យគន់ថ្នាំងថ្នាក់ ចិត្តនាងឡើយណា បើនាងក្អកទឹក រលឹកក្សត្រា ស្រីខ្វះបរបា លួងលោមឲ្យសើច ៗ ថាអ្នកម្ចាស់ថ្លៃ អញ្ជើញទៅថៃ ច្បាំងទឹងសង្កើច ថៃបោលហ៊ស ក្រឡេះថៃសើច លោតខាំសង្កើច ដួលផ្កាស្រពាង ៗ ខ្វះថាអ្នកម្ចាស់ មើលមួសធំណាស់ ខ្ទមប៉ុនពីងពាង ខ្ញុំនេះរាក្ងាក់ រាងាក់ខ្ញុំក្បាង ខ្ញុំដួលស្រពាង រាហើរតែបាត់ ៗ សារិកា ធើតធោម ស្តាប់គីលៀងលោម លួងសើចច្រើនក្អាត់ នាងធ្វើសែកាយ ថែកតាយសាសេត្យ គីលៀងអរក្អាត់ សើចសាទកល់គ្នា ៗ ស្រីស្នំ អក់យោយ សោតសីងសប្បាយ ធៀនកល់វេលា លុះល្ងាចព្រលប់ យប់សន្ធ្យា នាំនាងសារិកា ចូលទ្រុងមាសថ្លៃ ៗ កល់ពេលវេលា ហេតុគៀរវេក សារិកាទេះនៃ ពីព្រេងពេតពន់ កម្មជួន់ក្រាស់ក្រៃ តាមពាន់ស្រីថ្លៃ ឲ្យកើតទុក្ខម្នេញ ៗ

បទព្រហ្មគីតិ

មានគាសមួយទិន ហេតុវេកពីមុនមិញ មានស្នំដទៃវិញ ឈ្មោះនាងចន្ទាទេវី ៗ ជាគូនអ្នកអក់មួយ ដែលស្តេចឲ្យបណ្តេញគី ក្នុងកំនើតេញតាគទី ទៅកស៊ីដោយទម្ងន់ ៗ ដាក់ផ្កាស្នាបារី លក់ប្រក្រតីគស់គេគពន់ មិនដែលធ្វើការជួន់ ជាទុជិនខ្យត់តុះតាប ៗ ធន្ទាបានឃើញឡាយ ពុំសប្បាយទុក្ខតួលភាព រកស៊ីយល់ថាពាប

លក់ដូរនៅដោយកនផ្សារ ។ ឆន្ទាចងអាឃាត ចងព្យាបាទនាង សារិកា គិតថាអ្នកមាតា កាលដើមឡើយមានបុណ្យស័ក្តិ ។ ឥឡូវប្រែជាខ្សត់ យ៉ាងទុគ៌តឥតមាសប្រាក់ រកស៊ីនឿយសស្រាក់ តស៊ូម្ល៉េះហើយមកលំបាក ។ ព្រោះតែមេសារិកា ទើបមាតាអញ តោកយ៉ាក ម្ល៉េះហើយបានលំបាក នឹងដៃអញនេះមិនខាន ។ ឆន្ទាគិតដូច្នោះ ហើយក៏ដើរចុះតាមបាន ឡើងលើវិមាន ចូលបន្ទំមហាក្សត្រា ។ ថ្ងៃនោះជួនអស់ស្នំ ទូវតាស់ទុំក្អួចសារិកា ពុំបាននៅគ្នា ជាប្រក្រតីដូចសព្វដង ។ ហេតុកម្មនាងស្រីថ្ងៃ ពីព្រេង នៃនាងមានហ្ន បញ្ចូលចិត្តសុំផង ឲ្យក្អួចភាំងគ្រប់ ៗ គ្នា ។ ឆន្ទាចូលដល់ក្នុង ទៀបទៅទ្រុងនាងសារិកា ឆន្ទាឡៀងនេត្រា មើល ឆ្វេងស្តាំឃើញស្ងាត់ល្អ ។ បើកទ្វាសុវណ្ណ លូកហត្ថាហើយថ្នមទ្រ លើកយកសារិកាមក ដាក់ដល់ជិតជិតទុក ។ ដណ្តប់ឈួតជាហ៊ុម ពីក្រៅរុំទាំងសារិកា ហើយចុះបរយាត្រា វិលគាត្រាទៅភូមិបាន ។ រីឯនាងសារិកា កាលឆន្ទាចាប់បាន វិលទៅលំនៅឋាន ឲ្យនាងស្តីវា នឹងស្លាប់ ។ ហេតុនេះនាងសារិកា ពុំចរចារចែងសាសព្ទ ពុំហៅពុំស្រែក ប្រាប់ អ្នកដទៃឲ្យដឹងនាង ។ សម្ងំឲ្យឆន្ទា ថ្នមកាយាសព្វសព៌ាង្គ ឆន្ទា ដើរបំភាំង ហុចសារិកាឲ្យតាសី ។ ដោយនឹកក្នុងចិន្តា មានវាចាមិន

មេត្រី បង្គាប់ផ្ដល់តាសី ថាបានយកសារិកាទៅ ៗ ហោចពេមស្លាប់ចុំ
អេន ឲ្យលើនកុំឲ្យនៅ ហោចស្រេចបានយកទៅ កាប់ចិញ្ច្រាំសាច់ធ្វើន
វា ៗ ឲ្យល្អិតហើយខ្ទះ ឆ្អិនយកមកអញគោត្កា សងសឹកទីនខ្ទុនវា
គន់វេលានេះប្រញាប់ ៗ តាសីស្ដាប់វាថា ដែលឆ្នាបាឧបង្គាប់ ទើប
ធ្វើយ៉ាងប្រញាប់ តាប់សារិកាមិនប្រណី ៗ ឯនាងសារិកាសោត ពុ
ទៅក្រោធពុំប្រណី នាងភ្លេចភ្នាំងស្មាតី បន្ទិចមកគ្មារកាយា ៗ គិតថា
ខ្ទុនអញអើយ ទុក្ខទៀតហើយគួរអនិច្ចា មួងនេះស្លាប់អសារ រកអ្នក
ណាជួយពុំបាន ៗ រកស្ដេចៗពុំនៅ លើកទ័ពទៅឆ្ងាយទីបាន ទឹងហៅសុំ
គ្រប់ប្រាណ សឹងនៅឆ្ងាយហៅពុំឮ ៗ តាសីហោចចង្កា នាងសារិកា
ភ្ញាក់ព្រើតព្រឺ សាច់ស្បែកតើតធៀបឈើ ស្មើសេន្ទប់កាលនោះទៃ ៗ
ហោចប្រិបព្រើតព្រឺអង្គ ឈើស្រយង់គ្រប់សរសៃ ដលនេត្រនាងស្រីថ្វៃ
ស្រក់សស្រាក់ពុំស្រាកស្រាន្ត ៗ ឈើធៀបផ្សាអស់អង្គ ឡប់ឡិនឡង់
ទប់ពុំបាន ល្វើងល្វើយភ្លេចគន់ប្រាណ សន្ទប់ត្ញឹកភ្លេចអាត្មា ៗ កម្ម-
ព្រេងមកដល់មុន ក្រោយនោះបុណ្យភ័ព្វវាស្នា មកជួយនាងសារិកា
បន្ធើចិត្តមេតាសី ៗ ហោចរួចទុកប្រហែស ដើរក្រៅសេចុះទៅដី រក
បេះសុីកខ្ទុំម្ខុំ ធ្វើជាខ្ទួនញាំភ្ញា ៗ សារិកាកែវពិសី កាលតាសីវា
ដាក់នា ខាងអាងទឹកនោះណា នាងត្រដាក់ភ្ញាក់ជីងប្រាណ ៗ ប្រឹង

ប្រែបែរកាយា បើកនេត្រាមើលសព្វឋាន ស្ងើនស្ងាត់ពុំមាន មនុស្សម្នាម្នាក់នៅទីនោះ ។ នាងប្រឹងក្រោកឈរបាន ប្រែប្រឹងប្រាណឈានចំពុះ ចឹកចាប់នាបនោះ ទប់ខ្លួនដើរលើគ្រឹហា ។ ឈានមួនបានមួយជ្ញាប់ ឈើញរញាប់អស់អង្គា, សាច់ស្បែកផ្សាគ្រាំគ្រា ក្រកាយាយ៉ាងអនេក ។ កកិលមួយជ្ញាប់មួង ឃើញប្រហោងនោបញៀកប្រហជួបគេរ៉ែក នាងទំលាក់ខ្លួនចុះទៅ ។ ដល់ដីហើយនាងដើរឈានទីទើរតិចៗទៅ បានឃើញរូងមួយជ្រៅ ជារូងស្ដេចកណ្ដុរស ។ នាងចូលទៅលាក់ខ្លួន ជ្រកពឹងពួនកំបាំងល្អ ស្រេចហើយនាងបរក្រាបសម្រាន្តអង្គកាយា ។

គាថាម្ភសិកា: កជាបអំជិស្រុក គាប់កាលនោះសេនណារីឯស្ដេចកណ្ដុរស ។ ក្សាក្សាក់ពីទ្រោ ក្រោកលីលាត្រេចចេញចរនាំពលពាលស្មោះសរ ហែដើរលេងក្នុងរូងរន្ធ ។ បរិពារតាំង-ឈ្មោលញី ដើរហែមីអច្រើនពេកពន់ កណ្ដុរសគយគន់ មៀងមើលទៅយល់សារិកា ។ សំកុកសំកាំងក្រាប រកពេមស្ងាបគ្មានទៀយពណារលីងរងកាយា ជ្រកក្នុងរូងខ្លួនស្ងប្លោះ ។ ទើបស្ដេចកណ្ដុរសរពលររនៅទីងនោះ ស្ដាំងស្លួរកេឈ្មោះ ថាអ្នកនាងគឺឈ្មោះអ្វី ? ។

(នៅមានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## រឿងព្រេងជាកំណើតទំនៀមធ្វើពិធី

## សម្រាប់មនុស្សដើម្បីផ្តាច់គ្រោះ

លោក ថន-វន រៀបរៀង

តាមឯកសារនៃក្រុមជំនុំទំនៀមទម្លាប់

---

មានសេចក្តីដំណាលថា មានលោកគ្រូចៅអធិការមួយអង្គគង់នៅវត្តមួយ ជាអ្នកចេះចាំស្ទាត់នូវក្បួនតម្រាផ្សេង ៗ គ្មានចន្លោះ ។ នៅក្នុងកុដិលោកមានទូជាច្រើន សម្រាប់ដាក់ទុកនូវក្បួនតម្រាគ្រប់មុខ ។ បណ្តាសិស្សរបស់លោកទាំងអស់ មានសាមណេរមួយរូប ជាសិស្សជំនិត, លោកមានសេចក្តីរាប់អានសាមណេរនេះជាងសិស្សឯទៀត ។ ថ្ងៃមួយ លោកចង់ជ្រាបថា តើសាមណេរនេះ មានកម្មវាសនាដូចម្តេច? លោកក៏តាំងវាយលេខតាមវិធីក្បួនតម្រាផ្សេងៗទៅ ឃើញថា សាមណេរនេះនៅ ៧ ថ្ងៃទៀតត្រូវស្លាប់ទីងម្រឹត្យូវយក ។ កាលឃើញដូច្នោះ លោកគ្រូមានសេចក្តីតូចព្រះទ័យពន់ពេក ដោយនឹកករុណាដល់សាមណេរជាសិស្សនោះខ្លាំងណាស់ រួចហើយលោកហៅសាមណេរនោះមកប្រាប់ទាំងខ្សឹកខ្សួលថា នែនេន ! ឥឡូវអញបើកមើលក្បួនតម្រាផ្សេង ៗ

ទៅ ឃើញមានទំនាយថា នេនឯងនេះ ត្រូវស្លាប់នឹងម្រឹត្យូវយកក្នុងរវាង ៧ ថ្ងៃទៀត តើនេនឯងគិតដូចម្តេច ? ។ សាមណេរនោះក៏ដាក់មុខជ្រប់ ដោយគិតថា ក្បួនគម្ពីររបស់លោកគ្រូអញនេះទាយពិតណាស់ បើឃើញទំនាយយ៉ាងណា នឹងប្រាកដដូច្នោះចៀសពុំរួចទេ ហើយក៏ឆ្លើយតបទៅលោកគ្រូវិញថា ខ្ញុំព្រះករុណាពុំដឹងគិតដូចម្តេចទេ ព្រោះចៀសពុំរួចដដែល, ប៉ុន្តែណ្ហើយចុះខ្ញុំព្រះករុណាសូមលាព្រះតេជព្រះគុណដើរចេញពីវត្តនេះទៅ បើជួបនឹងម្រឹត្យូវយកត្រឹមណា ក៏ស្លាប់ត្រឹមនោះទៅចុះកុំឲ្យព្រះតេជព្រះគុណឃើញមុខ ព្រោះបើទុកជានៅក៏ស្លាប់ទៅក៏ស្លាប់ ។ លោកគ្រូមានពុទ្ធដីកាតាំងក្រៀមក្រំ ថា អើ ! តាមតែនេនឯងចុះ ។ រួចហើយ សាមណេរនោះ ក៏ថ្វាយបង្គំលាលោកគ្រូចេញពីវត្តទៅ ។

លុះសាមណេរចេញទៅដល់ពាក់កណ្តាលផ្លូវក្នុងព្រៃមួយ ក្នុងថ្ងៃទី ៧ ម្រឹត្យូវក៏មកស្រូបកាត់យកព្រះកេសសាមណេរនោះទៅ ។

ដូនជាក្នុងពេលនោះ មានព្រះឥសីមួយអង្គ ទើបចេញមកពីចង្ក្រមភាវនា និមន្តមកជួបម្រឹត្យូវបានក្បាលសាមណេរ ១ ដូច្នោះក៏សូមបិណ្ឌបាតយកពីម្រឹត្យូវ ។ ក៏ប្រគេនក្បាលសាមណេរនោះទៅព្រះឥសី ។ ព្រះឥសីកាលបើបានក្បាលហើយ ក៏រើសយកតាំងខ្លួនសាមណេរនោះមកផ្គុំ សែកមន្តប្រោះឲ្យរស់ឡើងវិញ ហើយនាំយកសាមណេរនោះ ទៅនៅឯ

អាស្រមរបស់លោក ។

ថ្ងៃក្រោយមក សាមណេរនោះមានសេចក្តីនឹករលឹកដល់លោកគ្រូ ព្រមទាំងញាតិញោមរបស់លោក ក៏សុំលាព្រះឥសីត្រឡប់មកវិញ ។ ព្រះឥសីក៏យល់ព្រម តែមុននឹងត្រឡប់មកវិញ ព្រះឥសីបានបង្ហាត់មន្តមួយសម្រាប់ព្រោះ ហើយផ្តាំថា "ត្រូវទៅបំពេញខ្លួនដល់វត្តតែម្តង កុំបង្អែបង្អង់ឡើយ ហើយវិជ្ជានេះកុំប្រើផ្តេសផ្តាស បើទុកជាឃើញសត្វអ្វីស្លាប់ក៏ដោយ" ។ លុះសាមណេរនោះ លាព្រះឥសីចេញកាត់មកដល់ពាក់កណ្តាលព្រៃ បានឃើញសាកសពខ្លាមួយស្លាប់ផុយរលួយអស់ នៅតែរាងឆ្អឹង នៅត្រង់មាត់រូងនៃនាគមួយ ។ ដោយការចង់ល្បងមើលវិជ្ជា សាមណេរនោះក៏សែកមន្តព្រោះខ្លានោះបានរស់ឡើង ។ កាលខ្លានោះរស់ឡើងវិញហើយ វាកើតចង់ស៊ីសាមណេរនោះវិញ ដោយវានឹងថាសាមណេរនេះ មកដាស់ពញាក់វាកំពុងដេកលក់ ។ សាមណេរថា អាត្មាមិនមែនពញាក់ទេ តាមការពិត គឺបងឯងស្លាប់ផុយរលួយអស់ទៅហើយ អាត្មាបានសង្គ្រោះព្រោះឲ្យរស់ឡើងវិញដោយករុណាតបឯងទេ ហេតុដូចម្តេចក៏គិតចង់ស៊ីអាត្មាដែលជាអ្នកមានគុណលើខ្លួននោះទៅវិញ ? ។ ខ្លាថា យើងមិនមែនស្លាប់ទេ យើងកំពុងដេកលក់ស្កប់ស្កល់ តែស្រមណ៍ចង្រៃឯងទេតើ ដែលមកពញាក់យើង រឿងនេះ យើងត្រូវតែ

ស៊ីស្រមណ៍ឯង ។ ក្រោយដែលបានដែកគ្នាយ៉ាងយូររួចហើយ, សាមណេរថា បើដូច្នោះ ត្រូវទៅរកចៅក្រមកាត់សេចក្ដីឲ្យបានដឹងខុសត្រូវសិន ទើបអាត្មាសុខចិត្ត ។ ខ្លានឹងសាមណេរនាំគ្នាដើរកាត់ព្រៃដើម្បីរកចៅក្រម ។

ចំណែកខាងព្រះឥសី ក្រោយដែលសាមណេរនោះចេញផុតមកលោកចេះតែពិបាកក្នុងចិត្តជាខ្លាំង លុះពិចារណាមើលទៅឃើញថា សាមណេរនឹងខ្លាកំពុងមានវិវាទនឹងគ្នាយ៉ាងសម្បើម រួចហើយព្រះឥសីក៏និមន្តដោយឫទ្ធិមកភ្លាម ទៅគង់ចាំនៅក្រោមដើមជ្រៃមួយដើម ដើម្បីជួយសង្គ្រោះសាមណេរ ។ ប្រហែលជាមួយសន្ទុះ បានឃើញសាមណេរនឹងខ្លាមកដល់ ។ អ្នកទាំងពីរក៏ថ្វាយបង្គំព្រះឥសីទូលតាមហេតុរៀងៗខ្លួន ។ ក្រោយដែលបានយល់ហេតុសព្វគ្រប់ហើយ ព្រះឥសីក៏មានវាចាថា ដើម្បីឲ្យច្បាស់រឿងនេះត្រូវយើងទៅពិនិត្យមើលដល់ទីកន្លែង ។ ខ្លានឹងសាមណេរក៏នាំព្រះឥសីត្រឡប់ទៅកន្លែងនោះវិញ ។ ព្រះឥសីក៏មានវាចាថា អើ! ចៅខ្លាឯងធ្វើទៅមើល! ដំណើរដូចម្ដេចមុនដំបូង? ។ ខ្លាក៏លូនចូលទៅដេកក្បែរមាត់រូងនាគនោះ ដើម្បីបង្ហាញព្រះឥសី ។ ឯនាគកាលបើដឹងថា ខ្លាចូលទៅជិតកន្លែងខ្លួនហើយ ក៏ព្រួសពិសមកចំលើខ្លានោះស្លាប់ពុកផុយរលួយដូចដើមវិញហោង ។

ព្រះឥសីបានស្តីបន្ទោសសាមណេរនោះជាច្រើន ព្រោះមិនព្រមស្តាប់បណ្តាំរបស់លោក រួចហើយ ព្រះឥសីបាននាំសាមណេរនេះដោយឫទ្ធិមកដាក់ក្បែរវត្ត ហើយត្រឡប់ទៅកាន់អាស្រមវិញ ។

ឯលោកគ្រូចៅអធិការ តាំងអំពីសាមណេរជាសិស្សលាចេញទៅពេលណា លោកមានព្រះទ័យព្រួយជាខ្លាំង ដោយទឹកអាណិតដល់សាមណេរជាសិស្សនោះ ចេះតែនឹកមមៃមកល់ថ្ងៃមិនដែលដាច់សោះ ។

ពេលរសៀលថ្ងៃមួយ លោកចេញមកគង់នៅពនហាលខាងមុខកុដិ ដើម្បីលំហើយការតានតឹងក្នុងព្រះទ័យរបស់លោក, កំពុងតែទន្ទឹង ស្រាប់តែឃើញសាមណេរនោះនិមន្តមកដល់ខ្លោងទ្វារវត្ត, ដោយសេចក្តីទឹកខ្លាំងពេក លោកក៏ស្ទុះចុះទៅទទួលសាមណេរនោះយ៉ាងរួសរាន់ព្រមទាំងសួរយ៉ាងប្រញាប់ប្រញាល់ថា ចុះថាម្រឹត្យរ៉ៃយកម៉េចក៏មកវិញ ? ។

ខ្ញុំព្រះករុណាមិនស្លាប់ទេ ! ( សាមណេរឆ្លើយ ) ។

លោកគ្រូខ្វល់ណាស់មានពុទ្ធដីកាថា អាក្បួនតម្រានេះយកជាការមិនបានទេ មើលឃើញថាត្រូវស្លាប់ ឥឡូវបែរជានៅរស់ទៅវិញ អ្នកណានាំធ្វើក្បួនតម្រានេះសុទ្ធតែកុហកទាំងអស់ ហើយលោកឲ្យយកក្បួនតម្រានោះទៅដុតភ្លើងចោល ។

សាមណេរឃើញដូច្នោះ ក៏ទូលលោកគ្រូចៅអធិការថា តម្រានេះ

មិនខុសទេ សូមឈប់សិនកុំអាលដុត ខ្ញុំព្រះករុណាត្រូវម្រឹត្យូវយកមែន ដែលរស់មកវិញនេះ ដោយសារព្រះឥសីលោកប្រោះឲ្យរស់ , បន្ទាប់មក សាមណេរនោះក៏រៀបរាប់តាមដំណើរ ។

លោកគ្រូក៏ប្រើក្មេងឲ្យទៅយកគម្ពីរពីក្អក់ភ្លើងមកវិញ មានឆេះខ្លះ នៅសល់ខ្លះ រួចហើយលោកចាត់ឲ្យចម្លងជាថ្មីឡើងវិញ ទុកតមកដល់សព្វថ្ងៃនេះ ។

ដោយហេតុនេះទើបក្បួនតម្រាសព្វថ្ងៃនេះពុំសូវទៀងទាត់ដូចកាលមុនព្រោះមានហេតុដូចរៀបរាប់មកនេះ ។

មានចំនៀមមួយទៀត អំពីពិធីចាប់មនុស្សយកទៅសម្លាប់ (១) ធ្វើទបទេសដើម្បីផ្តាច់គ្រោះ ក៏មានជាប់មកដោយអនុលោមតាមរឿងព្រេងនេះដែរ (គ្រង់ព្រះឥសីសុំបិណ្ឌបាតក្បាលសាមណេរអំពីម្រឹត្យូវយកមកប្រោះឲ្យរស់ឡើងវិញ) បានជាកាលណាបើមនុស្សណាម្នាក់ នៅសុខៗទេ តែគេមើលទៅឃើញដូចជាកំបុតក្បាល ។ គេត្រូវមត់គ្នាធ្វើពិធីចាប់មនុស្សនោះយកទៅសម្លាប់ដើម្បីផ្តាច់គ្រោះ , បើពុំធ្វើដូច្នោះទេ , ទឹង

---

១– តាមសេចក្តីឲ្យការណ៍ពីលោក ជឹម-ឈុំ សមាជិកឆ្លើយឆ្លងនៅឃុំឫស្សីព្រៃ ស្រុកសណ្តាន់ កំពង់ធំថា: បើមិនបានដល់ទៅរៀបចំធ្វើពិធីសម្លាប់ទេ គ្រាន់តែក្មេងបោទឲ្យភ័យដោយហេតុអ្វីមួយ ក៏សន្មតថាផ្តាច់គ្រោះដែរ ។

បណ្ដាលឲ្យមានគ្រោះថ្នាក់ ដូចជាខ្លាខាំ ពស់ចឹក ខ្ទុះបាញ់ នឹងធ្លាក់ពីចុងឈើជាដើម ។

ឯពិធីនោះ គឺ បើឃើញច្បាស់ថា មនុស្សនោះកំបុតក្បាលហើយ គេត្រូវប្រជុំអ្នកស្រុកទៅតាមចាប់ ដោយក្លែងយកហេតុអ្វីមួយទៅបំភ័យ, រីឯមនុស្សដែលនៅជាមួយមនុស្សនោះទាំងប៉ុន្មាន ក៏គេឥតប្រាប់ឲ្យដឹងដែរ ។ កាលណាគេចាប់បានហើយ គេនាំសំដៅទៅរកទីប៉ាធា ហើយគេនិយាយពាក្យគំហកកំហែងផ្សេងៗ ថា នឹងយកទៅសម្លាប់ក្នុងទីប៉ាធា, ត្រូវចាត់មនុស្សខ្លះទៅនិមន្តព្រះសង្ឃចំនួន ៤ ៥អង្គ ឬតែ ១អង្គ ២អង្គក៏បាន ឲ្យទៅគង់ចាំនៅទីប៉ាធានោះមុន (បើគ្មានព្រះសង្ឃត្រូវរកអាចារ្យណា ម្នាក់ក៏បាន) កាលណាគេនាំមនុស្សនោះទៅដល់ហើយ គេឲ្យអង្គុយបែរមុខទៅទិសបូព៌ា ប្រាប់ឲ្យភាវនាធម៌ (ពុទ្ធគុណត្រង់បទណាមួយក៏បាន) ហើយគេយកដើមចេកប្រវែងល្មមលើសពីក្បាលអ្នកទោស ដែលអង្គុយនោះប្រហែលមួយហត្ថ ដាក់បញ្ឈរពីក្រោយខ្នង ហើយគេស្រែកហោ ៣ ដងរួចហើយ គេយកដាវកាប់កាត់ផ្ដាច់ដើមចេកពីលើក្បាលមនុស្សនោះបន្តិចចេញទៅ ហើយគេច្រានផ្ទួលមនុស្សនោះឲ្យផ្កាប់មុខបន្តិចទៅដែរ ដោយគេនិយាយខបកិច្ចថា "សម្លាប់រួចហើយ! ស្លាប់ហើយ!" ។ ឯព្រះសង្ឃឬអាចារ្យដែលនៅក្បែរនោះ កាលបើឮគេ

និយាយពាក្យឧបកិច្ច ឬឧបទេសយ៉ាងនេះហើយ ត្រូវសួរគេៗ (១)និងប្រាប់តាមដំណើររួចហើយ ត្រូវសុំបិណ្ឌបាតយកសាកសពមនុស្សដែលគេសម្លាប់នោះ ។ អ្នកសម្លាប់ត្រូវតែប្រគេនទៅព្រះសង្ឃឬអាចារ្យនោះកុំខាន ។ ឯអ្នកដែលត្រូវគេសម្លាប់ ត្រូវងើបឡើងថ្វាយបង្គំព្រះសង្ឃឬអាចារ្យទទួលសីលរួចហើយ ព្រះសង្ឃឬអាចារ្យត្រូវសូត្រករតុ បាចទឹកឲ្យហើយឲ្យឈ្មោះ (២)ជាថ្មីទៀត ។

ឯវត្ថុដែលត្រូវមានក្នុងពេលធ្វើពិធីនោះ គឺ ស្លាធម៌១គូ ទៀន ធូប បារី ស្លា សម្រាប់ប្រគេនលោកឬជូនអាចារ្យ, ដើមចេកមួយកំណាត់សម្រាប់ធ្វើរូបស្អង, ទឹកមួយផ្តិលសំរាប់ព្រះសង្ឃសូត្របាចទឹក និងដាវ១សម្រាប់កាប់ ។

ពេលដែលត្រូវធ្វើគឺ ពេលព្រលប់ជាដើមទៅ ។

ឯពិធីទាំងនេះ លោក ជីម-ឈុំ បានឲ្យការណ៍ថា លោកបានឃើញគេធ្វើផង ធ្លាប់ធ្វើផ្ទាល់ខ្លួនលោកជាមួយនឹងអ្នកស្រុកនៅភូមិជាមួយគ្នាផង ។

---

១ សួរថា ចុះអស់លោកមកទីនេះទាំងយប់អធ្រាត្រមានការអ្វី ?, យើងខ្ញុំតាមមនុស្សនេះមកសម្លាប់, – សុំជានាកុំឲ្យសម្លាប់, ណានាម្តេចបានបើសម្លាប់រួចទៅហើយ (និយាយពាក្យឧបទេស) ។

២ ដូចជាមនុស្សឈ្មោះសុខ ដល់គេធ្វើពិធីសម្លាប់រួចហើយ គេដាក់ឈ្មោះសៅទៅវិញជាដើម ដោយគេឧបទេសថា រូបនឹងឈ្មោះមុននោះ ទុកដូចជាស្លាប់បាត់បង់ទៅហើយ ឯរូបនឹងឈ្មោះក្រោយនេះ ទើបនឹងកើតថ្មី ។

# រឿងព្រេងនឹងរឿងបុរាណជប៉ុនក្នុងមធ្យមសម័យ

(តមក)

*លោក ពីយ-ប៊ុក ប្រែរៀបរៀង*

## រឿងលោករ៉ាតាណាបេណ្ឌូស៊ុណា និងនាងអាប

*សម័យមួយ ពលរដ្ឋក្នុងក្រុងគិយ៉ូតូ (ប្រទេសជប៉ុន) បាននាំគ្នាតែស្លន់ស្លោភ័យតក់ស្លុតឥតឧបមា ដោយបានឮដំណឹងថា មាននាងអាបមួយបានពិឃាដមនុស្សម្នាក់ពីពេលព្រឹក ៗ មានមនុស្សជាច្រើន ប្រជុំគ្នាតាមវិថីទាំងឡាយ ជជែកគ្នាពីព្រឹត្តិការណ៍នេះ ដោយពោលថា :*

*"គួរឲ្យខ្លាច គួរឲ្យតក់ស្លុត .... រាល់ថ្ងៃនាងអាបតែងសម្លាប់មនុស្ស..,ក្នុងកាលកន្លងមកបីខែហើយ--តើនាងអាបសម្លាប់មនុស្សប៉ុន្មាននាក់ហើយ.... នាងអាបនេះ វានៅក្នុងសេនជិតមាត់ទ្វារក្រុងគិយ៉ូតូ ។*

*មនុស្សម្នាក់សួរថា តើអ្នកឯងធ្លាប់បានឃើញរូបនាងអាបនោះទេ?។*

*–ខ្ញុំមិនដែលបានឃើញទេ , តែក្មួយខ្ញុំម្នាក់បានឃើញ ហើយវាបានប្រាប់ខ្ញុំថា :*

*«នាងអាបនេះ មានមាឌគួរស្បើមពេកណាស់, មុខវាពណ៌ប្រផេះដូចពណ៌ដី សក់គគ្រើងសើងម៉ើង ភ្នែកស្លាំងសំឡឹងទៅលើ ភ្នែកម្ខាងតូច! សំឡឹងមកក្រោម , ច្រមុះធំមូររមួលគ្នា មាត់ធំប្រវាប បបូរមាត់*

ក្រាស់ក្រហមដូចប្រឡាក់ឈាម ; កាលណាមានមនុស្សដើរទៅជិតស៊ើននោះ ចង់ចូលឬចេញពីទីក្រុង . នាងអាបនោះយារដាវគ្រវីលោតទៅសង្គ្រប់កាប់មនុស្សនោះ ឲ្យរបួសឬស្លាប់មួយរំពេច, ជួនកាលវាហោះទៅលើអាកាស ស្វែងរកវំពារបស់វាដែលវាកាប់ឲ្យរបួស បើឃើញនៅទីកន្លែងណា វាលោតចុះទៅសង្គ្រប់ពីលើ ចាប់យកមកជាអាហារដូចគ្នា..,ហើយរឿងនេះខ្ញុំបានសួរអ្នកជិតខាងម្នាក់ថា «តើអ្នកឯងបានដឹងទេហេតុអ្វីបានជានាងអាបនេះស្អប់មនុស្សខ្លាំងម្ល៉េះ?» ។ អ្នកនោះបាននិយាយថា បានជាវាស្អប់មនុស្ស ព្រោះវាមានចិត្តលំបាកជាខ្លាំង ដោយសារតែមានរូបអាក្រក់. ហើយមនុស្សគេបោះបង់ចោលវា ជួនកាលមានមនុស្សនិយាយពាក្យចំអកឡកឡឺយឲ្យវាឈឺចិត្ត វាមានបំណងចង់បានបុរសជាស្វាមី ប៉ុន្តែ គ្មានបុរសណាអាចហ៊ានចូលមកដណ្តឹងវាសោះ ។ ម្យ៉ាងទៀតនាងអាបនេះវាអាចកាឡាខ្លួនជាស្ត្រីមានរូបស្អាតគួរពិស្វយក៏បាន ប៉ុន្តែវាមិនកាឡាខ្លួន ព្រោះមានបំណងចង់ឲ្យគេស្នេហាខ្លួនវាដោយរូបកាយធម្មជាតិដូច្នេះ ហើយមិនបានសម្រេចដូចបំណង ទើបវាធ្វើអំពើកាចសាហាវចំពោះមនុស្ស ដែលព្រងើយកន្តើយចំពោះខ្លួនវា » ។

មនុស្សទាំងនោះ ក៏ពាំគ្រោះគ្នាដោយព្រួយបារម្ភថា: តើអ្នកណាហ្ន៎! អាចជួយស្រោចស្រង់យើង ឲ្យរួចពីកណ្តាប់ដៃរបស់នាងអាបនោះបាន ។

ថ្ងៃក្រោយមក ស្តេចត្រាញ់ទៅក្នុងក្រុងតិយ៉ូត្ត ទ្រង់បានប្រមូលពួកយោធាទាំងឡាយ ហើយទ្រង់មានបន្ទូលថាៈ លោកអ្នកបានដឹងហើយថា មាននាគអាចមួយនៅខាងមុខខ្លោងទ្វារក្រុងតាំងពីយូរខែមក ហើយបានសម្លាប់មនុស្សក្នុងទីក្រុងជាច្រើន ក៏មិនឲ្យអ្នកណាចេញពីទីក្រុង ឬចូលមកក្នុងក្រុងបានឡើយ ក៏តែងកាន់ដាវត្រីលោកទៅកាប់មនុស្សឲ្យរបួសឬស្លាប់មិនខាន, យើងមិនអាចទុកស្ថានការណ៍បែបនេះឲ្យកើតនៅតទៅទៀតទេ ត្រូវតែកំចាត់វាចេញ, ខ្ញុំមានបំណងចង់រកយោធាក្លាហានម្នាក់ ដែលអាចតយុទ្ធនឹងវាបាន បណ្តាលោកអ្នកជាមេយោធាទាំងឡាយ តើអ្នកណាអាចទទួលការៈបែបនេះបាន ? ។

ក្រោយដែលមានការស្ងប់ស្ងៀមមួយស្របក់ មានមេយោធាម្នាក់ឆ្លើយថា " ទូលបង្គំ ! " ។ មេយោធាទាំងអស់ក៏ក្រឡេកមើលទៅបុរសយុវ័ន ដែលទើបនឹងក្រាបបង្គំទូលតបព្រះអង្គ ។

បុរសនេះ ជាមេយោធាមានឈ្មោះល្បីល្បាញថាជាអ្នកក្លាហាន មាននាមថា លោកក៏តាណាបេណ្ឌូស៊ុណា ។

ស្តេចត្រាញ់ ទ្រង់មានព្រះបន្ទូលតបទៅលោកក៏តាណាបេណ្ឌូស៊ុ-ណាថា « យើងអរគុណជាអនេកប្បការ, ព្រឹកស្អែក អ្នកត្រូវចូលទៅតយុទ្ធនឹងនាគអាចកុំខាន» ។

លុះពេលព្រឹក លោកក៉តាណាបេណូស៊ុណា ក៏ចេញទៅតាមខ្លោងទ្វារខាងជើងនៃទីក្រុងគិយ៉ូតូ ។

មេយោធានេះ មានមាឌធំ ស្គម មុខមានសម្បុរដូចលង្ហិន តែក្នុងពេលស្មើខ្មាំងធាបនេះ ចិញ្ចើមញាក់ម្តង ៗ ធ្មេញសង្កៀតរណ្តំគ្នា, ពាក់គ្រឿងក្រោះធ្វើពីដែកថែប ពាក់ស្រោមដៃធ្វើពីស្បែកមានពាសដែក ពាក់មួកដែករុំកញ្ចឹងកជិត, កាន់ដាវវែងមួយនៅដៃ, ពេលនោះ គាត់ក៏គិតមកដល់កូនប្រុសដែលមានអាយុ ៨ ឆ្នាំថា អញប្រហែលជាលែងឃើញមុខកូនហើយ ប្រសិនបើអញត្រូវស្លាប់ក្នុងពេលតស៊ូនឹងនាងអាបនេះ, ប៉ុន្តែ អញអាចទុកអនុស្សាវរីយមួយដ៏ត្រកាល ប្រកបដោយការល្បីល្បាញនៅក្នុងចិត្តនៃកូនអញដែរ ។

ពេលនោះ នាងអាប លុះក្រឡេកឃើញមេយោធាកំពុងដើរមកចំមុខខ្លួនដូច្នោះ មានចិត្តត្រេកអរឥតឧបមា ដោយនឹកក្នុងចិត្តថា "បុរសនេះ ត្រូវបានជាចំណីអញឥឡូវនេះហើយ" គិតស្រេច នាងអាបបើកទ្វារសើច កាន់ដាវគ្រវីដោយសេចក្តីក្លាហាន រង់ចាំមេយោធានោះ, នាងអាប ភ្លាមតែគ្រវីដាវហើយ មនុស្សដែលដើរមកកាន់ទីនោះក៏ភ័យតក់ស្លុតរត់ខ្ចាត់ខ្ចាយ ៗ ផ្ទុយទៅវិញ លោកក៉តាណាបេណូស៊ុណានេះឥតតក់ស្លុតសោះ ស្រាប់តែលោតដោយការបញ្ចេញស្នៀតយ៉ាង

រហ័សដូចព្រួញទៅតាមលោសាស្ត្រដ៏ឆ្មើម គេចផុតផុតពីមុខដាវនាងកាប ហើយស្ទុះទៅកាប់ដៃស្តាំនាងកាបដាច់ធ្លាក់ចុះ ហូរឈាមសស្រាក់មួយរំពេច ។

នាងកាបឈឺឈ្ងួលខ្លាំង រត់ចូលទៅក្នុងសេនវិញស្រែកទ្រហោយំៗ

លោកពាំតាណាបេណ្ឌូស៊ីណា ទៅរើសកំណាត់ដៃស្តាំនាងកាបយកសំពត់ព្រែរុំខ្ចប់ឲ្យស្អាត វិលមកផ្ទះវិញ ហើយលោកនឹកក្នុងចិត្តថា « តើកូនប្រុសរបស់អញមានចិត្តសប្បាយយ៉ាងណាទៅ ដល់វាដឹងថាឪពុកវាមានសេចក្ដីក្លាហាន កាប់បានដៃនាងកាបនោះ! ប្រហែលជាវាចង់ដឹងនូវការតស៊ូឪពុកវាចំពោះនាងកាបទេដឹង ! » ។

លុះមកដល់ផ្ទះភ្លាម, កូនប្រុសនឹងកូនស្រីរបស់លោក នាំគ្នារត់ត្រសងទៅទទួលឪពុក មានចិត្តត្រេកអរយ៉ាងខ្លាំងអង្វរឪពុកថា សូមប៉ាបង្ហាញដៃស្តាំនាងកាបឲ្យកូនឃើញផង កូនចង់ឃើញណាស់! ហើយសូមប៉ាបង្ហាញឲ្យប្អូនស្រីឃើញផង ព្រោះអូនចង់ឃើញណាស់ដែរ ។

លោកពាំតាណាបេណ្ឌូស៊ីណា ញាក់ចិញ្ចើម ហើយតបទៅកូនលោកវិញថា ទេ, កូន! ឪពុកបានប្ដេជ្ញាក្នុងចិត្តថា មិនបង្ហាញដៃកាបឲ្យនរណាឃើញឡើយ ។

បន្តិចមក ភរិយាលោកក៏ចូលមកដល់ ឃើញស្វាមីនៅម្នាក់ឯងក៏

អង្វរស្វាមីថា សូមបងមេត្តាបង្ហាញដៃអាបឲ្យប្អូនឃើញផង ដៃដែលជាកស្តុតាងនៃសេចក្តីក្លាហានរបស់បង ។ នាងជាភរិយា បើទុកជាទទូចអង្វរស្វាមី ដោយពាក្យផ្អែមល្ហែមយ៉ាងណា, ក៏ស្វាមីនាងមិនព្រមបង្ហាញដៃនាងអាបជាដាច់ខាត ។

លុះពេលរសៀល មានយាយចាស់ម្នាក់មកសុំជួបនឹងលោកព៏តា-ណាបេណ្ឌស៊ុណា ។ យាយចាស់នេះ គឺជាម្តាយមីង ដែលបានថែរក្សាលោកតាំងពីតូច ព្រោះលោកជាកូនកំព្រាតាំងពីនៅជាទារកនៅឡើយ, គាត់ពាក់អាវវែងមានសម្បុរស្រអាប់ មានមុខសក់ដូចភ្លុក ទឹកមុខស្លូតបូត តែដូចជាព្រួយចិត្តបន្តិច។ លុះបានជួបនឹងលោកព៏តាណាបេណ្ឌស៊ុណា គាត់ទៅជាមានទឹកមុខរីករាយទៅវិញ ដោយបានជួបនឹងក្មួយគាត់ ហើយក៏សរសើរថា:-

មីងបានដឹងថា ឯងទទួលនូវជោគជ័យយ៉ាងប្រសើរ ពីពេលព្រឹកមិញ មនុស្សដែលនៅក្នុងសង្កាត់ភូមិមីង បានសរសើរពីសេចក្តីក្លាហានរបស់ក្មួយ, ឯមីងមកសូមសរសើរសេចក្តីក្លាហានរបស់ក្មួយ សរសើរដោយស្មោះស្ម័គ្រ, មីងមានសេចក្តីត្រេកអរចំពោះក្មួយ ដែលបានសម្រេចនូវកល្យាណកិច្ចដ៏ប្រសើរនេះ ។

លោកព៏តាណាបេណ្ឌស៊ុណា ក៏ឱនក្បាលគោរពចំពោះម្តាយមីង ដែលលោកទុកដូចជាមាតាបង្កើត ហើយតបទៅម្តាយមីងថា:-

ខ្មើងអើយ ! មើងចិត្តល្អទើងខ្ញុំណាស់ ពិតមែនតែគ្មានពេលចំនេរមកលេងនឹងខ្ញុំ ប៉ុន្តែ មើងចាំឆ្លៀតឱកាសមកជួបនឹងខ្ញុំៗ មានសេចក្តីត្រេកអរណាស់ ។

ម្តាយមើងក៏ពោលថា នែកូយ ! កូយអាណិតមេត្តាមើង ... មើងសូមឱ្យកូយបង្ហាញនូវដៃនាងអាបនោះ តើមានសភាពបែបណាទៅ! មើងចង់ពាល់ដៃនាងអាបនេះ សូមកូយកុំប្រកាន់ចំងង ។

លោកព្រឹតាណាបេណ្ឌូស៊ីណា មានចិត្តញ្ញាក ហើយពោលតបថា លោកមើង! ខ្ញុំបានមិនព្រមបង្ហាញដៃនាងអាបនេះឲ្យគេយាបុត្រាបុត្រីខ្ញុំឃើញសោះ, ខ្ញុំបានប្តេជ្ញាថា នឹងមិនបង្ហាញដៃនាងអាបនេះឲ្យនរណាឃើញសោះ តែចំពោះលោកមើងជាទីស្រឡាញ់របស់កូយ ខ្ញុំទុកលោកមើងដូចជាមាតារបស់ខ្ញុំ ព្រោះលោកមើងបានបីបាច់ថែរក្សាខ្ញុំតាំងពីតូចមក ។ ខ្ញុំមិនអាចនឹងមិនឲ្យលោកមើង ឃើញដៃនាងអាបនោះសោះឡើយ, ករណីយនេះ គឺត្រូវតែខ្ញុំបង្ហាញឲ្យលោកមើងឃើញដោយមិនសង្ស័យ ... ។

លោកព្រឹតាណាបេណ្ឌូស៊ីណា បាននិយាយថា កុំឲ្យអ្នកណាចូលក្នុងបន្ទប់នេះជាដាច់ខាត រួចលោកដើរទៅយកដៃនាងអាបមកស្រាយកំណាត់សំពត់សូត្រដែលរុំនោះចេញ ។

ពេលនោះ ម្តាយមើងលោកយកដៃថ្នេងឈោងចាប់ដៃអាប ក៏ព្រឺពោម ព្រឺស្បែក ជាខ្លាំង ហើយពោលថាៈ-

មីងមានចិត្តក្រេកអរពន់ពេក ដោយបានឃើញដៃគាបនេះ ។

លោកភីតាណាបេណ្ឌស៊ុណា បើកភ្នែកធំមើលចំទៅម្ដាយមីងលោក ៗ បានឮសូរសម្លេងអំបាញ់មិញនេះ ហាក់ដូចជាមិនមែនសូរសម្លេងម្ដាយមីងលោក ព្រោះសម្លេងនេះមានសភាពប្លែកពីធម្មតា ។

គង់ពេលមួយរំពេចនោះ មុខម្ដាយមីងលោក ក៏ទៅជាមុះប្រផេះ មានធ្មេញ គគ្រាតគគ្រើមគួរឲ្យស្អប់ខ្ពើម ប្រមុះយឺតវែងរមួលគ្នា ភ្នែកស្ដាំរីកធំបើកពាញទៅលើ ភ្នែកឆ្វេងតូចបើកពាញទៅក្រោម... ។

លោកភីតាណាបេណ្ឌស៊ុណា ក៏សង្ស័យ ហើយដឹងច្បាស់ថាស្រីនេះ មិនមែនជាម្ដាយមីងលោកទេ គឺនាងគាបនោះទៅវិញ... នេះគឺជាឧបាយរបស់នាងគាប ដើម្បីឲ្យបានដៃយកទៅវិញប៉ុណ្ណោះ ។

លោកមេយោធាឥតនិយាយអ្វីមួយម៉ាត់ឡើយ លោកក៏ស្ទុះចេញទៅយកដាវ ដល់លោកវិលត្រឡប់មកវិញ, ស្រីនោះក៏បាត់ពីទីនោះទៅ ទ្វារផ្ទះរបស់លោកចំហ លោកស្ទុះទៅមើលតាមទ្វារនោះ ស្រាប់តែឃើញនាងគាបហោះយ៉ាងលឿនកណ្ដាលអាកាស មានដៃតែមួយ ហើយកាន់ដៃស្ដាំរបស់វាមានពណ៌ក្រហម, ខ្លួនវាពាក់អាវវែងមានពណ៌ប្រផេះ ។

ចប់រឿងភីតាណាបេណ្ឌស៊ុណានឹងនាងគាប

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤១

ឧកញ៉ាវិបុលរាជសេនា ង៉ូ-កង ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសត្តានៈស្នេហាជាតិ។

ប៉ាំងថង់ឆ្លើយថា ខ្ញុំបាទមករកលោកនេះ មិនមែននឹកឃើញដល់បណ្ដាស័ក្ដិទេ ព្រោះគំនិតករុណាប្រជានុរាស្ត្រនឹងឲ្យជាសុខ ប្រសិនបើលោកបានស្រុកកាំងតាំងហើយ សុំកុំសម្លាប់ញាតិបងប្អូនខ្ញុំបាទដែលនៅក្នុងស្រុកនោះឡើយ ។

ចូធូថា ខ្ញុំធ្វើការសឹកសង្គ្រាមនៅទីណាដំបន់ណាក្ដី មិនមែននឹងឲ្យរាស្ត្របានសេចក្ដីក្ដៅក្រហាយសោះឡើយ គិតតែបំរុងឲ្យបានសេចក្ដីសុខថែមទៀត ដែលខ្ញុំឲ្យកាប់សម្លាប់ខ្លះនោះ ព្រោះតែមនុស្សនោះរឹងទទឹង បើប្រសិនជាអ្នកខាងក្រុងញាតិបងប្អូនអន្ដរាយ ខ្ញុំនឹងធ្វើសំបុត្រទៅ

ឃុំក្បាលទុកជាសំគាល់ ៗ ប៉ាំងចងធ្វើជាត្រេកអរទុនគំនាប់ហើយថា បើមហាឧបរាជអាណិតមេត្តាឲ្យសំបុត្រទៅឃុំក្បាលទុក ខ្ញុំបាទក៏អស់សេចក្តីវិតក្កទុក្ខព្រួយ ៗ ចួចក៏តែងសំបុត្រឲ្យ ៗ ប៉ាំងចងក៏ទទួលយកសំបុត្រហើយផ្តាំនឹងចួចទុកថា បើខ្ញុំបានទៅហើយឲ្យមហាឧបរាជខំប្រញាប់ចាត់ចែងកងទ័ពទៅច្បាំងនឹងដីវយ៉េជាមុន កុំចាំឲ្យដីវយ៉េមកដាន់ ហើយប៉ាំងចងក៏លាចួចចេញមកចុះទូក ៗ

ខណៈនោះឈើស៊ីដែលនៅជិតទីនោះ ក៏ស្ទុះទៅចាប់ជាយអាវប៉ាំង-ចងទុកហើយទទួលខ្សឹបថា ខ្លួនអ្នកនេះអង់អាចណាស់ ខ្លាចជាក្រែងនោះនេះមិនអស់ទាហានចួចថ្មី បានជាក្រែងគិតជាកលឧបាយមកបញ្ឆោតចួចឲ្យចងក្បួនទូកចម្បាំងទុកទៀត ប្រាថ្នានឹងឲ្យជុតទាហាននឹងទូកចម្បាំងចេញឲ្យអស់លើងតែម្តងថ្ម ដែលជម្រះរិះគិតរបស់អ្នកនោះនឹងមិនយល់ចុះបានតែចួច ១ ឯខ្លួនខ្ញុំអាចដឹងដល់ទាំងអស់ ៗ ប៉ាំងចងឮដូច្នោះក៏តក់ស្លុតភ័យរន្ធត់ស្មារតី ក្រឡេកមើលមកក្រោយក៏ឃើញឈើស៊ីតែម្នាក់ឯង ក៏ដូចជាធូរទូលាយក្នុងចិត្ត ព្រោះឈើស៊ីជាគឿនសម្លាញ់ស្និទ្ធនឹងគ្នាមកពីក្មេង ហើយជាដែលខ្ញុំរិះគិតមកនិយាយនឹងចួចនេះ ព្រោះស្តាយស្រុកកាំងតាំងជាខេត្រឯក ហើយមានខេត្រឡើងដល់ ៨១ មណ្ឌល ក្រែងមានអន្តរាយ ទាំងប្រជានុរាស្ត្រចំណុះស្រុកក៏នឹងដល់នូវសេចក្តីស្លាប់ទាំងអស់គ្នា បានជាខ្ញុំ

មកបញ្ឆោតប្អូន ប្រាថ្នានឹងជួយជីវិតអ្នកស្រុកទាំងអស់ឲ្យរស់នៅ ។ ឈីស៊ីក៏ធ្វើជាតបថា ខ្លួនអ្នកមានចិត្តអាណិតស្ដាយពួកស្រុកកាំងតាំងខ្លាចអន្តរាយ ទើបមកខ្វល់ខ្វាយទំរំរិះគិតឲ្យបានការយ៉ាងនេះ ចុះទាហានប្អូនដល់ ៨៣ ម៉ឺននោះ អ្នកគ្មានចិត្តអាណិតថានឹងដល់នូវសេចក្ដីស្លាប់ទាំងអស់ទេឬ ? ។

ប៉ាំងថងថា ការទាំងអម្បាលនេះ មិនមែនជាការរបស់ស៊ុនគួនតែម្នាក់ឯងទេ គឺជាការរបស់ទៀវពីចៅហ្វាយបាស់អ្នកនោះដែរ ដែលអ្នកថាដូច្នេះមុះជាយកសេចក្ដីដែលខ្ញុំរិះគិតនេះ ទៅប្រាប់ប្អូនឲ្យដឹងមុនឬ? ។ ឈីស៊ីតបថា ដែលខ្ញុំបានផុនខ្លួនមកនៅនឹងប្អូនដូច្នេះ គឺមកដោយសេចក្ដីជាចិត្ត លុះមាតាខ្ញុំស្លាប់ទៅ ខ្ញុំក៏មានចិត្តនឹកខឹងនឹងប្អូនដកពបសព្វថ្ងៃនេះ ខ្ញុំក៏មានចិត្តលើកកាល័យទៀវពីមិនគេចសោះ ព្រោះគិតដល់គុណទៀវពីដែលមានមកពីដើម កាលដែលនឹងឃ្លាតចាកមកក៏បានស្បថស្បែទុកនឹងទៀវពីថា បើមកនៅទីតានេះក្ដី ក៏មិនបានប្រាប់កលសឹកអ្វីមួយឲ្យប្អូនដឹង ឥឡូវខ្លួនអ្នកក៏បានរិះគិតនឹងដុតទ័ពប្អូនឲ្យអស់ ហើយនឹងចង់ដុតទាំងខ្លួនខ្ញុំផងទៀតឬ ? ។ ប៉ាំងថងថា ហេតុម្ដេចអ្នកមកចរចាដូច្នេះ ឯធម្មតាអ្នកមានដម្រេះប្រាជ្ញា បើមានភ័យមកដល់ខ្លួនហើយ មិនគិតនឹងយកខ្លួនឲ្យរួចក៏មិនហៅថាជាអ្នកមានប្រាជ្ញាបាន ហើយប៉ាំងថងក៏លាចុះទូកទៅ ។

ឯឈឺស៊ី លុះបាំងចង់ទៅហើយក៏គិតថា បើយើងនៅក្នុងទ័ពបូចូ
គទៅ ក៏គង់ទីងបានសេចក្តីលំបាកវេទនា គួរតែមានប្រែប្រួលគិតឲ្យរួច
ភ័យ ទើបប្រើមនុស្សស្និទ្ធស្នាលឲ្យដើរទៅនិយាយឮល្បីថា មានអ្នក
ដំនួញមកប្រាប់ដំណឹងថា ម៉ាថេងទីងហ៊ានស៊ុយដែលនៅស្រុកសេលៀង
នោះ ទីងលើកកងទ័ពមកវាយយកស្រុកហ៊ូតោ ។ បណ្តាទាហានបូចូដឹងឮ
ល្បីថា មានអ្នកដំនួញមកប្រាប់ដំណឹងថា ម៉ាថេងទីងហ៊ានស៊ុយដែលនៅ
ស្រុកសេលៀងនោះ ទីងលើកកងទ័ពមកវាយយកស្រុកហ៊ូតោ បណ្តា
ទាហានបូចូដឹងឮដូច្នោះក៏ព្រួយចិត្ត ក៏ភ័យគិតដល់គ្រប់គ្រួ ទើបនាំគ្នា
ចូលទៅប្រាប់បូចូតាមកិត្តិស័ព្ទដែលឮនោះ ។ បូចូដឹងដូច្នោះទើបប្រឹក្សា
សេនាទាហានទាំងពួងថាកាលយើងទីងលើកកងទ័ពមកប្រាប់ប្រាមកាណា
ខែ១ គ្រមាត់ទទេ ក៏គិតខ្លាចតែម៉ាថេងទីងហ៊ានស៊ុយប៉ុណ្ណោះ ឥឡូវឮដំណឹង
មកថា ម៉ាថេងទីងហ៊ានស៊ុយលើកកងទ័ពមកវាយស្រុកហ៊ូតោហើយ គួរ
ទីងឲ្យនរណាដែលមានថ្វីដៃខ្លាំងពូកែទទួលអាសាចេញទៅការពារបាន ។

ឈឺស៊ីឆ្លើយថា ខ្ញុំបាទមកនៅទីងលោកនេះក៏មិនទាន់បានធ្វើការអ្វី
ឲ្យជាគុណបំណាច់ឡើយ ឥឡូវមានសត្រូវមកបង់ហើយ ខ្ញុំបាទទីងសុំ
អាសាលើកទាហាន ៣ ពាន់ទៅចាក់ចែងជាកក់គយល្បាតប្រុងប្រយ័ត្នស្កាត់
តាមប្រកផ្លូវដែលទៅត្រូវលើស្រុកហ៊ូតោជ.មុន បើសិនណាសឹកសត្រូវ

មកលើសលប់ទឹងទប់ពុំបាន ខ្ញុំបាទទឹងមានសំបុត្របួងមកលោកឲ្យបាន ជ្រាប ។ ចូច្ចូបានឮថា ឈើស៊ីស៊ុំកាសាទៅក៏មានចិត្តត្រេកអរថា ដែលអ្នកទទួលទៅនោះយើងគាប់ចិត្តណាស់ ព្រោះអាហារខាងណោះក៏សល់នៅជាច្រើន ចូរអ្នកបាត់ថែងថែងរំលែកយកទៅចុះ ហើយក៏ប្រមូលអាហារ ៣ ពាន់ថ្ងហោប៉ាជាទ័ពស្រួច ឈើស៊ីទឹងហោប៉ាក៏លាចូច្ចូចេញទៅដល់ស្រុកហ៊ូគោ ។

ឯចូច្ចូលុះវេលាព្រឹកក៏ឡើងសេះនាំអាហារដើរត្រួតមើលបន្ទាយជើងគោកឃើញមាំមួនទាំងអស់ហើយក៏ត្រឡប់មកវិញ លុះវេលាល្ងាចក៏ចុះទូកចេញទៅត្រួតកងទ័ពទឹក ដែលអ៊ូតិម ម៉ាកាយរៀបចំឲ្យចងជាក្បួនទុកជាកង ៗ ហើយបង្គាប់ឲ្យអាហារបាត់ថែងគ្រឿងសស្ត្រាវុធទឹងទូកតាមសើនបន្ទាយ ហើយតែងតុល្បៀងសេនាអាហារទាំងពួង ៗ ក្នុងខណៈនោះព្រះចៅហៀនតេសោយរាជសម្បត្តិបាន ១២ ឆ្នាំ (ព.ស. ៧៤៤) ។ កាលចូច្ចូចុះមកត្រួតកងទ័ពទូកនោះជាខែបុស្ស ១៥ កើត ព្រះចន្ទ្រពេញវង្សត្រចង់ត្រចះជ្រះថ្លា រាត្រីក៏ស្ងប់ស្ងាត់ឈឹង សមុទ្រធំល្ងឹងល្ងើយគ្មានរលកសោះ ទូកខ្មានទាំងអស់ទឹងដូចផែនដី តោះបើទឹងមានរលកខ្យល់បក់បោកមកធំយ៉ាងណា បណ្ដាទូកបញ្ចាំងទាំងអស់នោះក៏មិនរំកើបនឹងប្រែប្រួលទៅណា ទាំងបណ្ដាអាហារក៏មិនមានពុលរលកៗ

ឯចៅភ្នាក់ងារគ្រឿងលេងក្មេងតូចតន្ត្រី ក៏នាំគ្នាដេញចាប៉ីតូចទ្រសូរ ទ្រហឹងអឺងអាច់ ៗ ចូចូឃើញទាហានស៊ុលៀងតាមរបៀបថែរខ្ជាន់ខ្ជាប់ មើលប្រហែល ៣០០ ប៉ាយ នាំគ្នានិយាយពីការសង្គ្រាមទៅវិញទៅមក ខណៈដែលចូចូកំពុងសេពសុរានៅជាកណ្តាលទូកដៃ ជាមួយសេនាទាហានទាំងពួងនោះ ក៏ក្រឡេកមើលទៅលើអាកាស ឃើញខាងស្រុកកាំងតាំងនៅទិសបូព៌ា ទឹងស្រុកកាំងហៃក្បែរមាត់ទន្លេខាងទិសបស្ចិម មើលទៅទិសឧត្តរ ទិសទក្សិណក៏ភ្លឺដោយពន្លឺព្រះចន្ទ្រ ចូចូក៏មានសេចក្តីសោមនស្សរីករាយ ហើយនិយាយនឹងទាហានទាំងពួងថា ពីដើមយើងគិតថា នឹងទំនុកបំរុងផែនដីឲ្យជាសុខ យើងក៏បានធ្វើការប្រាប់ប្រាមសត្រូវរៀងមកជាច្រើនដំបន់ហើយ ឥឡូវនៅសល់តែស្រុកកាំងតាំង ១ ខ្លាំងពូកែជាងគេ ឲ្យអ្នកទាំងពួងរួមប្រមូលឲ្យមូលចិត្តគំនិតគ្នាជួយយើងឲ្យបាន នឹងកំចាត់ស៊ុនគួន, ដើរយើចេញ ហើយស្រុកទេសក៏នឹងនៅជាសុខ យើងទាំងឡាយក៏នឹងបានឃើញមុខគ្នាជាទីសប្បាយ ៗ ទីប្រឹក្សានឹងសេនាទាហានទាំងឡាយបានឮចូចូថាដូច្នោះ ក៏នាំគ្នាគំនាប់ហើយថា សូមឲ្យទេវតាជួយឲ្យបានសម្រេចដូចសេចក្តីប្រាថ្នាចុះ យើងខ្ញុំទាំងឡាយនឹងបានជាទីពឹងតទៅ ៗ (នៅមានត)

# ពាក្យវប្បធម៌

លោក នាង-ហ៊ួ រៀបរៀង

លោក សម-ថាំង ពិនិត្យ

---

## អស់លោកអ្នកអានទាំងឡាយ !

ក្នុងពេលនេះគណៈកម្មការវប្បធម៌សូមជូនការរិះគន់ ចំពោះពាក្យពីរ បី ម៉ាត់ទៀត ហើយដល់ទៅពេលខាងមុខ នឹងលើកយកពាក្យខ្លះដែលបានបង្កើតថ្មី មកធ្វើអត្ថាធិប្បាយពន្យល់អស់លោកអ្នកអាន ឲ្យបានច្បាស់ ដើម្បីងាយស្រួលចំពោះលោកអ្នក ដែលត្រូវការប្រើប្រាស់ នូវពាក្យនីមួយ ៗ តាមគួរដល់ការណ៍ ។

ចំពោះពាក្យពីរបីម៉ាត់ ដែលត្រូវលើកយកមករិះគន់ក្នុងពេលនេះគឺ:

១- អធិបតេយ្យភាព,

២- ឯករាជ្យភាព,

៣- អយស្ម័យយាន, ។

១- អធិបតេយ្យភាព ស័ព្ទនេះយើងធ្លាប់ប្រើមកខ្លះ តាំងពីផ្ទុះការទឹងផ្ទុះសារពត៌មានថា : អធិបតេយ្យភាពៗ តែដៃ តែមាត់គស់ទៅហើយ ៗ ស័ព្ទនេះបើសង្កេតរកឫសគល់ដើម គឺជាពាក្យបាលី ៗ តាមវេយ្យាករណ៍បាលីលោកហៅថា តទ្ធិត (Adjectif dérivée) បានជា

លោកសន្មតហៅថា តទ្ធិត ព្រោះអធិបតេយ្យនេះសំរេចមកពីសព្ទពីរគឺ : “អធិបតិ” មួយសព្ទនឹង “ភាវៈ” ដែលក្លាយមកជាភាពមួយសព្ទ ។ ដល់ចុះណេយ្យប្បច្ច័យ ក្នុងពួកភាវតទ្ធិតមកផ្សំផង បច្ច័យនេះមានអំណាចឈរឈ្មោះជាជំនួសសព្ទថា ភាវៈ ឬ ភាព បានពេញបរិបូណ៌, អធិបតិ+ភាវៈ+អេយ្យៈសម្រេចរូបទៅជា អធិបតេយ្យ ។ បើចង់បទវិគ្រោះ តាមវេយ្យាករណ៍បាលីសម្រាប់បទតទ្ធិតថា អធិបតិនោ-ភាវោ=អធិបតេយ្យំ ប្រែថា ភាពនៃបុគ្គលជាធំ ឬថា ភាពនៃអ្នកធំ (ហៅថាភាវតទ្ធិត) ។ ដូច្នេះ បញ្ជាក់ឲ្យឃើញច្បាស់ថា អធិបតេយ្យនេះ បើត្រូវការចង់និយាយ មិនចាំបាច់យកសព្ទថា «ភាព” មកដាក់ផ្សំពីខាងមុខថា “អធិបតេយ្យភាព» ផងទេ ព្រោះសព្ទថា អេយ្យៈនេះ ចេញមកជាជំនួសសព្ទថាភាវៈ ឬ ភាព ទៅហើយ ។ កាលបើយើងនិយាយថា “អធិបតេយ្យភាព” ។ ដូច្នេះនោះ តាមពិតឃើញមានសព្ទថា “ភាព” នៅក្នុងនេះដល់ពីរដងទៅហើយ ។ គឺអធិបតេយ្យភាពត្រូវប្រែថា «ភាព-ភាពនៃបុគ្គលជាធំ» ស្មើគ្នានឹងពាក្យថា «អធិបតិភាព.ភាព» ដែរ ដោយហេតុនេះ បើយើងចង់ប្រើពាក្យផ្លាស់ប្តូរគ្នា ត្រូវប្រើថា អធិបតិភាព ដែលមានន័យប៉ុនគ្នានឹង អធិបតេយ្យដែរ គឺថាអធិបតិភាព ក៏គឺអធិបតេយ្យ ។ ក៏គឺអធិបតិភាព ប្រែថា ភាពនៃបុគ្គលជាធំដូចគ្នាទាំងពីរសព្ទនេះ ។ ដូច្នេះ បើបែរទៅរកការត្រូវ,

យើងចង់និយាយថា "ភាពនៃបុគ្គលជាធំ" សូមនិយាយតែត្រឹម «អធិបតេយ្យ» ប៉ុណ្ណោះបានហើយ ព្រោះត្រង់ស័ព្ទថា "ភាព" នេះ មាននៅក្នុងបច្ច័យអេយ្យៈស្រាប់ទៅហើយ ។

ឧទាហរណ៍តែមួយ ដែលបានលើកយកមកអធិប្បាយ បញ្ជាក់ជូននេះ សូមលោកអ្នកអានទាំងឡាយ បណ្ដោយស្មារតីទៅកាន់ស័ព្ទដទៃទៀត ដែលជាពួកការតទ្ធិត ចុះបច្ច័យដូចគ្នាតែមួយនេះផងចុះ ដូចជាស័ព្ទថា "ប្រជាធិបតេយ្យ ពជាធិបតេយ្យ, ឯកាធិបតេយ្យ, អនាធិបតេយ្យ រដ្ឋាធិបតេយ្យ» ជាដើម ។ ស័ព្ទទាំងនេះក៏ដូចគ្នានឹងស័ព្ទថា «អធិបតេយ្យ" ដែលបានអធិប្បាយខាងលើនេះដែរ ។ បើត្រូវការនិយាយ មិនចាំបាច់យកស័ព្ទថា «ភាព» មកដាក់ពីខាងមុខទៀតឡើយ ព្រោះពាក្យភាពមានគប់នៅក្នុងនោះស្រាប់ហើយ ។

សុំបញ្ជាក់ជូនទៀតថា ប្រសិនបើចង់និយាយ ឬ សរសេរ នូវស័ព្ទថា "អធិបតិ» ហើយទឹងភាពផងថា "អធិបតិភាព» ហើយអានទៅតាមទម្លាប់ថា «អធិបតីភាព" ដូច្នេះវិញក៏ឥតមានទាស់ខុសអ្វីទេ គ្រាន់តែមានសូរស័ព្ទខុសគ្នា គឺស័ព្ទមួយថា "អធិបតេយ្យ" មួយថា «អធិបតីភាព" ប៉ុណ្ណោះ ។ ប៉ុន្តែចំពោះពាក្យ "អធិបតីភាព, គណៈកម្មការប្រែថា "នៅក្រោមអធិបតីភាព" ដូច្នេះទេ ។

២-ឯកកជ្យភាព ស័ព្ទនេះជាពាក្យសំស្រ្កឹតដែរ ។ កាលណាបើសរសេរថា "ឯកកជភាព" គឺសរសេរ : ឯ-ក-រ ស្រៈអា-ជ-ភ-ស្រៈ អា ហើយនឹងព- ដោយមិនមានដាក់ជើង.យ- ផ្ញើនឹងតួ ជ.ផងទេ ។ ពាក្យថា "ឯកកជភាព" នេះ ទៅជាសមាសនាម ព្រោះរួមមកពីស័ព្ទពីរ គឺ:ឯកកជ ១ នឹងភាព ១ ។ បើយើងប្រើថា "ឯកកជភាព" ដូច្នេះ ក៏បាន ឥតខុសទេ ។

ប៉ុន្តែបើសរសេរថា "ឯកកជ្យភាព" ដោយមានដាក់ជើង.យ-ផ្ញើនឹងអក្សរ ជ ផង ស័ព្ទថាឯកកជ្យៈនេះទៅជ:តទ្ធិតៈទៅវិញ ។ ដូច្នេះ កាលបើសរសេរមិនចាំបាច់ឲ្យមានស័ព្ទថា "ភាព" នៅភ្ជាប់ពីខាងមុខទៀតទេ "ឯកកជ្យភាព" នេះនឹងទៅជាមាន "ភាព" ដល់ទៅពីរជងនៅក្នុងនោះទៅហើយ ។ បានជាហ៊ានអះអាងដូច្នេះ ដោយហេតុស័ព្ទថា "ឯកកជ្យ" នេះ តាមវេយ្យាករណ៍សំស្រ្កឹត ជាភាវៈតទ្ធិត, ចុះណ្យ-បច្ច័យ ។ បើចង់ជាបទវិគ្រោះបាលីថា ឯកកជស្ស ភាវោ=ឯករជ្ជំ, ប្រែថា ភាពនៃស្តេចឯក ។ វិគ្រោះជាសំស្រ្កឹតថា "ឯកកជស្យ ភាវៈ ឯក.កជ្យំ ខ្មែរយើងថា "ឯកកជ្យ" ។ ឯ ណ្យ: បច្ច័យក្នុងភាវតទ្ធិតដែលចុះមកដូច្នេះ អាចផ្លាស់ប្តូរជំនួសស័ព្ទមួយថា "ភាព" បាន ។ ដូច្នេះស ឲ្យឃើញថា "ឯកកជ្យ" នេះគឺមានស័ព្ទថា "ភាព" កប់នៅខាងក្នុង

ស្រាប់ហើយ, បើត្រូវការសរសេរឬនិយាយមិនចាំបាច់ដាក់ «ភាព» ពីខាងមុខទៀតឡើយ ។

សេចក្ដីអធិប្បាយ ជាសង្ខេបដូចបានរៀបរាប់មកខាងលើនេះ ជាសេចក្ដីល្អិតពិបាកយល់បន្តិចចំពោះអស់លោកអ្នកអានខ្លះ ដែលពុំសូវបានសង្កេតពិនិត្យវេយ្យាករណ៍បាលីនិងសំស្ក្រឹត ។ ក៏ប៉ុន្តែជាការចាំបាច់ត្រូវតែលើកកាយយកមកនិយាយ ព្រោះដើម្បីជាគ្រឿងបញ្ជាក់ជូនលោកអ្នកអានឲ្យឃើញច្បាស់ថា បានជាគណៈកម្មការវប្បធម៌ហ៊ានពោលរិះគន់ ចំពោះសព្ទថា «អធិបតេយ្យភាព» នឹង «ឯករាជ្យភាព» ថាខុស ព្រោះអាងទៅលើគោលបារិកដូចបានរៀបរាប់ដោយសង្ខេបខាងលើនេះឯង ។

តាមការសង្កេតរបស់យើងសព្ទថា "ឯករាជ្យភាព" នេះប្រហែលជាអស់លោកអ្នកដែលធ្លាប់សរសេរ ឬ និយាយនោះ ផ្គូតម្រូវទៅនឹងពាក្យបារាំងថា Indépendance ទេដឹង ? ប្រសិនបើការស្មានរបស់យើងនេះ ត្រូវតាមចំណាំរបស់អស់លោកទាំងនោះពិតមែន យើងសូមបញ្ជាក់ជូនថា ពាក្យ Indépendance នេះគណៈកម្មការវប្បធម៌ បានផ្គូទៅនឹងពាក្យខ្មែរយើងថា «ឥស្សរភាព» ដែលបានសេចក្ដីថាភាពជាធំ ឬភាពដែលស្រេចតែនឹងចិត្តទៅវិញទេ ព្រោះ Indépendance បារាំងគេ

ពាក្យថា Etats d'une personne indépendante ។

ដូច្នេះ បើសិនលោកត្រូវការបកប្រែពាក្យ Indépendance នេះ មកជាសេចក្តីខ្មែរ សុំកុំសរសេរថា "ឯករាជ្យភាព" សុំឲ្យប្រើថា "ឥស្សរភាព" ឬឯករាជ្យទៅវិញ ព្រោះពាក្យនេះគណៈកម្មការវប្បធម៌ បានផ្សាយជាផ្លូវការរួចទៅហើយ ។

៣– ពាក្យថា "អយស្ម័យយាន" ត្រូវអានថា «អៈយ៉ុស.ស្មៃយាន» កុំអានថា "អៈយៈស្មៃយាន" ឬអៈយ៉ុស.ស្មៃយៈយាន« ឡើយ ។

ពាក្យនេះ គណៈកម្មការវប្បធម៌ បានបង្កើតឡើងព្រមទាំងបានផ្សាយតាមផ្លូវការជាយូរមកហើយ ។ តាមការសង្កេតឃើញថាជនជាតិយើងទម្លាប់ប្រើពាក្យនេះតាមផ្លូវការស្រួលមាត់ ស្រួលត្រចៀក លែងឆាស់លែងតាស់គួងទៅហើយ ។ ទាំងភ្នាក់ងាររាជការផ្នែកខាងក្រុមត្រួតត្រាពជអយស្ម័យយានរបស់ប្រទេសយើង ក៏បានយកពាក្យនេះ ទៅប្រើប្រាស់ពេញលក្ខណៈដែរ ។ គេតែងឃើញសរសេរដាក់នៅពាសពេញតែកន្លែងនៅក្នុងក្រុមនោះ ។ ក៏ប៉ុន្តែ ពាក្យចចាមអារាមរមែងតែឮសូរពោលរិះគន់ថា គណៈកម្មការវប្បធម៌ បេះតែជ្រើសរកតែពាក្យណាដែលលំបាក ដែលគេមិនធ្លាប់ដឹង, មិនធ្លាប់និយាយ យកមកដាក់ឲ្យគេ

ប្រើ, ឲ្យគេនិយាយ នាំឲ្យតែលំបាកប្រើ ៗ ដូចពាក្យអយស្ម័យយាននេះ ចាំបាច់បង្កើតមកធ្វើអ្វី បើមានពាក្យខ្មែរសម្រាប់ប្រើហៅថា រថ-ភ្លើង, រទេះភ្លើងស្រាប់មកហើយ ៗ

ការពោលរិះគន់ដូច្នេះ គឺជាការមួយគួរឲ្យចាប់អារម្មណ៍ដែរ ៗ គណៈកម្មការវប្បធម៌ មានសេចក្ដីត្រេកអរក្រៃលែង ចំពោះការរិះគន់នេះព្រោះជាករណីយ៍មួយនាំឲ្យគណៈកម្មការ បាននូវចំណុចទីងធ្វើអធិប្បាយជូនអស់លោកអ្នកអាន ឲ្យបានយល់ច្បាស់ អំពីពាក្យអយស្ម័យយាននោះ ៗ

អស់លោកអ្នកអានទាំងឡាយ ! ចំពោះពាក្យថា អយស្ម័យយាននេះ សូមលោកអ្នកជ្រាបដូចតទៅ ៖

ហេតុខាងដើម ពាក្យនេះពុំមែនគណៈកម្មការវប្បធម៌ ជ្រើសរើសរកដោយឯង ៗ ទេ ៗ តាមពិត មុនដំបូងលោកអ្នកត្រួតត្រាកិច្ចការ ខាងក្រុមអយស្ម័យយាន បានស្រង់យកពាក្យតិកនិកជាភាសាបារាំង ជាច្រើនពាក្យ សម្រាប់ប្រើការខាងមុខក្រសួងខ្លួននោះ ផ្ញើទៅឲ្យគណៈកម្មការវប្បធម៌ ដើម្បីជ្រើសរើសរកពាក្យដែលមានសូរស័ព្ទជាខ្មែរយកមកផ្គុំ ហើយមានបញ្ជាក់ថា សុំគណៈកម្មការជ្រើសរើសរកពាក្យខ្មែរ យកមកផ្គុំនោះ ឲ្យមានទំហំប៉ុន ៗ គ្នានឹងពាក្យបារាំង កុំឲ្យខ្វះកុំឲ្យលើស ៗ ព្រោះហេតុនេះហើយ បានជាគណៈកម្មការវប្បធម៌ ជ្រើសរើសបានពាក្យ

ថា អយស្ម័យយាននេះ យកមកផ្ទឹមនឹងពាក្យបារាំងថា «Chemin de fer»

សព្ទថា "អយស្ម័យ" នេះជាគុណនាម សម្រេចមកពីពាក្យសំស្ក្រឹត "អយស៑ និង មយ:" យកតួ "ស" តម្រួតលើតួ "ម" បានជា អយស្មយ: ឬអយស្ម័យ, បើជាពាក្យបាលីវិញថា "អយោមយ: ឬ អយោម័យ ។ អយស៑ប្រែថា "ដែក," "មយ:" ប្រែថា "ផ្សំមក, សម្រេចមក," រួមគ្នាទៅថា ដែលធ្វើដោយដែក, ដែលយកដែកធ្វើ (ពុំមែនធ្វើអំពីដែកទេ ព្រោះដែកនៅជាដែកដដែល) ។ យាន: ឬយាន ជាពាក្យសំស្ក្រឹត និង បាលី ប្រែថា "គ្រឿងដឹកនាំ, គ្រឿងនាំបន្ទុកទៅមក គ្រឿងសម្រាប់ជិះ ។ អយស្ម័យយាន ប្រែថា "គ្រឿងសម្រាប់ជិះ ដែលធ្វើដោយដែក" ឬ ជាដែលលឿនទៅតាមផ្លូវដែក ។

Chemin de fer គណ:កម្មការវប្បធម៌ បង្កើតពាក្យថា អយស្ម័យមាគ៌ាយាន, ប៉ុន្តែដោយយល់ឃើញថាវែងណាស់ពិបាកហៅ គឺកាត់ពាក្យមាគ៌ាចេញ ទុកឲ្យនៅត្រឹមតែអយស្ម័យយាន ។ សុំបញ្ជាក់មួយថែមទៀត ត្រូវអានថា អ:យ៉ុស-ស្មៃ-យាន ពុំមែនអានថា អ: យ:-ស្មៃ យាន ឬអ, យ៉ុសស្មៃយ:យានទេ ។ ដូច្នេះអាចបញ្ជាក់ឲ្យឃើញថា ការរិះគន់យ៉ាងនេះ ពុំសមហេតុសមផលឡើយ, ព្រោះពាក្យដែលគណ:កម្មការវប្បធម៌ បានបង្កើតឲ្យមានឡើងនេះ សុទ្ធសឹងតែខំប្រឹងរិះរកដោយហ្មត់ចត់ ផ្ទឹមឲ្យស្មើ

នឹងពាក្យបារាំងថា Chemin de fer ពុំមែនឲ្យស្មើនឹងពាក្យថា (Voiture de fer) ឬ Charrêtte de fer ទេ ។ ពាក្យថាអយស្ម័យយាន Chemin de fer នេះ សម្រាប់ប្រើជា បោរីភាសា ឬបោរីភាព សម្រាប់ប្រទេសឯករាជ្យប៉ុណ្ណោះ ។ ឯពាក្យថារថភ្លើងក្តី, រទេះភ្លើងក្តី បើនឹងចាត់ថាជាគ្រាមភាសា ឬភាសាសាមញ្ញ សម្រាប់ជាតិខ្មែរយើងក៏បាន គឺយើងអាចប្រើជាភាសាសាមញ្ញ និយាយស្តីប្រាស្រ័យគ្នាបានតាមធម្មតា ឥតមានទោសកំហុសអ្វីទេ ដូចជារថយន្ត, ទោចក្រយាន, ត្រីចក្រយាន ជាដើម ដូច្នោះដែរ យើងចង់ហៅថាឡាន, កង់ ស៊ីក្លូ តាមទម្លាប់ក៏បាន ។ល។ សូមអស់លោកអ្នកជ្រាប ។

នៅទីបំផុតនេះ យើងសុំអស់លោកអ្នកអាន បំបែរយោបល់ទៅរកពាក្យបារាំងវិញមើល ៖ លោកអ្នកគង់នឹងឃើញថា ត្រង់ពាក្យសម្រាប់ហៅយានប្រភេទនេះ បារាំងគេមានពាក្យច្រើនគឺ Rail, Locomotive chemin de fer ដែរ ពុំមែនមានពាក្យតែ ១ ម៉ាត់នោះទេ ។

ត្រង់ពាក្យថា រថអយស្ម័យយាននេះ ប្រសិនបើគណៈកម្មការវប្បធម៌បង្កើតវិញ យើងពេញចិត្តថា រថាយស្ម័យយាន ។ គឺមកពីរថៈនឹងអយស្ម័យយានស្រួលមាត់ហៅជាង រថអយស្ម័យយាន ។

---

## ផ្នែកគំណាត់នឹងប្រវត្តិការណ៍

# ការធ្វើសន្និសីទ

### អំពីការសិក្សាខាងព្រះពុទ្ធសាសនា

### នៅសហរដ្ឋអាមេរិក

### ដោយលោកបណ្ឌិត វិស្សា ឯ គារ៉េ

### ចំពោះសមណនិស្សិត នឹង សាស្ត្រាចារ្យទាំងឡាយ

### នៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ នឹង

### ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត

លោក អៀង-គុណ-សាគី

អគ្គលេខាធិការ នៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ រៀបរៀង

---

មុនដំបូង យើងសូមថ្លែងអំពីបុព្វហេតុ ដែលនាំឲ្យលោកបណ្ឌិត វិស្សា ឯ គារ៉េ បានអញ្ជើញមកធ្វើសន្និសីទ ដូចសេចក្ដីតទៅនេះ ៖

លោកបណ្ឌិត វិស្សា ឯ គារ៉េ ជាតិអាមេរិកាំង ជាទីប្រឹក្សានៃមូលនិធិអាស៊ីផង ជាសាស្ត្រាចារ្យបង្រៀនវិជ្ជាខាងព្រះពុទ្ធសាសនា នៅសាកលវិទ្យាល័យយ៉េល ក្នុងសហរដ្ឋអាមេរិកផង ។ លោកបណ្ឌិតនេះជាអ្នកត្រិះរិះរករឿងរ៉ាវខាងព្រះពុទ្ធសាសនា លោកបានចេះដឹងលទ្ធិព្រះពុទ្ធសាសនាទាំងពីរយ៉ាង គឺលទ្ធិខាងថេរវាទ នឹងមហាយាន ។ លោក

ធ្លាប់បានអញ្ជើញមកប្រទេសកម្ពុជាយើងនេះ ជាច្រើនដងហើយ ។ កាលពីឆ្នាំ ១៩៥៨ លោកបានអញ្ជើញមកធ្វើសន្និសីទ អំពីរឿងព្រះពុទ្ធ-សាសនាម្ដងហើយ នៅក្នុងបរិវេណនៃពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត ចំពោះសាធារណៈជន ជាពិសេសចំពោះសមណនិស្សិត ។

កាលពីថ្ងៃទី ២២ កក្កដានេះ លោកបណ្ឌិតវិស្សុ ឯ តារ៉េ បានអញ្ជើញមកដល់ក្រុងភ្នំពេញ ហើយលោកអញ្ជើញទៅថ្វាយបង្គំសម្តេចព្រះសង្ឃនាយក បានទៅសន្ទនាជាមួយសមាគមព្រះពុទ្ធសាសនា ជាមួយនឹងព្រះសង្ឃព្រមទាំងពុទ្ធបរិស័ទខ្លះ ។

ព្រះតេជព្រះគុណព្រះពោធិវង្ស ជាអគ្គាធិការនៃពុទ្ធិកសិក្សា ដោយលោកធ្លាប់បានស្គាល់លោកបណ្ឌិតនេះ តាំងពីក្នុងកាលដែលលោកបានធ្វើដំណើរទៅកាន់សហរដ្ឋអាមេរិកពីឆ្នាំ ១៩៤៦ ទើបលោកទៀតយកឱកាសនេះ អញ្ជើញលោកបណ្ឌិត តារ៉េ ឲ្យធ្វើសន្និសីទអំពីការសិក្សាខាងព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក ចំពោះសមណនិស្សិតទាំងឡាយដែលកំពុងសិក្សាសព្វថ្ងៃ ក្នុងពុទ្ធិកមហាវិទ្យាល័យ និង ពុទ្ធិកវិទ្យាល័យ ដើម្បីឲ្យសមណនិស្សិតទាំងឡាយនោះបានដឹងបានយល់ថា ការសិក្សាខាងព្រះពុទ្ធសាសនា មិនមែនមានតែក្នុងប្រទេសយើងដែលជាប្រទេសធ្លាប់មានព្រះពុទ្ធសាសនារាប់ពាន់ឆ្នាំមកហើយនោះទេ សូម្បីប្រទេស

ទាំងឡាយដែលមិនធ្លាប់មានព្រះពុទ្ធសាសនា ក៏គង់តែគេបង្កើតឲ្យមានការសិក្សាខាងព្រះពុទ្ធសាសនាដែរ ព្រោះថាព្រះពុទ្ធសាសនា ជាសាសនាប្រកបដោយហេតុផល មនុស្សគ្រប់ប្រទេសក្នុងសាកលលោកមានសហ-រដ្ឋអាមេរិកជាដើម ទោះបីគេមិនប្រាថ្នាកាន់តាមក៏ដោយគង់គេត្រូវការចង់ចេះចង់ដឹងដែរ ។

អាស្រ័យហេតុដូចខាងលើនេះ ទើបព្រះតេជព្រះគុណព្រះពោធិវង្ស បានអញ្ជើញលោកដុកទ័រ គីរទ៍ ឲ្យធ្វើសន្និសីទដោយក្រសួងធម្មការបានយល់ព្រមផង ដូចបានរៀបរាប់រួចមកហើយ ។ លោកដុកទ័រ គីរទ៍ ក៏បានទទួលដោយរីករាយ ។

ដូច្នេះ បានជាកាលពីថ្ងៃអាទិត្យទី ២៤ កក្កដា ១៩៦០ ពេលម៉ោង ១៦ លោកបណ្ឌិតវិស្វា ឯ គីរទ៍ បានអញ្ជើញទៅកាន់បណ្ណាល័យនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដោយមានលោកដុកទ័រ ហ្វារ៉ាំ ជាតំណាងនៃមូលនិធិអាស៊ីជូនទៅផង ។ ក្នុងបណ្ណាល័យនោះ មានការជួបជុំសមណ-និស្សិត និងសាស្ត្រាចារ្យព្រមទាំងបុគ្គលិកក្នុងពុទ្ធិកវិទ្យាល័យ មួយអន្លើដោយលោកនាយការិយាល័យ ក្រសួងធម្មការតំណាងលោករដ្ឋមន្ត្រី រួមទាំងអស់ប្រមាណ ៤០០ នាក់ ។

មុននឹងធ្វើសន្និសីទនោះ ព្រះតេជព្រះគុណព្រះពោធិវង្ស បានរៀប

រាប់សង្ខេបអំពីប្រវត្តិនៃលោកបណ្ឌិត គ៊ារទ៍ នឹងហេតុដែលត្រូវធ្វើសន្និសីទ រួចបានជូនឱកាសដល់លោកដុកទ័រ ។

លោកដុកទ័រគ៊ារទ៍ បានធ្វើសន្និសីទក្នុងពេលនោះអស់រយៈកាលជាង ១ ម៉ោងទើបចប់ ។ លោកថ្លែងជាភាសាអង់គ្លេស ហើយលោកជា-ទន់ សាស្ត្រាចារ្យបង្រៀនភាសាអង់គ្លេសនៅពុទ្ធិកវិទ្យាល័យ ជាអ្នកប្រែមកជាភាសាខ្មែរ ។

យើងសូមដកស្រង់យកតែត្រង់គោលចំណុចខ្លះ ៗ នៃសន្និសីទនោះមកថ្លែងជូនដូចតទៅនេះ :

លោកដុកទ័រ គ៊ារទ៍ បានថ្លែងថា :

-ក្នុងសហរដ្ឋអាមេរិក មានសាកលវិទ្យាល័យជាច្រើន មានសា-កលវិទ្យាល័យ យ៉េល ជាដើម ដែលមានសិក្សាខាងព្រះពុទ្ធសាសនា ,

-ពួកនិស្សិតដែលទទួលការសិក្សាខាងព្រះពុទ្ធសាសនា គឺសិក្សាដោយយកចិត្តទុកដាក់ណាស់ ,

-សាស្ត្រាចារ្យដែលបង្រៀនព្រះពុទ្ធសាសនា ច្រើនតែជាតិជប៉ុន ដែលមានការចេះដឹងច្រើន,

-ក្រៅពីជាតិជប៉ុន មានសាស្ត្រាចារ្យជាតិអាមេរិកាំងខ្លះ ជាតិបារាំងសែសខ្លះ ,

-ចំពោះការសិក្សាព្រះពុទ្ធសាសនា  បើអ្នកសិក្សាបានចេះដឹងវិជ្ជាច្រើនយ៉ាង  វិជ្ជានោះអាចនឹងធ្វើជំនួយជួយឲ្យអ្នកសិក្សាមានការភ្លឺស្វាងច្រើន ហើយនឹងនាំឲ្យកាន់តែបានចេះដឹងយល់ផ្លូវព្រះពុទ្ធសាសនា ជាក់ច្បាស់ឡើងទៀត ,

-ចំពោះភាសា  បើអ្នកសិក្សាបានចេះភាសាឲ្យច្រើនដូចជាភាសាអង់គ្លេស ភាសាបារាំងសែស  ភាសាចិន-ទីបេត៍ ជាដើម ផ្សំជាមួយនឹងភាសាជាតិរបស់ខ្លួន  នឹងនាំអ្នកសិក្សាខាងព្រះពុទ្ធសាសនា ងាយយល់ទូលំទូលាយក្នុងរឿងព្រះពុទ្ធសាសនា  ដោយបានយកសៀវភៅដែលនិយាយពីព្រះពុទ្ធសាសនា ជាភាសាផ្សេងៗ ទាំងនោះមកពិនិត្យប្រៀបធៀប ។

-ចំពោះសហរដ្ឋអាមេរិក ដែលសព្វថ្ងៃនេះកំពុងមានការសិក្សាខាងព្រះពុទ្ធសាសនាមែនហើយ  ប៉ុន្តែពុំទាន់មានអង្គការនៃព្រះពុទ្ធសាសនាឲ្យដូចជានៅក្នុងប្រទេសកម្ពុជាយើងនេះនៅឡើយ  គឺពុំទាន់មានវត្តអារាម ពុំទាន់មានព្រះសង្ឃ  ពុំទាន់មានអ្នកគោរពប្រតិបត្តិកាន់ឲ្យបានបរិបូណ៌នៅឡើយ ។ ប៉ុន្តែមានសង្ឃឹមថា តទៅក្នុងអនាគត ប្រសិនបើមានការសិក្សាចំរើនឡើង  អ្នកសិក្សាក៏យកចិត្តទុកដាក់ ហើយមានជំនឿ គង់តែនឹងមានព្រះសង្ឃ មានពុទ្ធបរិស័ទពុំខាន ។

កាលដែលលោក ដុកទ័រ តារ៉េ បញ្ចប់សន្និសីទហើយ មានសមណនិស្សិតច្រើនរូបបានសួរលោកដុកទ័រនោះ អំពីបញ្ហាផ្សេងៗ ខាងការសិក្សាព្រះពុទ្ធសាសនា សួរជាភាសាអង់គ្លេស លោកដុកទ័រក៏បានឆ្លើយតបវិញរហូតដល់ម៉ោង ១៧ កន្លះទើបចប់ ។ កាលដែលចប់ហើយ ព្រះតេជព្រះគុណ ព្រះពោធិវង្ស បានថ្លែងអំណរគុណចំពោះលោកដុកទ័រ ដែលបានធ្វើសន្និសីទ អំពីការសិក្សាព្រះពុទ្ធសាសនា នាំឲ្យសមណនិស្សិតទាំងឡាយមានការចាប់អារម្មណ៍ជាច្រើន ។

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិទបិ៌ត គុ. ដែលកោង, ដែលក្រអឺត ។

អតិទសិ៌ន គុ. ដែលមើលឃើញឆ្ងាយ ។

អតិទហ៑ ធាតុ. ឆេះក្រៃលែង; ធ្វើឲ្យទំនាស់ ។

អតិទហនាត្មក គុ. ដែលមានអាត្មាក្តៅក្រហាយក្រៃពេក ។

អតិទាតឫ ការ. ន. អ្នកឲ្យទានក្រៃលែង ។

អតិទាន នបុំ អតិទាន, កិរិយាឲ្យក្រៃលែង ។

អតិទារុណ គុ. ទារុណក្រៃលែង ។

អតិទាហ បុំ. កិរិយាឆេះក្រៃលែង; កិរិយារលាកក្រៃលែង ។

អតិទិឝ៑ ធាតុ. ពង្អុលក្រៃពក, កំណត់, បញ្ជូន ។

អតិទីប្ត គុ. ដែលឆេះសន្ធោ, ដែលភ្លឺក្រៃលែង ។

អតិទីប្តិ ស្ត្រី. ពន្លឺក្រៃលែង ។

អតិទីឃ៌ គុ. វែងក្រៃពេក ។

អតិទីវ៑ ធាតុ. លេងក្រៃពេក; ភ្នីក្រៃលែង ។

(នៅមានត)